# អនុសញ្ញាអង្គការសហប្រជាជាតិ
# ប្រឆាំងនឹងអំពើពុករលួយ

# អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ

## បុព្វកថា

### ភាគីរដ្ឋទាំងអស់ក្នុងអនុសញ្ញានេះ

ដោយមានការព្រួយបារម្ភពីភាពធ្ងន់ធ្ងរនៃបញ្ហា និងការគំរាមកំហែងដែលបង្កឡើងដោយអំពើពុករលួយចំពោះស្ថេរភាពនិងសន្តិសុខសង្គម ដែលធ្វើអោយអន្តរាយដល់ស្ថាប័ននិងតំលៃលទ្ធិប្រជាធិបតេយ្យ តំលៃក្រមសីលធម៌ យុត្តិធម៌និងការធ្វើអោយគ្រោះថ្នាក់ដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព និងនីតិរដ្ឋ ។

ដោយមានការព្រួយបារម្ភផងដែរ អំពីទំនាក់ទំនងរវាងអំពើពុករលួយនិងឧក្រិដ្ឋកម្មគ្រប់រូបភាពដទៃទៀតជាពិសេសឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងឧក្រិដ្ឋកម្មសេដ្ឋកិច្ច ដោយរួមទាំងការលាងលុយផងដែរ ។

ដោយមានការព្រួយបារម្ភបន្ថែមទៀតអំពីករណីអំពើពុករលួយ ជាប់ពាក់ពន្ធ័នឹងបរិមាណធំធេងនៃទ្រព្យសម្បត្តិ ដែលអាចបង្កើតសមាមាត្រដែលមានសារៈសំខាន់នៃធនធានរបស់រដ្ឋ ហើយគំរាមកំហែងដល់ស្ថេរភាពនយោបាយ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពរបស់រដ្ឋទាំងនោះ ។

ដោយមានការព្រួយបារម្ភថា អំពើពុករលួយគឺលែងជាបញ្ហានៅក្នុងតំបន់ទៀតហើយ ប៉ុន្តែវាគឺជាបាតុភូតឆ្លងដែនដែលជះឥទ្ធិពលដល់សង្គមនិងសេដ្ឋកិច្ចទាំងអស់ ជាការសំខាន់ណាស់ដែលត្រូវមានកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បី ការពារនិងត្រួតពិនិត្យអំពើពុករលួយ ។

ដោយទទួលស្គាល់ផងដែរថាត្រូវការដំណោះស្រាយទូលំទូលាយមួយដើម្បីការពារ និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធិភាព ។

ដោយទទួលស្គាល់បន្ថែមទៀតថា វត្តមាននៃជំនួយបច្ចេកទេសអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកំពស់សមត្ថភាពរបស់រដ្ឋ រួមមានតាមរយៈការពង្រឹងសមត្ថភាពនិងការបង្កើតស្ថាបន័ ដើម្បីការពារនិងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្របកដោយប្រសិទ្ធិភាព។

ដោយមានជំនឿថា ការទទួលទ្រព្យសម្បត្តិផ្ទាល់ខ្លួនខុសច្បាប់អាចនឹងធ្វើអោយខូចខាតជាពិសេសដល់ស្ថាបន័លទ្ធិប្រជាធិបតេយ្យ សេដ្ឋកិច្ចជាតិនិងក្រិតក្រមច្បាប់ ។

ដោយបានប្តេជ្ញាចិត្តដើម្បីការពារ លុបបំបាត់ និងធ្វើអោយញៀញើតដល់ការផ្ទេរជាលក្ខណៈអន្តរជាតិនៃទ្រព្យសម្បត្តិដែលបានទទួលដោយខុសច្បាប់តាមបែបបទកាន់តែមានប្រសិទ្ធិភាព និងដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិក្នុងការយកទ្រព្យសម្បត្តិទាំងនោះមកវិញ។

ដោយទទួលស្គាល់គោលការណ៍ជាសារវន្តនៃដំណើរការច្បាប់ដែលកំណត់នៅក្នុងបណ្តឹងព្រហ្មទណ្ឌ និងនៅក្នុងបណ្តឹងរដ្ឋបាល រឺរដ្ឋប្បវេណីដើម្បីវិនិច្ឆ័យទោសលើកម្មសិទ្ធិបញ្ញា ។

ដោយចាំទុកក្នុងចិត្តថា ការការពារនិងការបំបាត់អំពើពុករលួយគឺជាការទទួលខុសត្រូវរបស់រដ្ឋទាំងអស់ ហើយថា ពួកគេត្រូវតែសហការគ្នាទៅវិញទៅមកដោយមានការគាំទ្រនិងការជាប់ពាក់ពន្ធ័របស់បុគ្គលនិងក្រុមខាងក្រៅផ្នែកសាធារណៈ ដូចជាសង្គមស៊ីវិលអង្គការក្រៅរដ្ឋាភិបាលនិងអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍ ប្រសិនបើធ្វើអោយកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេនៅក្នុងតំបន់នេះមានប្រសិទ្ធិភាព ។

ដោយចាំទុកក្នុងចិត្តផងដែរនូវគោលការណ៍នៃការគ្រប់គ្រងកិច្ចការសាធារណៈនិងទ្រព្យសម្បត្តិសាធារណៈត្រឹមត្រូវ ស្មើភាពគ្នា ការទទួលខុសត្រូវនិងសមភាពនៅចំពោះមុខច្បាប់និងសេចក្តីត្រូវការដើម្បីការពារសេចក្តីថ្លៃថ្នូរ និងដើម្បីលើកតំកើងប្រពៃណីនៃការបដិសេធន៍អំពើពុករលួយ ។

ដោយលើកតំកើងការងាររបស់គណៈកម្មាធិការទប់ស្កាត់ឧក្រិដ្ឋកម្មនិងយុត្តិធមិព្រហ្មទណ្ឌ និងការិយាល័យគ្រឿងញៀននិងបទឧក្រិដ្ឋរបស់អង្គការសហប្រជាជាតិ ក្នុងការទប់ស្កាត់និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។

ដោយរំលឹកឡើងវិញនូវការងារដែលបានអនុវត្តដោយអង្គការតំបន់និងអន្តរជាតិនៅក្នុងវិស័យនេះ រួមមានសកម្មភាពរបស់សហគមន៍អាហ្វ្រិច ក្រុមប្រឹក្សាអឺរ៉ុប ក្រុមប្រឹក្សាសហប្រតិបត្តិការគយ (ដែលត្រូវគេស្គាល់ផងដែរថាជា អង្គការគយពិភពលោក) សហគមន៍អឺរ៉ុប សម្ពន្ធ័រដ្ឋអារ៉ាប់ អង្គការសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ និងអង្គការរដ្ឋអាមេរិក ។

ដោយកត់សំគាល់ជាមួយនឹងការកើនឡើងនៃឯកសារពហុភាគីដើម្បីការពារ និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមមាន អនុសញ្ញាអន្តរៈអាមេរិកប្រឆាំងនឹងអំពើពុករលួយដែលបានអនុមត័ដោយអង្គការរដ្ឋអាមេរិកនៅថ្ងៃទី ២៩ មីនា ១៩៩៦[១] អនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដែលជាប់ពាក់ពន្ធ័នឹងមន្ត្រីរបស់សហគមន៍អឺរ៉ុប រឺមន្ត្រីនៃរដ្ឋសមាជិកសហគមន៍អឺរ៉ុបដែលបានអនុមត័ដោយក្រុមប្រឹក្សាសហគមន៍អឺរ៉ុបនៅថ្ងៃទី ២៦ ឧសភា ១៩៩៧[២] អនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងនឹងការស៊ីសំណូករបស់មន្ត្រីសាធារណៈការបទេសក្នុងផ្នែកជំនួញអន្តរជាតិដែលបានអនុមត័ដោយអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ នៅថ្ងៃទី ២១ វិច្ឆកា ១៩៩៧[៣] អនុសញ្ញាច្បាប់ព្រហ្មទណ្ឌ ស្តីពីអំពើពុករលួយដែលបានអនុមត័ដោយគណៈកម្មាធិការរដ្ឋមន្ត្រីនៃក្រុមប្រឹក្សាអឺរ៉ុបនៅថ្ងៃទី ២៧ មករា ១៩៩៩[៤] អនុសញ្ញាច្បាប់រដ្ឋប្បវេណី ស្តីពីអំពើពុករលួយដែលអនុមត័ដោយគណៈកម្មាធិការរដ្ឋមន្ត្រីនៃក្រុមប្រឹក្សាអឺរ៉ុបនៅថ្ងៃទី ៤ វិច្ឆកា ១៩៩៩[៥] អនុសញ្ញាសហគមន៍អាហ្វ្រិកស្តីពីការការពារនិងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដែលបានអនុមត័ដោយប្រមុខរដ្ឋនិងរដ្ឋាភិបាលរបស់សហគមន៍-អាហ្វ្រិក នៅថ្ងៃទី ១២ កក្កដា ២០០៣ ។

ដោយស្វាគមន៍ការចូលជាធរមាននៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងបទឧក្រិដ្ឋ[6] ឆ្លងដែនដែលមានអង្គការចាត់តាំង ។

បានយល់ព្រមដូចតទៅ:

## ជំពូក ១

## ប្រការទូទៅ

### មាត្រា ១

### គោលបំណង

គោលបំណងនៃអនុសញ្ញានេះគឺ :

ក. ដើម្បីជំរុញនិងពង្រឹងវិធានការការពារនិងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយអោយកាន់តែមានប្រសិទ្ធិភាព និងមានផលល្អ ។

ខ. ដើម្បីជំរុញ ជួយសំរួលនិងគាំទ្រដល់សហប្រតិបត្តិការអន្តរជាតិ និងជំនួយបច្ចេកទេសក្នុងការទប់ស្កាត់ និងការប្រឆាំងនឹងអំពើពុករលួយដែលមានរាប់បញ្ចូលនៅក្នុងការដកហូតទ្រព្យសម្បត្តិមកវិញ ។

គ. ដើម្បីជំរុញលើកកំពស់សេចក្តីថ្លៃថ្នូរ ការទទួលខុសត្រូវនិងការគ្រប់គ្រងកិច្ចការសាធារណៈ និងទ្រព្យសម្បត្តិសាធារណៈត្រឹមត្រូវ ។

### មាត្រា ២

### ការប្រើប្រាស់ពាក្យ

សំរាប់គោលបំណងនៃអនុសញ្ញានេះ :

ក. "មន្ត្រីសាធារណៈ" មានន័យថា : (i) ជនណាដែលកាន់ការិយាល័យនីតិបញ្ញត្តិ ការិយាល័យនីតិប្រតិបត្តិ ការិយាល័យរដ្ឋបាល រឺការិយាល័យយុត្តិធម៌របស់ភាគីរដ្ឋមួយ ទោះជាបានតែងតាំង រឺបោះឆ្នោតជ្រើសរើស ទោះជាបណ្តោះអាសន្ន រឺអចិន្ត្រៃយ៍ ទោះជាអោយប្រាក់ រឺមិនអោយប្រាក់ខែក៏ដោយ មិនគិតពីឧត្តមភាព

របស់ជននោះឡើយ (ii) ជនណាក៏ដោយដែលបំពេញមុខងារសាធារណៈ រួមមានសំរាប់ភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ រឺដែលផ្តល់សេវាកម្មសាធារណៈដូចដែលបានចែងនៅក្នុងច្បាប់ប្រទេសរបស់ភាគីរដ្ឋ ហើយ

---

5 Ibid., No. 174

6 General Assembly resolution 55/25, annex I.

ដូចដែលបានអនុវត្តនៅក្នុងផ្នែកជាប់ទាក់ទងនៃច្បាប់របស់ភាគីរដ្ឋនោះ (iii)ជនណាក៏ដោយដែលបានកំណត់ជា "មន្ត្រីសាធារណៈ"នៅក្នុងច្បាប់ប្រទេសរបស់ភាគីរដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះគោលបំណងនៃវិធានការណ៏ជាក់លាក់មួយចំនួនដែលមាននៅក្នុងជំពូក II នៃអនុសញ្ញានេះ "មន្ត្រីសាធារណៈ"អាចមានន័យថា ជនណាក៏ដោយដែលបំពេញមុខងារសាធារណៈ រឺផ្តល់សេវ៉ាកម្មសាធារណៈដូចដែលបានកំណត់នៅក្នុងច្បាប់ប្រទេសរបស់ភាគីរដ្ឋ ហើយដូចដែលបានអនុវត្តនៅក្នុងផ្នែកដែលជាក់ទាក់ទងនៃច្បាប់របស់ភាគីរដ្ឋនោះ។

ខ. "មន្ត្រីសាធារណៈបរទេស" មានន័យថា ជនណាដែលកាន់ដំណែង ជនណាដែលកាន់ដំណែងនីតិបញ្ញត្តិ ដំណែងនីតិប្រតិបត្តិ ដំណែងរដ្ឋបាល រឺដំណែងយុត្តិធម៌របស់ប្រទេសក្រៅ ទោះជាបានតែងតាំង រឺបោះឆ្នោតជ្រើសរើសក៏ដោយ និងជនណាដែលអនុវត្តមុខងារសាធារណៈសំរាប់ប្រទេសក្រៅ រួមមានចំពោះភ្នាក់ងារសាធារណៈ រឺសហគ្រាសសាធារណៈ ។

គ. "មន្ត្រីអង្គការអន្តរជាតិសាធារណៈ" មានន័យថា មន្ត្រីស៊ីវិលអន្តរជាតិម្នាក់ រឺជនណាក៏ដោយដែលត្រូវបានផ្តល់អាជ្ញាអោយដោយអង្គការដើម្បីអោយធ្វើការតាងនាមអោយអង្គការនោះ ។

ឃ. "ទ្រព្យសម្បត្តិ" មានន័យថា ទ្រព្យគ្រប់ប្រភេទ ទោះជាមានរូបរាង រឺគ្មានរូបរាង អាចរំកិលបានរឺមិនអាចរំកិលបាន អាចស្ទាបបានរឺមិនអាចស្ទាបបាន និងទោះជាឯកសារស្របច្បាប់ រឺឧបករណ៏ដែលបង្ហាញអោយឃើញច្បាស់លាស់នូវឈ្មោះកម្មសិទ្ធិ រឺផលប្រយោជន៏នៅក្នុងទ្រព្យទាំងនោះ ។

ង. "ផលនៃបទល្មើស" មានន័យថា ទ្រព្យណាក៏ដោយដែលបានមកពី រឺទទួលបានដោយផ្ទាល់ រឺដោយប្រយោលតាមរយៈការប្រព្រឹត្តិបទល្មើស ។

ច. "ការបង្កក" រឺ "ការរឹបអូស" មានន័យថា ការហាមឃាត់ការផ្ទេរ ការផ្លាស់ប្តូរ ការចែកចាយ រឺការបំលាស់ទីទ្រព្យសម្បត្តិជាបណ្តោះអាសន្ន រឺជាការបង្ខាំង រឺការត្រួតពិនិត្យមើលទ្រព្យសម្បត្តិជាបណ្តោះអាសន្ន តាមដីការដែលចេញដោយតុលាការ រឺអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត។

ឆ. "ការរឹបអូស" ដែលរួមមានការពិន័យនៅពេលណាសមស្រប មានន័យថា ការដកហូតជាអចិន្ត្រៃយ៍នៃទ្រព្យសម្បត្តិណាមួយតាមរយៈដីការរបស់តុលាការ រឺអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ។

ជ. "បទល្មើសដើម" មានន័យថា បទល្មើសទាំងឡាយណាដែលតាមរយៈបទល្មើសនេះបង្កើតបានផលដែលអាចក្លាយជាប្រធានបទនៃបទល្មើសដូចដែលបានកំណត់នៅក្នុងមាត្រា ២៣នៃអនុសញ្ញានេះ ។

**ឈ.** "តស៊ូករណី" មានន័យថា បច្ចេកទេសនៃការអនុញ្ញាតអោយបញ្ជើខុសច្បាប់ រឺបញ្ជើសង្ស័យ ឆ្លងកាត់ រឺចូលទៅក្នុងទឹកដីរបស់រដ្ឋមួយ រឺរដ្ឋច្រើនទៀត ដោយអាជ្ញាធរមានសមត្ថកិច្ចដឹង ឬ ស្ថិតនៅក្រោមការគ្រប់គ្រង របស់ខ្លួនក្នុងលក្ខខណ្ឌស៊ើបអង្កេតបទល្មើសមួយ និង ការកំណត់អត្តសញ្ញាណមនុស្សដែលពាក់ពន្ធ័ក្នុងការប្រព្រឹត្តិ បទល្មើសុ ។

## មាត្រា ៣

## វិសាលភាពនៃការអនុវត្តន៍

១. ដោយអនុឡោមទៅតាមពាក្យរបស់វា អនុសញ្ញានេះត្រូវអនុវត្តចំពោះការការពារ ការស៊ើបអង្កេតនិងការ ផ្តន្ទាទោសលើអំពើពុករលួយ និងចំពោះការបង្កក ការរឹបអូស ទ្រព្យរឹបអូស និងការយកមកវិញនូវផល នៃបទល្មើសដែលបានចែងឡើងដោយយោងទៅតាមអនុសញ្ញានេះ ។

២. ចំពោះគោលបំណងនៃការអនុវត្តន៍អនុសញ្ញានេះ វានឹងមិនចាំបាច់ទេ លើកលែងតែបានចែងនៅក្នុងអនុសញ្ញា ចំពោះបទល្មើសដែលមានចែងនៅក្នុងអនុសញ្ញានេះដែលនាំអោយខូចខាត រឺអន្តរាយដល់ទ្រព្យសម្បត្តិរដ្ឋ ។

## មាត្រា ៤

## ការការពារអធិបតេយ្យភាព

១. ភាគីរដ្ឋត្រូវអនុវត្តកាតព្វកិច្ចរបស់ពួកគេក្រោមអនុសញ្ញានេះក្នុងបែបបទមួយស្របទៅតាមគោលការណ៍ សមភាព អធិបតេយ្យ និងបូរណភាពទឹកដីរបស់រដ្ឋ ហើយមិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ រដ្ឋផ្សេងទៀត ។

២. គ្មានអ្វីនៅក្នុងអនុសញ្ញានេះផ្តល់សិទ្ធិអោយភាគីរដ្ឋមួយអនុវត្តនៅក្នុងទឹកដីរបស់រដ្ឋផ្សេងទៀតនូវការ អនុវត្តន៍យុត្តាធិការនិងការបំពេញមុខងារដែលគេរៀបចំបំរុងដោយមិនរាប់បញ្ចូលចំពោះអាជ្ញាធរនៃរដ្ឋ ផ្សេងទៀតនោះតាមរយៈច្បាប់ក្នុងប្រទេសរបស់ខ្លួន ។

# ជំពូក II

## វិធានការបង្ការ

## មាត្រា ៥

## គោលនយោបាយនិងការអនុវត្តន៍ប្រឆាំងនឹងអំពើពុករលួយ

១. ដោយអនុឡោមទៅតាមគោលការជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវបង្កើតនិងអនុវត្ត រឺរក្សានូវគោលនយោបាយប្រឆាំងនឹងអំពើពុករលួយ សំរបសំរួលគោលនយោបាយប្រឆាំងអំពើពុករលួយដែលជំរុញអោយមានការចូលរួមរបស់សង្គម ហើយឆ្លុះបញ្ចាំងនូវគោលការណ៍នៃក្រិតក្រមច្បាប់ ការគ្រប់គ្រងកិច្ចការសាធារណៈនិងទ្រព្យសម្បត្តិសាធារណៈត្រឹមត្រូវ សេចក្តីថ្លៃថ្នូរ តម្លាភាព និងការទទួលខុសត្រូវ ។

២. ភាគីរដ្ឋនីមួយៗត្រូវខំខ្នះខ្នែងដើម្បីបង្កើតនិងជំរុញការអនុវត្តន៍ដែលមានប្រសិទ្ធិភាព សំដៅការទប់ស្កាត់អំពើពុករលួយ ។

៣. ភាគីរដ្ឋនីមួយៗត្រូវខំខ្នះខ្នែងដើម្បីវាយតំលៃនូវរាល់ឯកសារច្បាប់ដែលជាប់ពាក់ពន្ធ័ និងវិធានការរដ្ឋបាលជាមួយការយល់ឃើញចំពោះការកំណត់ភាពគ្រប់គ្រាន់របស់ពួកគេដើម្បីទប់ស្កាត់និងប្រយុទ្ធប្រឆាំងអំពើ-ពុករលួយ ។

៤. នៅពេលណាសមស្របហើយដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ពួកគេ ភាគីរដ្ឋទាំងអស់ត្រូវសហការជាមួយគ្នាទៅវិញទៅមក និងជាមួយអង្គការជាតិនិងអន្តរជាតិដែលជាប់ពាក់ពន្ធ័ដើម្បីជំរុញនិងអភិវឌ្ឍន៏វិធានការដែលមានចែងក្នុងមាត្រានេះ ។ ការសហការនោះអាចបញ្ចូលការចូលរួមនៅក្នុងកម្មវិធីអន្តរជាតិនិងគំរោងដែលសំដៅទៅលើការទប់ស្កាត់អំពើពុករលួយ ។

## មាត្រា ៦
## អង្គការប្រឆាំងនឹងអំពើពុករលួយ

១. ដោយអនុលោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវធានានូវអត្ថិភាពរបស់អង្គការដែលទប់ស្កាត់អំពើពុករលួយនៅពេលណាសមស្របតាមរយៈមធ្យោបាយដូចជាៈ

ក. ការអនុវត្តន៏គោលនយោបាយដោយយោងទៅតាមមាត្រា ៥នៃអនុសញ្ញានេះ ហើយនៅពេលណាសមស្របត្រួតពិនិត្យនិងសំរបសំរួលការនុវត្តន៏គោលនយោបាយទាំងនោះ ។

ខ. ការបង្កើននិងការចែកចាយចំណេះដឹងអំពីការទប់ស្កាត់អំពើពុករលួយ ។

២. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវផ្តល់អោយអង្គការ យោងទៅតាមកថាខណ្ឌ ១នៃមាត្រានេះ នូវឯករាជ្យភាពចាំបាច់ដើម្បីធ្វើអោយអង្គការនោះអាចអនុវត្តមុខងាររបស់ខ្លួន រឺរបស់ពួកគេប្រកបដោយប្រសិទ្ធិភាពនិងអាចរួចផុតពីឥទ្ធិពលដែលមិនបានគ្រោងទុក

ណាមួយ ។ គេត្រូវផ្តល់អោយនូវធនធានសំភារៈចាំបាច់និងបុគ្គលិកឯកទេសក៏ដូចជាការបណ្តុះបណ្តាល ដែលបុគ្គលិកទាំងនេះត្រូវការដើម្បីអនុវត្តមុខងាររបស់ពួកគេនោះ ។

៣. ភាគីរដ្ឋនីមួយៗត្រូវផ្តល់ពតិមានដល់អគ្គលេខាធិការអង្គការសហប្រជាជាតិនូវឈ្មោះ និងអាស័យដ្ឋានរបស់អាជ្ញាធរដែលអាចជួយដល់ភាគីរដ្ឋដទៃទៀតក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍វិធានការជាក់លាក់សំរាប់ការទប់ស្កាត់អំពើពុករលួយ ។

## មាត្រា ៧

## ផ្នែកសាធារណៈ

១. នៅពេលណាសមស្របនិងអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវខំខ្នះខ្នែងទទួលយករក្សាទុកនិងពង្រឹងប្រពន្ធ័ទាំងនេះសំរាប់ការជ្រើសរើស ការជួល ការទិញទុកជាមុន ការដំឡើងឋានៈនិងការចូលនិវត្តន៍របស់មន្ត្រីរាជការ និងនៅពេលណាសមស្រប របស់មន្ត្រីសាធារណៈដែលមិនបានទទួលការបោះឆ្នោតជ្រើសរើស :

ក. ដែលត្រូវពឹងផ្អែកលើគោលការណ៍ប្រសិទ្ធិភាព តម្លាភាព និងលក្ខណៈវិនិច្ឆ័យមិនលំអៀង និង គោលបំណងសមភាព និងសម្បទា ។

ខ. ដែលបញ្ចូលនីតិវិធីគ្រប់គ្រាន់សំរាប់ការបោះឆ្នោតជ្រើសរើស និងការបណ្តុះបណ្តាលបុគ្គលសំរាប់មុខដំណែងសាធារណៈដែលបានចាត់ទុកជាពិសេសថាងាយប្រព្រឹត្តអំពើពុករលួយ ហើយនៅពេលណាសមស្របការផ្លាស់ប្តូរបុគ្គលបែបហ្នឹងអោយកាន់មុខដំណែងផ្សេងទៀត ។

គ. ដែលជំរុញការផ្តល់រង្វាន់គ្រប់គ្រាន់និងទំហំប្រាក់ខែប្រកបដោយសមធម៌ ដោយពិចារណាលើកំរិតការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ភាគីរដ្ឋនោះ ។

ឃ. ដែលជំរុញការអប់រំនិងកម្មវិធីបណ្តុះបណ្តាលដើម្បីធ្វើអោយពួកគេអាចឆ្លើយតបទៅតាមតំរូវការសំរាប់ការបំពេញមុខងារសាធារណៈត្រឹមត្រូវ ស្មោះត្រង់និងសមរម្យ និងផ្តល់អោយពួកគេនូវការបណ្តុះបណ្តាលជំនាញឯកទេសនិងសមស្របដើម្បីលើកកំពស់ការយល់ដឹងរបស់ពួកគេពីគ្រោះថ្នាក់នៃអំពើពុករលួយដែលមានជាប់ជាមួយនឹងការបំពេញមុខងាររបស់ពួកគេ ។ កម្មវិធីបែបនេះអាចធ្វើជាសេចក្តីយោងដល់ក្រមសីលធម៌ ឬ ស្តង់ដានៃការអនុវត្តន៍នៅផ្នែកដែលអាចអនុវត្តបាន ។

២. ភាគីរដ្ឋនីមួយៗត្រូវពិចារណាផងដែរលើការទទួលទុកជារបស់ខ្លួននូវវិធានការនីតិបញ្ញត្តិនិងរដ្ឋបាលសមស្របដែលស្របទៅតាមគោលបំណងរបស់អនុសញ្ញានេះ ហើយអនុឡោមទៅតាមគោលការណ៍ច្បាប់ក្នុងប្រទេស

របស់ខ្លួនជាសារវន្តដើម្បីបញ្ញត្តិលក្ខណៈវិនិច្ឆ័យដែលជាប់ទាក់ទងនឹងបេក្ខភាពសំរាប់និងការបោះឆ្នោត ចំពោះដំណែងសាធារណៈ ។

៣. ភាគីរដ្ឋនីមួយៗក៏ត្រូវពិចារណាផងដែរលើការអនុវត្តន៍វិធានការនីតិបញ្ញត្តិនិងរដ្ឋបាលសមស្របដែលស្របទៅតាមគោលបំណងនៃអនុសញ្ញានេះ និងអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ដើម្បីលើកកំពស់តម្លាភាពនៅក្នុងការផ្តល់មូលនិធិរបស់បេក្ខភាពសំរាប់ដំណែងសាធារណៈដែលត្រូវបោះឆ្នោតជ្រើសរើស និងនៅក្នុងការផ្តល់មូលនិធិរបស់គណៈបក្សនយោបាយនៅកន្លែងណាដែលអាចអនុវត្តទៅបាន ។

៤. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន រដ្ឋនីមួយៗត្រូវខិតខំខ្នះខ្នែងដើម្បីទទួលយក រក្សាទុកនិងពង្រឹងប្រព័ន្ធដែលជំរុញអោយមានតម្លាភាព និងទប់ស្កាត់ជំលោះផលប្រយោជន៍

## មាត្រា ៨

## ក្រមសីលធម៌សំរាប់មន្ត្រីសាធារណៈ

១. ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ភាគីរដ្ឋនីមួយៗត្រូវជំរុញលើកទឹកចិត្តលើសេចក្តីថ្លៃថ្នូរ សេចក្តីស្មោះត្រង់និងការទទួលខុសត្រូវក្នុងចំណោមមន្ត្រីសាធារណៈរបស់ខ្លួន។

២. ជាពិសេសនៅក្នុងប្រព័ន្ធច្បាប់និងស្ថាប័នផ្ទាល់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវខំខ្នះខ្នែងដើម្បីអនុវត្តក្រមសីលធម៌ រឺស្តង់ដានៃការអនុវត្តន៍សំរាប់ការបំពេញមុខងារសាធារណៈត្រឹមត្រូវ ស្មោះត្រង់និងសមស្រប ។

៣. ចំពោះគោលបំណងនៃការអនុវត្តន៍ប្រការទាំងឡាយនៃមាត្រានេះ នៅពេលណាសមស្របហើយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវធ្វើការកត់សំគាល់លើគំនិតផ្តួចផ្តើមដែលជាប់ពាក់ព័ន្ធរបស់អង្គការពហុភាគី អង្គការអន្តរជាតិនិងអង្គការក្នុងស្រុក ដូចជាក្រមសីលធម៌អន្តរជាតិសំរាប់មន្ត្រីសាធារណៈដែលបានបញ្ចូលក្នុងឧបសម្ព័ន្ធនៃសេចក្តីសំរេចរបស់មហាសន្និបាតលេខ 51/59 of 12 December, 1996 ។

៤. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗក៏ត្រូវពិចារណាផងដែរលើការបង្កើតវិធានការនិងប្រព័ន្ធដើម្បីសំរួលដល់ការធ្វើរបាយការណ៍លើមន្ត្រីសាធារណៈដែលពុករលួយ ទៅអាជ្ញាធរមានសមត្ថកិច្ចសមស្រប នៅពេលពិនិត្យឃើញថាអំពើទាំងនេះកើតមានក្នុងដំណើរការអនុវត្តភារៈកិច្ចរបស់គេ ។

៥. នៅពេលណាសមស្របនិងអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗ ត្រូវខំខ្នះខ្នែងដើម្បីបង្កើតវិធានការណ៍និងប្រពន្ធ័ដែលតំរូវអោយមានមន្ត្រីសាធារណៈដើម្បីធ្វើការប្រកាស ចំពោះអាជ្ញាសមស្របអំពីសកម្មភាពខាងក្រៅរបស់ពួកគេ ការជួល ការ វិនិយោគទុន ទ្រព្យ និងអំណោយរឺគុណប្រយោជន៍ច្រើន ដែលអាចកើតមានជំលោះផលប្រយោជន៍ជាមួយនឹង មុខងាររបស់ខ្លួនជាមន្ត្រីសាធារណៈ ។

៦. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវធ្វើការពិចារណាលើការប្រកាន់យកនូវវិន័យ រឺវិធានការប្រឆាំងមន្ត្រីសាធារណៈណាដែលរំលោភក្រមសីលធម៌ រឺស្តង់ដាដែលបានបង្កើតឡើងដោយយោងទៅតាមមាត្រានេះ ។

## មាត្រា ៩
## ការទិញនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការចាំបាច់ដើម្បីបង្កើតប្រពន្ធ័នៃការផ្តល់អោយសមស្របដោយផ្អែកលើតម្លាភាព ការប្រកួតប្រជែងនិងលក្ខណៈវិនិច្ឆ័យមិនលំអៀងក្នុងការធ្វើការសំរេចចិត្តដែលមានប្រសិទ្ធិភាពដើម្បីទប់ស្កាត់អំពើពុករលួយ ។ ប្រពន្ធ័បែបនេះដែលអាចយកមកពិចារណាលើតំលៃសមស្របនៅក្នុងការអនុវត្តន៍ត្រូវលើកឡើងអំពី :

ក. ការបែងចែកជាសាធារណៈនូវពត៌មានដែលជាប់ពាក់ពន្ធ័នឹងនីតិវិធីការផ្តល់ជូននិងកិច្ចសន្យា រួមមានពត៌មានស្តីពីការសុំអញ្ជើញអោយដាក់ស្នើសុំជាផ្លូវការនិងពត៌មានចំៗរឺជាប់ពាក់ពន្ធ័ស្តីអំពីការផ្តល់ជូនកិច្ចសន្យា ដោយអនុញ្ញាតអោយអ្នកដាក់ស្នើសុំមានសក្តានុពលមានពេលគ្រប់គ្រាន់ដើម្បីរៀបចំនិងដាក់ជូនការដាក់ស្នើសុំជាផ្លូវការរបស់ខ្លួន ។

ខ. ការបង្កើតជាមុននៃលក្ខខណ្ឌសំរាប់ការចូលរួម រួមមានការជ្រើសរើសនិងលក្ខណៈវិនិច្ឆ័យនៃការសំរេចជ្រើសរើសនិងការដាក់ស្នើសុំការគ្រប់គ្រង និងការបោះពុម្ពផ្សាយរបស់ពួកគេ ។

គ. ការប្រើប្រាស់លក្ខណៈវិនិច្ឆយ័ដែលបានកំណត់ទុកជាមុននិងមិនលំអៀងសំរាប់ការសំរេចចិត្តផ្តល់អោយជាសាធារណៈដើម្បីសំរួលដល់ការពិនិត្យបញ្ជាក់ជាបន្តបន្ទាប់លើការអនុវត្តន៍ត្រឹមត្រូវនូវគោលការណ៍ រឺនីតិវិធី

ឃ. ប្រពន្ធ័នៃការពិនិត្យមើលឡើងវិញក្នុងស្រុកដែលមានប្រសិទ្ធិភាព រួមមានប្រពន្ធ័នៃការប្តឹងឧទ្ធរណ៍ដែលមានប្រសិទ្ធិភាព ដើម្បីធានានូវបណ្តឹងសើរើស្របច្បាប់និងអ្វីផ្សេងៗទៀតក្នុងព្រឹត្តិការណ៍ដែលការគ្រប់គ្រង រឺ នីតិវិធីត្រូវបានបង្កើតឡើងស្របទៅតាមកថាខណ្ឌនេះមិនត្រូវបានគេគោរពតាម ។

ង. ក្នុងករណីសមស្រប វិធានការធ្វើនិយតកម្មបញ្ហាដោយគិតពីការទទួលខុសត្រូវរបស់បុគ្គលិកសំរាប់ការផ្តល់អោយ ដូចជាការប្រកាសពីការចាប់អារម្មណ៍លើការផ្តល់អោយជាសាធារណៈ ការបង្ហាញនីតិវិធីជ្រើសរើស និងតំរូវការការបណ្តុះបណ្តាល ។

២. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវអនុវត្តវិធានការសមស្របដើម្បីជំរុញអោយមានតម្លាភាពនិងការទទួលខុសត្រូវនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ វិធានការបែបនេះត្រូវមានៈ

ក. នីតិវិធីនៃការអនុមត័ថវិកាជាតិ

ខ. ការធ្វើរបាយការណ៍អោយទាន់ពេលវេលាស្តីអំពីប្រាក់ចំណូលប្រចាំឆ្នាំនិងការចំណាយ

គ. ប្រពន្ធ័ស្តង់ដាគណៈនេយ្យនិងការធ្វើសវនកម្ម និងការត្រួតពិនិត្យផ្សេងៗដែលពាក់ពន្ធ័

ឃ. ប្រពន្ធ័នៃការគ្រប់គ្រងគ្រោះថ្នាក់និងការត្រួតពិនិត្យខាងក្នុងដែលមានប្រសិទ្ធិភាពនិងផ្តល់ផលល្អ និង

ង. ក្នុងករណីសមស្រប សកម្មភាពកែតំរូវក្នុងករណីខកខានមិនបានឆ្លើយតបទៅតាមតំរូវការដែលបានបង្កើតឡើងនៅក្នុងកថាខណ្ឌ័នេះ ។

៣. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានរដ្ឋបាលនិងស៊ីវិលបែបហ្នឹងនៅពេលណាចាំបាច់ ដើម្បីរក្សាទុកនូវសេចក្តីសុច្ចរិតនៃសៀវភៅគណៈនេយ្យ របាយការណ៍ បញ្ជីរហិរញ្ញវត្ថុ រឺឯកសារផ្សេងទៀតដែលជាប់ពាក់ពន្ធ័ទៅនឹងការចំណាយសាធារណៈ និងប្រាក់ចំណូលប្រចាំឆ្នាំ និងដើម្បីទប់ស្កាត់ការក្លែងបន្លំឯកសារទាំងអស់នេះ ។

## មាត្រា ១០
## ការធ្វើរបាយការណ៍សាធារណៈ

ធ្វើការពិចារណាលើសេចក្តីត្រូវការដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការទាំងឡាយនេះនៅពេលណាចាំបាច់ ដើម្បីលើកកំពស់តម្លាភាពនៅក្នុងរដ្ឋបាលសាធារណៈរបស់ខ្លួន រួមមាន ដោយសំដៅលើអង្គការ ការបំពេញមុខងារនិងដំណើរការធ្វើការសំរេចចិត្តរបស់ខ្លួន នៅពេលណាសមស្រប និងអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ។ វិធានការទាំងនេះអាចរួមបញ្ចូលៈ

ក. នីតិវិធី និង គោលការណ៍អនុមត័ដែលអនុញ្ញាតអោយសមាជិកសាធារណៈទូទៅទទួលយក នៅពេលណាសមស្រប នូវពត៌មានស្តីពីអង្គការ ការបំពេញមុខងារ និងដំណើរការនៃការធ្វើការសំរេចចិត្តរបស់រដ្ឋបាល

សាធារណៈរបស់ខ្លួន និង ការការពារទិន្នន័យផ្ទាល់ខ្លួន និងឯកជន លើការសំរេចចិត្តនិងវិធានច្បាប់ដែលជាប់ពាក់ពន្ធ័ទៅនឹងសមាជិកសាធារណៈ ។

ខ. ការធ្វើអោយងាយស្រួលនូវនីតិវិធីរដ្ឋបាល នៅពេលណាសមស្រប ដើម្បីជួយសំរួលដល់ការទទួលបានជាសាធារណៈនូវអាជ្ញាទំនាក់ទំនងជាមួយនឹងសមត្ថកិច្ចដែលមានសិទ្ធិសំរេច និង

គ. ការបោះពុម្ពពតិមានដែលអាចបញ្ចូលរបាយការណ៍ស្តីពីគ្រោះថ្នាក់នៃអំពើពុករលួយនៅក្នុងរដ្ឋបាល-សាធារណៈរបស់ខ្លួន។

## មាត្រា ១១

## វិធានការអំពីសេវាកម្មតុលាការនិងការកាត់ទោស

១. ចាំទុកក្នុងចិត្តនូវឯករាជ្យភាពនៃតួនាទីតុលាការនិងតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានដើម្បីពង្រឹងសេចក្តីថ្លៃថ្នូរនិងដើម្បីទប់ស្កាត់ឱកាសប្រព្រឹត្តិអំពើពុករលួយនៅក្នុងចំណោមសមាជិកតុលាការ ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួននិងដោយមិនលំអៀងចំពោះឯករាជ្យភាពតុលាការ។ វិធានការបែបហ្នឹងអាចរួមបញ្ចូលទាំងគោលការណ៍លើទង្វើរបស់សមាជិកតុលាការទាំងអស់។

២. វិធានការចំពោះប្រសិទ្ធិតែមួយដូចគ្នានឹងវិធានការដែលគេបានអនុវត្តស្របទៅតាមកថាខណ្ឌ ១នៃមាត្រានេះអាចត្រូវបានគេបញ្ចូលនិងអនុវត្តនៅក្នុងសេវាកម្មការកាត់ទោសក្នុងភាគីរដ្ឋទាំងនោះដែលវាមិនបង្កើតជាផ្នែកនៃតុលាការ ប៉ុន្តែទទួលបាននូវឯករាជ្យភាពស្រដៀងគ្នាទៅនឹងឯករាជ្យភាពនៃសេវាកម្មតុលាការ។

## មាត្រា ១២

## ផ្នែកឯកជន

១. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការដើម្បីទប់ស្កាត់អំពើពុករលួយដែលជាប់ពាក់ពន្ធ័នឹងផ្នែកឯកជន លើកកំពស់ស្តង់ដាគណៈនេយ្យនិងការធ្វើសវនកម្មនៅក្នុងផ្នែកឯកជន និងនៅពេលណាសមស្រប ផ្តល់ការពិន័យរដ្ឋប្បវេណី ពិន័យរដ្ឋបាលរឺព្រហ្មទណ្ឌដែលមានប្រសិទ្ធិភាពធ្វើអោយរាងចាលនិងសមាមាត្រទៅនឹងទោសកំហុសនោះចំពោះការខកខានមិនបានអនុវត្តតាមវិធានការបែបនោះ។

២. វិធានការដើម្បីសំរេចគោលបំណងទាំងនេះអាចរួមមានៈ

ក. ការជំរុញអោយមានការសហប្រតិបត្តិការរវាងភ្នាក់ងារអនុវត្តច្បាប់និងអង្គភាពឯកជនដែលជាប់ពាក់ពន្ធ័ទាំងអស់ ។

ខ. ការជំរុញអោយមានការអភិវឌ្ឍន៍ស្តង់ដានិងនីតិវិធីដែលបានរៀបចំឡើងដើម្បីការពារសេចក្តីថ្លៃថ្នូររបស់អង្គភាពឯកជនដែលជាប់ពាក់ពន្ធ័ រួមមានក្រមសីលធម៌ចំពោះការបំពេញសកម្មភាពជំនួញត្រឹមត្រូវ ស្មោះត្រង់និងស្អាតស្អំ និងគ្រប់វិជ្ជាជីវៈដែលជាប់ពាក់ពន្ធ័ទាំងអស់ និងការទប់ស្កាត់ជំលោះផលប្រយោជន៍ និងចំពោះការជំរុញអោយមានការប្រើប្រាស់ការប្រតិបត្តិជំនួញល្អក្នុងចំណោមមុខជំនួញទាំងឡាយនិងក្នុងការទំនាក់ទំនងជំនួញដែលបញ្ញត្តិដោយកិច្ចសន្យាជាមួយរដ្ឋនោះ ។

គ. ការជំរុញអោយមានតម្លាភាពក្នុងចំណោមអង្គភាពឯកជន នៅពេលណាសមស្របរួមមានវិធានការចំពោះអត្តសញ្ញាណរបស់រូបវន្តបុគ្គលនិងនីតិបុគ្គលដែលជាប់ពាក់ពន្ធ័នឹងការបង្កើតនិងការគ្រប់គ្រងរបស់អង្គភាពសាជីវកម្ម ។

ឃ. ការទប់ស្កាត់ការប្រើខុសនៃនីតិវិធីដែលធ្វើនិយតកម្មដល់អង្គភាពឯកជនទាំងអស់ រួមមាន នីតិវិធីចំពោះការទំនុកបំរុងដោយប្រាក់និងអាជ្ញាបណ្ណ័ដែលបានផ្តល់អោយដោយអាជ្ញាធរសាធារណៈសំរាប់សកម្មភាពជំនួញ ។

ង. ការទប់ស្កាត់ជំលោះផលប្រយោជន៍តាមរយៈការដាក់លក្ខខណ្ឌ នៅពេលណាសមស្របនិងសំរាប់រយៈពេលមួយសមហេតុផល លើសកម្មភាពវិជ្ជាជីវៈរបស់អតីតមន្ត្រីសាធារណៈ រឺលើការជួលមន្ត្រីសាធារណៈដោយផ្នែកឯកជនបន្ទាប់ពីការលាលែងរឺការចូលនិវត្តន៍របស់ពួកគេ នៅពេលដែលសកម្មភាព រឺការជួលបែបនេះមានទំនាក់ទំនងដោយផ្ទាល់នឹងមុខងារដែលកាន់កាប់ រឺដែលគ្រប់គ្រងដោយមន្ត្រីសាធារណៈទាំងនោះក្នុងអំឡុងពេលកាន់មុខដំណែងរបស់ពួកគេ ។

ច. ការធានាថា ដោយពិចារណាលើរចនាសម្ពន្ធ័និងទំហំរបស់ពួកគេ សហគ្រាសឯកជនទាំងអស់មានការត្រួតពិនិត្យសវនកម្មខាងក្នុងដើម្បីជួយក្នុងការទប់ស្កាត់និងការពារអំពើពុករលួយ ហើយថា គណនីនិងបញ្ជីរហិរញ្ញវត្ថុរបស់សហគ្រាសឯកជនបែបនោះដែលតំរូវអោយមានអាចនឹងមានការធ្វើសវនកម្មនិងមាននីតិវិធីធ្វើវិញ្ញាបនកម្មបញ្ជាក់សមស្រប ។

៣. ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួននិងបទបញ្ជាទាំងឡាយចំពោះការរក្សាទុកសៀវភៅនិងឯកសារទាំងអស់ ការបង្ហាញបញ្ជីរហិរញ្ញវត្ថុ និងស្តង់ដាគណៈនេយ្យនិងសវនកម្ម នៅពេលណាចាំបាច់ភាគីរដ្ឋទាំងអស់ត្រូវចាត់វិធានការបែបហ្នឹងដើម្បីហាមឃាត់អំពើដូចខាងក្រោមដែលបានអនុវត្តសំរាប់គោលបំណងនៃការប្រព្រឹត្តិបទល្មើសណាមួយដែលបានចែងនៅក្នុងអនុសញ្ញានេះ :

ក. ការបង្កើតគណនីក្រៅសៀវភៅបញ្ជី

ខ. ការបង្កើតសៀវភៅក្រៅ រឺ ប្រតិបត្តិការដែលបានធ្វើអត្តសញ្ញាណកម្មដោយមិនពេញលេញ

គ. ការកត់ចូលការចំណាយមិនពិត

ឃ. ការបញ្ចូលបំណុលជាមួយការធ្វើអត្តសញ្ញាណកម្មខុសពីកម្មវត្ថុរបស់វា

ង. ការប្រើប្រាស់ឯកសារក្លែងក្លាយ និង

ច. ការបំផ្លាញឯកសារដែលបានរក្សាទុកដោយចេតនាមុនការកំណត់ក្នុងច្បាប់ ។

៤. ភាគីរដ្ឋនីមួយៗមិនត្រូវអនុញ្ញាតអោយមានការកាត់បន្ថយពន្ធលើចំណាយដែលនាំអោយមានសំណូក ដែលក្រោយមកក្លាយជាសមាសភាគផ្សំនៃបទល្មើសមួយដែលមានចែងនៅក្នុងមាត្រា ១៥ និង១៦ នៃអនុសញ្ញានេះ និងនៅពេលណាសមស្រប ចំណាយផ្សេងៗទៀតដែលនាំមកនូវការជួយជ្រោមជ្រែងដល់សកម្មភាពពុករលួយ ។

## មាត្រា ១៣

### ការចូលរួមរបស់សង្គម

១. ទៅតាមមធ្យោបាយនិងអនុលោមតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការសមស្របដើម្បីជំរុញអោយមានការចូលរួមយ៉ាងសកម្មរបស់បុគ្គលនិងក្រុមខាងក្រៅផ្នែកសាធារណៈ ដូចជាសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលនិងអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៍ ក្នុងការទប់ស្កាត់ និងប្រឆាំងនឹងអំពើពុករលួយ និងដើម្បីផ្សព្វផ្សាយអោយមានការយល់ដឹងជាសាធារណៈចំពោះការកើតមានឡើង បុព្វហេតុនិងកំលាំងស្រូបទាញនៃអំពើពុករលួយ និងការគំរាមកំហែងដែលបង្កឡើងដោយអំពើពុករលួយ ។ ការចូលរួមនេះត្រូវបានពង្រឹងតាមរយៈវិធានការដូចតទៅ :

ក. ការលើកកំពស់តម្លាភាពនៃការចូលរួម និងការជំរុញអោយមានការចូលរួមរបស់សាធារណៈជនក្នុងដំណើរការធ្វើការសំរេចចិត្ត ។

ខ. ការធានាថា សាធារណៈជនទទួលបានពត៌មានដោយប្រសិទ្ធិភាព ។

គ. ការអនុវត្តន៏សកម្មភាពពត៌មានសាធារណៈដែលនាំអោយមានការមិនអាចអត់ទ្រាំនឹងការប្រព្រឹត្តអំពើពុករលួយបាន ក៏ដូចជាកម្មវិធីអប់រំសាធារណៈ រួមមានកម្មវិធីសិក្សានៅតាមសាលារៀននិងសាកលវិទ្យាល័យ

ឃ. ការគោរព ការជំរុញនិងការការពារសេរីភាពដើម្បីស្វែងរក ទទួលយក បោះពុម្ព និងចែកចាយពត៌មានដែលជាប់ពាក់ពន្ធ័នឹងអំពើពុករលួយ ។ សេរីភាពនោះអាចមានលក្ខខណ្ឌមួយចំនួន ប៉ុន្តែលក្ខខណ្ឌទាំងនេះត្រូវតែដូចអ្វីដែលបានផ្តល់អោយដោយច្បាប់ ហើយលក្ខខណ្ឌទាំងនេះគឺចាំបាច់ :

i. ចំពោះការគោរពសិទ្ធិ រឺកេរ្តិ៍ឈ្មោះរបស់អ្នកដទៃទៀត

ii. ចំពោះការការពារសន្តិសុខជាតិរឺសណ្តាប់ធ្នាប់សាធារណៈ រឺសុខភាពសាធារណៈ រឺការការពារសីលធម៌

២. ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការសមស្របដើម្បីធានាថា អង្គការប្រឆាំងអំពើពុករលួយដែលជាប់ពាក់ពន្ធ័ទាំងអស់ដូចមានចែងនៅក្នុងអនុសញ្ញានេះ ត្រូវបានគេស្គាល់ជាសាធារណៈ ហើយត្រូវអនុញ្ញាតអោយមានការចេញចូលក្នុងអង្គការទាំងនោះបាន នៅពេលណាសមស្របសំរាប់ការរាយការណ៍ ការបញ្ចូលឧប្បត្តិហេតុណាមួយដោយអនាមិកដែលគេអាចចាត់ទុកថាបង្កើតបានជាបទល្មើសដូចដែលបានចែងនៅក្នុងអនុសញ្ញានេះ

## មាត្រា ១៤

## វិធានការដើម្បីទប់ស្កាត់ការលាងលុយ

១. ភាគីរដ្ឋនីមួយៗត្រូវ :

ក. បង្កើតរបបត្រួតពិនិត្យនិងដាក់កំរិតក្នុងស្រុកទូទៅមួយសំរាប់ធនាគារនិងស្ថាប័ហិរញ្ញវត្ថុដែលមិនមែនជាធនាគារ ដោយរាប់បញ្ចូលទាំងរូបវន្តបុគ្គល រឺនីតិបុគ្គល ដែលផ្តល់សេវាកម្មជាផ្លូវការ រឺក្រៅផ្លូវការសំរាប់ការផ្ទេរលុយ រឺរបស់មានតំលៃ និងនៅពេលណាសមស្រប រាប់បញ្ចូលទាំងអង្គការដទៃៗទៀតជាពិសេសដែលអាចប្រព្រឹត្តិអំពើលាងលុយ នៅក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើអោយញញើតនិងស៊ើបរកអោយឃើញគ្រប់រូបភាពនៃការលាងលុយទាំងអស់ដែលរបបនោះត្រូវសង្កត់បញ្ជាក់នូវអ្វីៗដែលតំរូវអោយមានសំរាប់អតិថិជន និងនៅពេលណាសមស្របសំរាប់ការធ្វើអត្តសញ្ញាណកម្មម្ចាស់ដែលទទួលផលប្រយោជន៍ការរក្សាទុកឯកសារនិងការធ្វើរបាយការណ៍ពីកិច្ចការជំនួញគួរអោយសង្ស័យ ។

ខ. ដោយគ្មានបុរេនិច្ឆ័យចំពោះមាត្រា ៤៦នៃអនុសញ្ញានេះ ត្រូវធានាថា ការអនុវត្តន៍ច្បាប់ដែលដាក់កំរិតផ្នែករដ្ឋបាល និងអាជ្ញាដទៃទៀតដែលបានផ្តល់អោយដើម្បីប្រយុទ្ធប្រឆាំងនឹងការលាងលុយ (ដែលរាប់បញ្ចូលនៅពេលណាសមស្របក្រោមច្បាប់ក្នុងប្រទេសនូវអំណាចតុលាការ) មានសមត្ថភាពដើម្បីសហការនិងផ្លាស់ប្តូរពត៌មាននៅកំរិតជាតិនិងអន្តរជាតិនៅក្នុងលក្ខខណ្ឌដែលបានបញ្ញត្តិដោយច្បាប់ក្នុងប្រទេសរបស់

ខ្លួន ហើយចំពោះគោលបំណងនោះ ត្រូវពិចារណាលើការបង្កើតកងចារកម្មហិរញ្ញមួយដើម្បីធ្វើជាមជ្ឈមណ្ឌជាតិសំរាប់ប្រមូល វិភាគ និងចែកចាយពត៌មានចំពោះការលាយលុយដែលមានសក្តានុពល ។

២. ភាគីរដ្ឋទាំងអស់ត្រូវពិចារណាលើការអនុវត្តន៏វិធានការដែលអាចធ្វើទៅបានដើម្បីស៊ើបរកនិងត្រួតពិនិត្យចរន្តរបស់លុយនិងឧបករណ៏ដែលមានតំលៃគួរសមឆ្លងកាត់ព្រំដែនរបស់ពួកគេដែលអាចមានការការពារ ដើម្បីធានាបាននូវការប្រើប្រាស់ពត៌មានត្រឹមត្រូវ និងគ្មានការរារាំងតាមវិធីណាមួយដល់ការចរាចរមូលធនស្របច្បាប់ ។ វិធានការបែបនេះអាចរាប់បញ្ចូលការតំរូវមួយដែលអោយឯកត្តជន និងក្រុមហ៊ុនទាំងអស់ធ្វើការរាយការណ៏ពីផ្ទេរចំនួនសាច់ប្រាក់ច្រើនក្រាស់ក្រែលនិងឧបករណ៏មានតំលៃគួរសមឆ្លងកាត់ព្រំដែននោះ ។

៣. ភាគីរដ្ឋទាំងអស់ត្រូវពិចារណាលើការអនុវត្តន៏វិធានការដែលអាចធ្វើទៅបាន ហើយសមស្របដើម្បីតំរូវអោយស្ថាប័នហិរញ្ញវត្ថុ ដោយរាប់បញ្ចូលទាំងអ្នកបញ្ជូនប្រាក់ :

ក. បញ្ចូលលើទំរង់បែបបទសំរាប់ការផ្ទេរមូលនិធិតាមអេឡិចត្រូនិក និងសារដែលជាប់ពាក់ពន្ធ័ទៅក្នុងពត៌មានចំ១និងមានន័យគ្រប់គ្រាន់ស្ដីពីម្ចាស់ដើម ។

ខ. រក្សាទុកពត៌មានបែបនោះទូទាំងបណ្តាញការចំណាយប្រាក់ និង

គ. អនុវត្តការលើកកំពស់ការពិនិត្យពិច័យចំពោះការផ្ទេរមូលនិធិដែលមិនមានពត៌មានគ្រប់គ្រាន់ស្ដីអំពីម្ចាស់ដើម ។

៤. ក្នុងការបង្កើតរបបត្រួតពិនិត្យនិងដាក់ក៏រិតក្នុងប្រទេសមួយនៅក្រោមលក្ខខណ្ឌនៃមាត្រានេះ និងដោយគ្មានបុរេនិច្ឆ័យចំពោះមាត្រាដទៃទៀតនៃអនុសញ្ញានេះ ភាគីរដ្ឋទាំងអស់ត្រូវបានអំពាវនាវអោយប្រើប្រាស់ជាគោលការណ៏នូវគំនិតដើមដែលជាប់ពាក់ពន្ធ័របស់អង្គការជាតិ អន្តរជាតិនិងពហុភាគីប្រឆាំងនឹងការលាងលុយ ។

៥. ភាគីរដ្ឋទាំងអស់ត្រូវខិតខំខ្នះខ្នែងដើម្បីបង្កើតនិងជំរុញអោយមានកិច្ចសហប្រតិបត្តិការជាសាកល ក្នុងតំបន់អនុតំបន់ និងទ្វេរភាគីក្នុងចំណោមអំណាចតុលាការ អាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរនិយតករដើម្បីប្រយុទ្ធប្រឆាំងនឹងការលាងលុយ ។

## ជំពូក III

## ការធ្វើអោយទៅជាបទឧក្រិដ្ឋនិងការអនុវត្តច្បាប់

### មាត្រា ១៥

### ការស៊ីសំណូករបស់មន្ត្រីសាធារណៈជាតិ

ភាគីរដ្ឋនីមួយៗត្រូវទទួលទុកជារបស់ខ្លួននូវវិធានការច្បាប់និងវិធានការដទៃទៀតដែលអាចចាំបាច់ត្រូវបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តិដោយចេតនានូវ :

ក. ការសន្យា ការផ្តល់អោយ រឺការអោយដោយផ្ទាល់រឺដោយប្រយោលនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកទៅដល់មន្ត្រីសាធារណៈសំរាប់ផ្ទាល់ខ្លួនជាផ្លូវការ រឺសំរាប់ជនណាម្នាក់រឺអង្គភាពផ្សេងទៀតទៅតាមលំដាប់លំដោយការប្រព្រឹត្តិជាផ្លូវការ រឺទប់ស្កាត់កុំអោយអនុវត្តភារៈកិច្ចជាផ្លូវការរបស់ខ្លួន ។

ខ. ការរែអង្គាស រឺការទទួលយកនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកដោយផ្ទាល់ រឺប្រយោលដោយមន្ត្រីសាធារណៈសំរាប់ផ្ទាល់ខ្លួនជាផ្លូវការ រឺសំរាប់ជនណាម្នាក់ រឺអង្គភាពផ្សេងទៀតទៅតាមលំដាប់លំដោយការប្រព្រឹត្តិជាផ្លូវការ រឺទប់ស្កាត់កំអោយអនុវត្តភារៈកិច្ចជាផ្លូវការរបស់ខ្លួន ។

### មាត្រា ១៦

### ការស៊ីសំណូករបស់មន្ត្រីសាធារណៈបរទេសនិងមន្ត្រីអង្គការអន្តរជាតិសាធារណៈ

១. ភាគីរដ្ឋនីមួយៗត្រូវទទួលទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹង និងវិធានការដទៃទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តិដោយចេតនានូវការសន្យា ការផ្តល់អោយ ឬការអោយទៅមន្ត្រីសាធារណៈបរទេសណាម្នាក់ ឬ មន្ត្រីរបស់អង្គការអន្តរជាតិសាធារណៈ ដោយផ្ទាល់ឬប្រយោលនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកមួយសំរាប់ខ្លួនឯងជាផ្លូវការ ឬសំរាប់ជនណាម្នាក់ផ្សេងទៀត ឬ អង្គភាពមួយផ្សេងទៀតទៅតាមលំដាប់លំដោយការប្រព្រឹត្តិជាផ្លូវការ ឬ ទប់ស្កាត់ពីការបំពេញតួនាទីរបស់ខ្លួនជាផ្លូវការដើម្បីទទួលបានមកវិញ រឺឃាត់ឃាំងជំនួញ រឺគុណប្រយោជន៍ដែលមិនបានគ្រោងទុកផ្សេងទៀតជាប់ទាក់ទងនឹងការអនុវត្តន៍ពាណិជ្ជកម្មអន្តរជាតិ ។

២. ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹងនិងវិធានការដទៃទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាមន្ត្រីសាធារណៈបរទេស ឬ

មន្ត្រីអង្គការអន្តរជាតិសាធារណៈបានប្រព្រឹត្តិដោយចេតនានូវការរែអង្គាសប្រាក់ ឬការទទួលយកដោយផ្ទាល់ ឬដោយប្រយោលនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកមួយសំរាប់ខ្លួនឯងជាផ្លូវការ ឬ សំរាប់អ្នកដទៃទៀត ឬ សំរាប់អង្គភាពទៅតាមលំដាប់លំដោយនៃអំពើជាផ្លូវការ ឬ ទប់ស្កាត់មិនអោយមានការបំពេញតួនាទីជាផ្លូវការរបស់ខ្លួន ។

## មាត្រា ១៧

### ការលួចបន្លំ ការយកធ្វើជារបស់ខ្លួនខុសច្បាប់ ឬការបន្លែបន្លំទ្រព្យសម្បត្តិដោយមន្ត្រីសាធារណៈ

ភាគីរដ្ឋនីមួយៗត្រូវទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់នេះ និងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តិដោយចេតនាដោយមន្ត្រីសាធារណៈនូវការលួចបន្លំ ការយកធ្វើ ជារបស់ខ្លួនខុសច្បាប់ ឬ ការបន្លែបន្លំដទៃទៀតនៃទ្រព្យសម្បត្តិណាមួយ មូលនិធិសាធារណៈ ឬ ឯកជន ឬ សន្តិសុខ ឬ អ្វីមួយផ្សេងទៀតមានតំលៃដែលបានផ្តល់អោយដល់មន្ត្រីសាធារណៈដោយអាស្រ័យតួនាទីរបស់ខ្លួន សំរាប់ផលប្រយោជន៍របស់ ឬ សំរាប់ផលប្រយោជន៍អ្នកផ្សេងទៀត ឬ ផលប្រយោជន៍អង្គភាព។

## មាត្រា ១៨

### ការធ្វើជំនួញនៅក្នុងឥទ្ធិពល

ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបនេះ និងវិធាការដទៃទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តិដោយចេតនានូវៈ

ក. ការសន្យា ការផ្តល់អោយ ឬ ការអោយទៅមន្ត្រីសាធារណៈម្នាក់ ឬ ជនណាម្នាក់ផ្សេងទៀតដោយផ្ទាល់ ឬ ប្រយោលនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកទៅតាមលំដាប់លំដោយដែលមន្ត្រីសាធារណៈ ឬ ជននោះរំលោភនូវឥទ្ធិពលពិតប្រាកដ ឬ សន្មត់របស់ខ្លួនជាមួយនឹងទស្សនៈចំពោះការទទួលបានពីអាជ្ញាសាធារណៈ ឬ អាជ្ញារដ្ឋបាលរបស់ភាគីរដ្ឋនោះនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកសំរាប់អ្នកចាប់ផ្តើមសកម្មភាពមុន ឬ សំរាប់ជនណាម្នាក់ផ្សេងទៀត ។

ខ. ការរែអង្គាស ឬ ការទទួលយកនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកដោយផ្ទាល់ ឬ ប្រយោលដោយខ្លួនឯង ឬ សំរាប់ជនណាម្នាក់ផ្សេងទៀតដោយមន្ត្រីសាធារណៈ ឬ ជនណាម្នាក់ផ្សេងទៀត ទៅតាមលំដាប់

លំដោយដែលមន្ត្រីសាធារណៈ ឬ ជននោះរំលោភឥទ្ធិពលពិត ឬដែលសន្មត់របស់ខ្លួនជាមួយទស្សនៈចំពោះការទទួលបាននូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកពីអាជ្ញាធរសាធារណៈ ឬ រដ្ឋបាលនៃភាគីរដ្ឋនោះ ។

## មាត្រា ១៩

## ការរំលោភមុខងារ

ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបនេះ និង វិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាមន្ត្រីសាធារណៈដែលមិនទទួលខុសត្រូវមុខងាររបស់ខ្លួនបានប្រព្រឹត្តដោយចេតនានូវការរំលោភមុខងារឬតួនាទី ដែលនោះគឺជាការប្រព្រឹត្តិ ឬ ការខកខានមិនបានប្រព្រឹត្តិសកម្មភាពមួយដែលរំលោភច្បាប់ ក្នុងគោលបំណងទទួលបាននូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកសំរាប់ខ្លួនឯង ឬ ជនណាម្នាក់ផ្សេងទៀត ឬ សំរាប់អង្គភាពណាមួយ ។

## មាត្រា ២០

## ការបានទ្រព្យខុសច្បាប់

ដោយអនុទ្យោមទៅតាមច្បាប់រដ្ឋធម្មនុញ្ញ និង គោលការណ៍ជាសារវ័ន្តនៃប្រព័ន្ធច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការទទួលយកទុកជារបស់ខ្លួននូវវិធាការច្បាប់បែបនេះ និង វិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តដោយចេតនានូវការបានទ្រព្យសម្បត្តិខុសច្បាប់ ដែលនោះគឺជា ការកើនឡើងគួរអោយកត់សំគាល់នូវទ្រព្យសម្បត្តិរបស់មន្ត្រីសាធារណៈម្នាក់ដែលគេមិនអាចពន្យល់អោយសមហេតុផលនូវទំនាក់ទំនងប្រាក់ចំណូលស្របច្បាប់របស់ខ្លួន ។

## មាត្រា ២១

## អំពើសំណូកនៅក្នុងផ្នែកឯកជន

ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការទទួលយកនូវវិធានការច្បាប់បែបនេះ និង វិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តដោយចេតនានៅក្នុងសកម្មភាពពាណិជ្ជកម្ម សេដ្ឋកិច្ច ហិរញ្ញវត្ថុនូវៈ

ក. ការសន្យា ការផ្តល់អោយ ឬ ការអោយដោយផ្ទាល់ ឬ ប្រយោលនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុកណាមួយទៅដល់ជនណាម្នាក់ដែលដឹកនាំ ឬ ធ្វើការក្នុងឋានៈណាមួយអោយអង្គភាពឯកជនមួយ សំរាប់

ផ្ទាល់ខ្លួន ឬ សំរាប់អ្នកដទៃណាម្នាក់ទៅតាមលំដាប់លំដោយដែលជននោះប្រព្រឹត្ត ឬ ទប់ស្កាត់ពីការប្រព្រឹត្ត ដោយរំលោភភារៈកិច្ចរបស់ខ្លួន។

ខ. ការរំលោភអង្គាស ឬ ការទទួលយកដោយផ្ទាល់ ឬ ប្រយោលនូវគុណប្រយោជន៍ដែលមិនបានគ្រោងទុក ដោយជនណាម្នាក់ដែលដឹកនាំ ឬ ធ្វើការក្នុងឋានៈណាមួយអោយអង្គភាពផ្នែកឯកជនសំរាប់ខ្លួនឯង ឬ សំរាប់ជនណាម្នាក់ផ្សេងទៀតទៅតាមលំដាប់លំដោយដែលជននោះប្រព្រឹត្ត ឬទប់ស្កាត់ពីការប្រព្រឹត្ត ដោយរំលោភភារៈកិច្ចរបស់ខ្លួន។

## មាត្រា ២២

### ការលួចបន្លំទ្រព្យសម្បត្តិក្នុងផ្នែកឯកជន

ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបនេះ និងវិធានការដទៃៗទៀតដែលអាចចាំដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលបានប្រព្រឹត្តដោយចេតនានូវការលួចបន្លំនៅក្នុងសកម្មភាពពាណិជ្ជកម្ម សេដ្ឋកិច្ច រឺហិរញ្ញវត្ថុ ដោយជនណាម្នាក់ដែលនាំដឹកនាំ រឺធ្វើការក្នុងឋានៈណាមួយនៅក្នុងអង្គភាពផ្នែកឯកជននៃទ្រព្យ រឺមូលនិធិឯកជន រឺសន្តិសុខ រឺវត្ថុដទៃៗទៀតដែលមានតំលៃដែលបានប្រគល់អោយជននោះដោយអាស្រយ័នូវតួនាទីរបស់ខ្លួន។

## មាត្រា ២៣

### ការលាងផលនៃបទល្មើស

១. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹង និងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តដោយចេតនានូវ :

ក. (i) ការបន្លែបន្លំ រឺការផ្ទេរទ្រព្យសម្បត្តិ ដែលដឹងថា ទ្រព្យនោះគឺជាផលនៃបទឧក្រិដ្ឋសំរាប់គោលបំណងបិទបាំង រឺក្លែងប្រភពខុសច្បាប់របស់ទ្រព្យនោះ រឺប្រភពដើមនៃការជួយជនណាម្នាក់ដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសដើមដើម្បីបញ្ចៀសវិបាកច្បាប់នៃការប្រព្រឹត្តរបស់ខ្លួន។

(ii) ការលាក់បាំង រឺការក្លែងធម្មជាតិ ប្រភព ទីតាំង ការចែកចាយ ការរំកិល រឺកម្មសិទ្ធិពិតនៃ រឺសិទ្ធិជាមួយនឹងការគោរពចំពោះទ្រព្យសម្បត្តិ ដែលដឹងថា ទ្រព្យនោះគឺជាផលនៃបទឧក្រិដ្ឋ។

ខ. ដោយអនុឡោមទៅតាមទស្សនៈជាមូលដ្ឋាននៃប្រពន្ធ័ច្បាប់របស់ខ្លួនៈ

(i) ការបានមក កាន់កាប់ រឺការប្រើប្រាស់ទ្រព្យសម្បត្តិ ដែលដឹងនៅពេលទទួលថា ទ្រព្យសម្បត្តិនោះគឺជាផលនៃបទឧក្រិដ្ឋ ។

(ii) ការចូលរួម ការសេពគព រឺការសមគំនិតដើម្បីប្រព្រឹត្តិ ការប៉ុនប៉ងប្រព្រឹត្តិនិងការជួញជាជំនួញ ការជុំញការជួយសំរួលនិងការប្រឹក្សាពិគ្រោះយោបល់ ការប្រព្រឹត្តិបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមមាត្រានេះ ។

២. សំរាប់គោលបំណងនៃការអនុវត្តន៍ រឺការប្រើប្រាស់កថាខណ្ឌ ១នៃមាត្រានេះ :

ក. ភាគីរដ្ឋនីមួយៗត្រូវស្វះស្វែងដើម្បីអនុវត្តកថាខណ្ឌ ១នៃមាត្រានេះចំពោះវង្វង់បទល្មើសដើមធំទូលាយបំផុត ។

ខ. ភាគីរដ្ឋនីមួយៗត្រូវបញ្ចូល ដូចជាបទល្មើសដើមនៅត្រឹមអប្បរមានូវវង្វង់ទូទៅមួយនៃបទល្មើសព្រហ្មទណ្ឌដូចដែលបានចែង ដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

គ. សំរាប់គោលបំណងនៃអនុកថាខណ្ឌ (ខ) ខាងលើ បទល្មើសដើមត្រូវបញ្ចូលបទល្មើសដែលបានប្រព្រឹត្តិទាំងពីរ នៅខាងក្នុងនិងនៅខាងក្រៅយុត្តាធិការនៃភាគីរដ្ឋដែលកំពុងមានបញ្ហា ។ ទោះបីជាយ៉ាងណាក៏ដោយបទល្មើសដែលបានប្រព្រឹត្តិខាងក្រៅយុត្តាធិការនៃភាគីរដ្ឋមួយត្រូវតាំងជាបទល្មើសដើមតែមួយគត់នៅពេលណា កិរិយាបទជាប់ពាក់ពន្ធ័គឺជាបទល្មើសព្រហ្មទណ្ឌនៅក្រោមច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋនោះដែលជាកន្លែងបទល្មើសត្រូវបានគេប្រព្រឹត្តិ ហើយវាជាបទល្មើសព្រហ្មទណ្ឌនៅក្រោមច្បាប់ក្នុងស្រុករបស់ភាគីរដ្ឋនោះដែលអនុវត្ត រឺប្រើប្រាស់មាត្រានេះ ប្រសិនបើបទល្មើសកើតមានឡើងនៅទីនោះ ។

ឃ. ភាគីរដ្ឋនីមួយៗត្រូវផ្តល់ឯកសារថតចំលងនៃច្បាប់របស់ខ្លួនដែលផ្តល់ឥទ្ធិពលដល់មាត្រានេះ និងឯកសារថតចំលងនៃការផ្លាស់ប្តូរបន្តបន្ទាប់ចំពោះច្បាប់បែបនេះ រឺ សេចក្តីពន្យល់របស់ច្បាប់នោះទៅអោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ង. ប្រសិនបើតំរូវដោយគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋមួយ វាអាចអាចត្រូវបានគេផ្តល់អោយថា បទល្មើសទាំងឡាយដែលបានចែងនៅក្នុងកថាខណ្ឌ ១នៃមាត្រានេះមិនអនុវត្តចំពោះបុគ្គលណាដែលបានប្រព្រឹត្តិបទល្មើសដើមទេ ។

## មាត្រា ២៤

### ការបិទបាំង

ដោយគ្មានបុរេនិច្ឆ័យចំពោះប្រការទាំងឡាយនៃមាត្រា ២៣នៃអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបនេះនិងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តិដោយចេតនានូវការបិទបាំង ការឃាត់ទុកទ្រព្យសម្បត្តិបន្តនៅពេលជនជាប់ពាក់ពន្ធ័នោះដឹងថា ទ្រព្យសម្បត្តិនោះគឺជាលទ្ធផលបានមកពីបទល្មើសណាមួយដូចដែលបានចែងនៅក្នុងអនុសញ្ញានេះបន្ទាប់ពីការប្រព្រឹត្តិបទល្មើសណាមួយដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះដោយមិនបានចូលរួមនៅក្នុងបទល្មើសបែបនេះ ។

## មាត្រា ២៥

### ការរារាំងយុត្តិធម៌

ភាគីរដ្ឋនីមួយៗត្រូវទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់និងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងជាបទល្មើសព្រហ្មទណ្ឌ នៅពេលណាបានប្រព្រឹត្តិដោយចេតនានូវ :

ក. ការប្រើប្រាស់កំលាំងកាយ ការគំរាមកំហែង រឺការបំភ័យ រឺការសន្យា ការផ្តល់អោយរឺការអោយនូវគុណប្រយោជន៍មិនបានគ្រោងទុកមួយ ដើម្បីអន្ទងសក្ខីភាពមិនពិត រឺដើម្បីជ្រៀតជ្រែកក្នុងការផ្តល់អោយសក្ខីភាព រឺផលិតកម្មភស្តុតាងនៅក្នុងដំណើរការដែលជាប់ទាក់ទងនឹងការប្រព្រឹត្តិបទល្មើសដូចដែលបានចែង ដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

ខ. ការប្រើប្រាស់កំលាំងកាយ ការគំរាមកំហែង រឺការបំភ័យដើម្បីជ្រៀតជ្រែកជាមួយការអនុវត្តន៏ភារៈកិច្ចជាផ្លូវការដោយមន្ត្រីអនុវត្តច្បាប់ រឺមន្ត្រីយុត្តិធម៌ដែលពាក់ពន្ធ័នឹងការប្រព្រឹត្តិបទល្មើសដូចបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។ គ្មានអ្វីនៅក្នុងអនុកថាខណ្ឌ័នេះត្រូវធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់ភាគីរដ្ឋដើម្បីទទួលបានច្បាប់ដែលការពារដល់ប្រភេទមន្ត្រីសាធារណៈផ្សេងទៀត ។

## មាត្រា ២៦

### សំណង និង ការទទួលខុសត្រូវរបស់នីតិបុគ្គល

១. ស្របទៅតាមគោលច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវទទួលយកទុកជារបស់ខ្លួននូវវិធានការបែបហ្នឹងនិងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតឡើងនូវបំណុលរបស់នីតិបុគ្គលចំពោះការចូលរួមនៅក្នុងបទល្មើស ដូចបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

២. ដោយអនុឡោមតាមគោលការណ៍ច្បាប់របស់ភាគីរដ្ឋនោះ បំណុលរបស់នីតិបុគ្គលអាចជាបទល្មើសរដ្ឋបាល បទល្មើសរដ្ឋប្បវេណី រឺជាបទល្មើសព្រហ្មទណ្ឌ ។

៣. បំណុលបែបនេះត្រូវគ្មានបុរេនិច្ឆ័យចំពោះបំណុលព្រហ្មទណ្ឌនៃរូបវន្តបុគ្គលដែលបានប្រព្រឹត្តិបទល្មើស ។

៤. ភាគីរដ្ឋនីមួយៗត្រូវធានាជាពិសេសថា នីតិបុគ្គលដែលទទួលខុសត្រូវ ដោយអនុឡោមទៅតាមមាត្រានេះ អាចនឹងទទួលការដាក់ទណ្ឌកម្មមិនមែនព្រហ្មទណ្ឌ រឺព្រហ្មទណ្ឌសមស្រប និងដែលធ្វើអោយរាងចាលប្រកបដោយប្រសិទ្ធិភាព រួមមានទណ្ឌកម្មរូបិយវត្ថុ ។

## មាត្រា ២៧

### ការចូលរួមនិងការប៉ុនប៉ង

១. ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹងនិងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនូវការចូលរួមនៅក្នុងឋានៈណាមួយ ដូចជាអ្នកសមគំនិត អ្នកជំនួញការ រឺអ្នកមេគំនិតនៅក្នុងបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

២. ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗអាចទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹងនិងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនូវការប៉ុនប៉ងណាមួយដើម្បីប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

៣. ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗអាចទទួលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹងនិងវិធានការដទៃៗទៀតដែលអាចចាំបាច់ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌនូវការរៀបចំសំរាប់បទល្មើសមួយដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

## មាត្រា ២៨

## ការដឹង ចេតនានិងគោលបំណងជាធាតុផ្សំនៃបទល្មើស

ការដឹង ចេតនា រឺគោលបំណងដែលតំរូវជាធាតុផ្សំនៃបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះអាចទាញចេញពីកាលៈទេសៈពិតមិនលំអៀង ។

## មាត្រា ២៩

## អាជ្ញាយុកាល

ភាគីរដ្ឋនីមួយៗនៅពេលណាសមស្របត្រូវបង្កើតនៅក្រោមច្បាប់ក្នុងប្រទេសរបស់ខ្លួននូវអាជ្ញាយុកាលវែងមួយដែលនៅក្នុងនោះត្រូវផ្តើមបណ្តឹងចំពោះបទល្មើសណាមួយដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ហើយបង្កើតអាជ្ញាយុកាលវែងមួយ រឺផ្តល់អោយសំរាប់ការផ្អាកជាបណ្តោះអាសន្ននូវអាជ្ញាយុកាលដែលជនល្មើសតាមការចោទប្រកាន់បានរត់គេចពីរដ្ឋបាលតុលាការ ។

## មាត្រា ៣០

## ការកាត់ទោស ការវិនិច្ឆ័យទោសនិងការដាក់ទណ្ឌកម្ម

១. ភាគីរដ្ឋនីមួយៗត្រូវកំណត់ថាការប្រព្រឹត្តិបទល្មើសដូចដែលបានចែងក្នុងអនុសញ្ញានេះនឹងត្រូវទទួលទណ្ឌកម្ម ទៅតាមទំងន់នៃបទល្មើសនោះ ។

២. ដោយអនុឡោមទៅតាមប្រពន្ធ័ច្បាប់របស់ខ្លួន និងគោលការណ៏រដ្ឋធម្មនុញ្ញ ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការបែបហ្នឹងដែលអាចចាំបាច់ដើម្បីបង្កើត រឺរក្សាទុកនូវតុល្យភាពសមស្របរវាងអភ័យឯកសិទ្ធីណាមួយ រឺបុព្វសិទ្ធិនៃយុត្តាធិការដែលបានព្រមព្រៀងគ្នាចំពោះមន្ត្រីសាធារណៈរបស់ខ្លួនសំរាប់ការបំពេញមុខងាររបស់ពួកគេ និងលទ្ធភាពទាំងឡាយនៃការស៊ើបអង្កេត ការកាត់ទោស និងការវិនិច្ឆ័យទោសបទល្មើសប្រកបដោយប្រសិទ្ធភាព ដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ នៅពេលណាចាំបាច់ ។

៣. ភាគីរដ្ឋនីមួយៗត្រូវខំខ្នះខ្នែងដើម្បីធានាថា អំណាចច្បាប់ដែលប្រុងប្រយត្ន័ណាមួយនៅក្រោមច្បាប់ក្នុងប្រទេសរបស់ខ្លួនដែលជាប់ទាក់ទងទៅនឹងការកាត់ទោសមនុស្សសំរាប់បទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញា ត្រូវបានគេអនុវត្តដើម្បីបង្កើនអោយដល់អតិបរិមានូវប្រសិទ្ធិភាពនៃវិធានការអនុវត្តន៏ច្បាប់ ដោយអនុឡោមទៅតាមបទល្មើសទាំងនេះ ហើយចំពោះសេចក្តីត្រូវការដើម្បីធ្វើអោយញញើតនូវការប្រព្រឹត្តិបទល្មើសបែបនេះ ។

៤. នៅក្នុងករណីនៃបទល្មើសដូចដែលបានចែងនៅក្នុងអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការសមស្របដើម្បីខំប្រឹងប្រែងធានាថា លក្ខខណ្ឌដែលបានរំលោភជាប់ទាក់ទងទៅនឹងការសំរេចចិត្តលើការលើកលែង ការផ្អាកការកាត់ទោស រឺការប្តឹងឧទ្ធរណ៍ ត្រូវគិតគូរពិចារណានូវសេចក្តីត្រូវការដើម្បីធានាវត្តមានចុងចោទនៅពេលសាវនាការព្រហ្មទណ្ឌបន្តបន្ទាប់ ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន និងចំពោះសិទ្ធិការពារ ។

៥. ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើទំងន់នៃបទល្មើសដែលជាប់ពាក់ពន្ធ័ នៅពេលធ្វើការពិចារណាលើយថាភាពនៃការដោះលែងមនុស្សមុន រឺការដោះលែងមនុស្សដោយមានលក្ខខណ្ឌកំណត់មុន ដែលត្រូវបានគេកាត់អោយជាប់ទោសពីបទល្មើសបែបហ្នឹង ។

៦. ភាគីរដ្ឋនីមួយៗដោយអនុឡោមទៅតាមគោលការណ៏ជាសារវន្ត័នៃប្រពន្ធ័ច្បាប់របស់ខ្លួន ត្រូវពិចារណាលើការបង្កើតនីតិវិធីដែលតាមនីតិវិធីនេះគេអាចចោទប្រកាន់មន្ត្រីសាធារណៈពីបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ នៅពេលណាសមស្របអាចត្រូវបានគេដកហូត ពន្យារឺចាត់តាំងឡើងវិញដោយអាជ្ញាធរសមស្រប ដែលចាំទុកក្នុងចិត្តនូវការគោរពចំពោះគោលការណ៏សន្មត់ជាមុនថាគ្មានទោស ។

៧. ដោយអនុឡោមទៅតាមគោលការណ៏ជាសារវន្តនៃប្រពន្ធ័ច្បាប់របស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការបង្កើតវិធានការសំរាប់ការដកសិទ្ធិរបស់ជនដែលត្រូវបានគេកាត់អោយជាប់ទោសពីបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះតាមរយៈដីកាតុលាការ រឺមធ្យោបាយសមស្របដទៃទៀតណាមួយសំរាប់រយៈពេលមួយដែលបានកំណត់ដោយច្បាប់ក្នុងប្រទេសរបស់ខ្លួន នៅពេលណាគេចេញដីកាអោយចាប់ខ្លួនតាមរយៈស្ថានទំងន់នៃបទល្មើស ពីៈ

ក. ការកាន់មុខតំណែងសាធារណៈ និង

ខ. ការកាន់មុខតំណែងនៅក្នុងសហគ្រាសមួយដែលបានគ្រប់គ្រងដោយផ្នែក រឺទាំងមូលដោយរដ្ឋ ។

៨. កថាខណ្ឌ ១ នៃមាត្រានេះត្រូវគ្មានបុរេនិច្ឆ័យចំពោះការអនុវត្តនីអំណាចវិន័យដោយអាជ្ញាធរមានសមត្ថកិច្ចប្រឆាំងនឹងមន្ត្រីស៊ីវិល ។

៩. គ្មានអ្វីដែលមាននៅក្នុងអនុសញ្ញានេះត្រូវជះឥទ្ធិពលដល់គោលការណ៍ដែលថា សេចក្តីពិពណ៌នាពីបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ និងការការពារស្របច្បាប់ដែលអាចអនុវត្តបាន រឺ គោលការណ៍ច្បាប់ផ្សេងទៀតដែលត្រួតពិនិត្យភាពត្រឹមត្រូវតាមច្បាប់នៃការអនុវត្តន៍ត្រូវបានគេរក្សាទុកចំពោះច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋមួយ ហើយដែលថា បទល្មើសបែបហ្នឹងត្រូវបានគេយកមកកាត់ទោសនិងផ្តន្ទាទោសដោយអនុលោមទៅតាមច្បាប់នោះ ។

១០. ភាគីរដ្ឋទាំងអស់ត្រូវខិតខំខ្នះខ្នែងដើម្បីជំរុញការចូលសមាហរណកម្មឡើងវិញទៅក្នុងសង្គមរបស់ជនដែលត្រូវបានកាត់អោយជាប់ទោសពីបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

## មាត្រា ៣១

## ការបង្កក ការចាប់យកនិងការរឹបអូស

១. ដោយគោរពទៅតាមវិសាលភាពដ៏អស្ចារ្យដែលអាចធ្វើទៅបានស្ថិតនៅក្នុងប្រពន្ធ័ច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការបែបហ្នឹងនៅពេលណាអាចចាំបាច់ដើម្បីធ្វើអោយអាចប្រព្រឹត្តិទៅនូវការរឹបអូសៈ

ក. ផលបទឧក្រិដ្ឋដែលមានដើមកំណើតមកពីបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ រឺទ្រព្យសម្បត្តិដែលតំលៃរបស់វាឆ្លើយតបទៅនឹងផលបែបនោះ ។

ខ. ទ្រព្យសម្បត្តិ សំភារៈ រឺឧបករណ៍ផ្សេងៗទៀតដែលបានប្រើប្រាស់ រឺកំណត់សំរាប់ការប្រើប្រាស់នៅក្នុងបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

២. ភាគីរដ្ឋនីមួយៗត្រូវអនុវត្តវិធានការណ៍នៅពេលណាអាចចាំបាច់ដើម្បីជួយអោយអាចធ្វើអត្តសញ្ញាណកម្មលើការតាមដាន ការបង្កក ការរឹបអូសរបស់របរណាមួយដោយយោងទៅតាមកថាខណ្ឌ ១នៃមាត្រានេះសំរាប់គោលបំណងនៃការរឹបអូសជាយថាហេតុ ។

៣. ដោយអនុលោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវទទួលយកទុកជារបស់ខ្លួននូវវិធានការបែបនេះនិងវិធានការដទៃៗទៀតនៅពេលណាអាចចាំបាច់ដើម្បីធ្វើយិតកម្មការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានបង្កក រឹបដកហូត រឹបអូស ដូចដែលបានចែងនៅក្នុងកថាខណ្ឌ ១និង២នៃមាត្រានេះ ។

៤. ប្រសិនបើផលនៃបទឧក្រិដ្ឋបែបនោះត្រូវបានគេធ្វើអោយទៅជា រឺផ្លាស់ទៅជាទ្រព្យផ្សេងមួយទៀតដោយផ្នែក រឺទាំងស្រុង ទ្រព្យបែបនោះត្រូវអាចមានការរឹបអូសដោយយោងទៅតាមមាត្រានេះជំនួសផលនោះ ។

៥. ប្រសិនបើផលនៃបទឧក្រិដ្ឋបែបនោះត្រូវបានគេច្របូកចូលជាមួយនឹងទ្រព្យដែលបានមកពីប្រភពត្រឹមត្រូវតាមច្បាប់ ទ្រព្យសម្បត្តិបែបនោះត្រូវអាចមានការរឹបអូសឡើងតាមតំលៃប៉ាន់ស្មាននៅក្នុងផលដែលបានច្របូកចូលគ្នានោះដោយគ្មានបុរេនិច្ឆ័យចំពោះអំណាចណាមួយដែលជាប់ទាក់ទងនឹងការបង្កក រឺការរឹបអូស ។

៦. ប្រាក់ចំណូល រឺផលប្រយោជន៍ផ្សេងទៀតដែលមានប្រភពមកពីផលនៃបទឧក្រិដ្ឋ ពីទ្រព្យសម្បត្តិដែលផលនៃបទឧក្រិដ្ឋបែបហ្នឹងត្រូវបានគេប្រែក្លាយរឺផ្លាស់ប្តូរទៅជា រឺពីទ្រព្យសម្បត្តិនោះជាមួយនឹងផលនៃបទឧក្រិដ្ឋបែបហ្នឹងដែលត្រូវបានគេច្របូកចូលគ្នា ត្រូវតែអាចមានវិធានការផងដែរដោយយោងទៅតាមមាត្រានេះ ទៅតាមបែបបទដូចគ្នា និងចំពោះវិសាលភាពដូចគ្នានឹងផលនៃបទឧក្រិដ្ឋ ។

៧. សំរាប់គោលបំណងនៃមាត្រានេះនិងមាត្រា ៥៥ នៃអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗត្រូវផ្តល់អំណាចដល់តុលាការ រឺអាជ្ញាធរមានសមត្ថកិច្ចដទៃៗទៀតរបស់ខ្លួនដើម្បីចេញបញ្ជាអោយធនាគារធ្វើរបាយការណ៍ហិរញ្ញវត្ថុ រឺរបាយការណ៍ពាណិជ្ជកម្មដែលអាចរកបាន រឺដែលអាចរឹបអូសបាន ។ ភាគីរដ្ឋមិនត្រូវបដិសេធមិនព្រមធ្វើការក្រោម ខដែលបានចែងនៅក្នុងកថាខណ្ឌនេះស្តីអំពីមូលដ្ឋាននៃការសំងាត់របស់ធនាគារឡើយ ។

៨. ភាគីរដ្ឋទាំងអស់អាចពិចារណាលើលទ្ធភាពនៃការតំរូវអោយជនល្មើសបង្ហាញពីប្រភពត្រឹមត្រូវតាមច្បាប់របស់ផលនៃបទល្មើសដែលបានចោទប្រកាន់ រឺរបស់ទ្រព្យសម្បត្តិដទៃទៀតដែលអាចមានការរឹបអូសទៅតាមវិសាលភាពដែលសេចក្តីតំរូវការបែបហ្នឹងស្របទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ពួកគេ និងទៅតាមធម្មជាតិនៃនីតិវិធីតុលាការ និងនីតិវិធីដទៃៗទៀត ។

៩. ខដែលបានចែងនៃមាត្រានេះមិនត្រូវបានគេបកស្រាយដូចនោះដើម្បីធ្វើអោយមានសេចក្តីលំអៀងដល់សិទ្ធិតតីជនឡើយ ។

១០. គ្មានអ្វីដែលមាននៅក្នុងមាត្រានេះត្រូវជះឥទ្ធិពលដល់គោលការណ៍ដែលថាវិធានការដែលវាយោងដល់នោះ ត្រូវបានគេកំណត់ និងអនុវត្តដោយអនុឡោមទៅតាម ហើយធ្វើទៅតាមខដែលបានចែងនៃច្បាប់ក្នុងប្រទេស របស់ភាគីរដ្ឋមួយ ។

## មាត្រា ៣២

## ការការពារសាក្សី អ្នកជំនាញការនិងជនរងគ្រោះ

១. ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការសមស្របដោយអនុឡោមទៅតាមប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួននិងទៅតាមមធ្យោបាយរបស់ខ្លួនដើម្បីផ្តល់ការការពារដែលមានប្រសិទ្ធិភាពសំរាប់សាក្សីនិងអ្នកជំនាញការដែលផ្តល់សក្ខីភាពជាប់ទាក់ទងនឹងបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ និងនៅពេលណាសមស្របសំរាប់សាច់ញាតិរបស់ពួកគេនិងជនដទៃៗទៀតដែលជិតស្និទ្ធនឹងពួកគេពីការសងសឹក រឺការគំរាមកំហែងដែលមានសក្តានុពល ។

២. វិធានការដែលបានគ្រោងទុកជាមុននៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ដោយគ្មានបុរេនិច្ឆ័យចំពោះសិទ្ធិរបស់ចុងចោទអាចរួមមាន ដោយរាប់បញ្ចូលសិទ្ធិចំពោះដំណើរការរឿងដោយផ្លូវតុលាការ :

ក. ការបង្កើតនីតិវិធីសំរាប់ការការពាររាងកាយដល់ជនទាំងនោះសំរាប់វិសាលភាពដែលចាំបាច់និងដែលអាចផ្លាស់ប្តូរ ដូចជា ការប្តូរទីកន្លែងអោយពួកគេ និងការអនុញ្ញាតអោយមានការបិទបាំង រឺការកំរិតលើការផ្សព្វផ្សាយពត៌មានដែលជាប់ទាក់ទងនឹងអត្តសញ្ញាណ និងទីកន្លែងដែលជនទាំងនោះរស់នៅ នៅពេលណាសមស្រប ។

ខ. ការផ្តល់ក្បួនច្បាប់ភស្តុតាងដើម្បីអនុញ្ញាតអោយសាក្សីនិងអ្នកជំនាញការផ្តល់ភស្តុតាងអោយទៅតាមបែបបទដែលធានាដល់សុវត្ថិភាពរបស់ជនទាំងនោះ . ដូចជាការអនុញ្ញាតអោយគេផ្តល់ភស្តុតាងតាមរយៈការប្រើប្រាស់បច្ចេកវិជ្ជាទំនាក់ទំនង ដូចជា វីដេអូ រឺមធ្យោបាយគ្រប់គ្រាន់ដទៃទៀត ។

៣. ភាគីរដ្ឋទាំងអស់ត្រូវពិចារណាលើការចូលទៅក្នុងកិច្ចសន្យា រឺការរៀបចំជាមួយនឹងរដ្ឋដទៃៗទៀតសំរាប់ការផ្លាស់ទីកន្លែងរស់នៅរបស់ជនទាំងឡាយដោយយោងទៅតាមកថាខណ្ឌ ១នៃមាត្រានេះ ។

៤. ខដែលបានចែងនៃមាត្រានេះត្រូវអនុវត្តផងដែរចំពោះជនរងគ្រោះត្រឹមតែពួកគេជាសាក្សី ។

៥. ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវជួយអោយទស្សនៈនិងការព្រួយបារម្ភរបស់ជនរងគ្រោះអាចត្រូវបានបង្ហាញនិងពិចារណានៅដំណាក់កាលសមស្របនៃដំណើរការព្រហ្មទណ្ឌប្រឆាំងនឹងជនល្មើសនៅក្នុងបែបបទមួយដែលមិនមានបុរេនិច្ឆ័យចំពោះសិទ្ធិការពារ ។

## មាត្រា ៣៣

## ការការពាររបស់អ្នករាយការណ៍

ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើបញ្ចូលទៅក្នុងប្រពន្ធ័ច្បាប់ក្នុងប្រទេសរបស់ខ្លួននូវវិធានការសមស្របដើម្បីផ្តល់ការការពារប្រឆាំងនឹងការប្រព្រឹត្តិមិនយុត្តិធមិចំពោះជនណាដែលរាយការណ៍ដោយសុច្ចចិត្ត ហើយសំអាងលើមូលដ្ឋានសមហេតុផលទៅអោយអាជ្ញាធរមានសមត្ថកិច្ចនូវការពិតណាមួយដែលជាប់ទាក់ទងនឹងបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

## មាត្រា ៣៤

## ផលវិបាកនៃអំពើពុករលួយ

ជាមួយនឹងការគិតគូរដល់សិទ្ធិរបស់តតីភាគីដែលបានមកដោយសុច្ចចិត្ត ភាគីរដ្ឋនីមួយៗដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ត្រូវចាត់វិធានការដើម្បីនិយាយពីវិបាកនៃអំពើពុករលួយ ។ នៅក្នុងបរិបទនេះ ភាគីរដ្ឋទាំងអស់អាចចាត់ទុកអំពើពុករលួយជាកត្តាដែលជាប់ពាក់ពន្ធ័មួយនៅក្នុងដំណើរការច្បាប់ដើម្បីទុកជានិរាករ រឺទុកជាមោឃៈនូវកិច្ចសន្យា ដកហូតសម្បទាន រឺឧបករណ៍ស្រដៀងគ្នាដទៃៗទៀត រឺដើម្បីចាត់វិធានការឧបាស្រ័យដទៃទៀត ។

## មាត្រា ៣៥

## សំណងការខូចខាត

ភាគីរដ្ឋនីមួយៗដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ត្រូវចាត់វិធានការបែបហ្នឹងនៅពេលណាអាចចាំបាច់ដើម្បីធានាថា អង្គភាព រឺបុគ្គលដែលបានទទួលរងនូវការខូចខាតដែលជាលទ្ធផលនៃអំពើពុករលួយទាំងអស់មានសិទ្ធិផ្តើមបណ្តឹងតាមច្បាប់ប្រឆាំងនឹងជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការខូចខាតដើម្បីទទួលសំណង ។

## មាត្រា ៣៦
## អាជ្ញាធរឯកទេស

ភាគីរដ្ឋនីមួយៗដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រព័ន្ធច្បាប់របស់ខ្លួន ត្រូវធានាដល់វត្តមានរបស់អង្គការមួយ រឺច្រើន រឺជនទាំងឡាយដែលឯកទេសខាងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមរយៈការអនុវត្តន៍ច្បាប់។ អង្គការ រឺមនុស្សបែបហ្នឹងត្រូវបានគេផ្តល់អោយនូវឯករាជ្យភាពចាំបាច់ ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃប្រព័ន្ធច្បាប់របស់ភាគីរដ្ឋនោះ ដើម្បីអោយគេអាចអនុវត្តមុខងាររបស់ពួកគេប្រកបដោយប្រសិទ្ធិភាព ហើយដោយគ្មានរងឥទ្ធិពលដែលមិនបានគ្រោងទុកណាមួយឡើយ។ ជនបែបនោះ រឺបុគ្គលិករបស់អង្គការបែបហ្នឹងត្រូវមានធនធាននិងការបណ្តុះបណ្តាលសមស្របដើម្បីអនុវត្តភារកិច្ចរបស់ពួកគេ។

## មាត្រា ៣៧
## កិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរអនុវត្តច្បាប់

១. ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការសមស្របដើម្បីលើកទឹកចិត្តដល់ជនដែលចូលរួម រឺជនដែលបានចូលរួមនៅក្នុងការប្រព្រឹត្តិបទល្មើសដូចដែលបានចែងឡើងដោយអនុឡោមអនុសញ្ញានេះ ដើម្បីផ្តល់ពត៌មានដែលមានសារៈប្រយោជន៍ចំពោះអាជ្ញាធរមានសមត្ថកិច្ចសំរាប់គោលបំណងស៊ើបអង្កេតនិងភស្តុតាង ហើយដើម្បីផ្តល់ជំនួយពិសេសពិតៗទៅអោយអាជ្ញាធរមានសមត្ថកិច្ចដែលអាចរួមចំណែកចំពោះការអូសទាញជនល្មើសអោយចេញពីផលនៃបទល្មើស និងចំពោះការរឹបយកមកវិញនូវផលបែបហ្នឹង។

២. ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការផ្តល់អោយលទ្ធភាពនៃការបន្ធូរការផ្តន្ទាទោសដល់ជនដែលជាប់ចោទដែលផ្តល់ការសហការត្រឹមត្រូវក្នុងការស៊ើបអង្កេត រឺការកាត់ទោសបទល្មើសដែលបានបង្កើតឡើង ដោយអនុឡោមទៅតាមអនុសញ្ញានេះ ក្នុងករណីសមស្រប។

៣. ដោយអនុឡោមទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការផ្តល់អោយលទ្ធភាពនៃការផ្តល់អភ័យឯកសិទ្ធិពីការកាត់ទោសដល់ជនណាម្នាក់ដែលផ្តល់ការសហការត្រឹមត្រូវក្នុងការស៊ើបអង្កេត រឺការកាត់ទោសបទល្មើសដែលបានបង្កើតឡើង ដោយអនុឡោមទៅតាមអនុសញ្ញានេះ។

៤. ការការពារដល់ជនទាំងនេះត្រូវធ្វើឡើងតាមគោលការណ៍ដូចដែលបានចែងនៅក្នុងមាត្រា ៣២ នៃអនុសញ្ញានេះ ។

៥. នៅពេលណាជនណាម្នាក់ដោយយោងទៅកថាខណ្ឌ ១នៃមាត្រានេះដែលត្រូវគេរកឃើញក្នុងភាគីរដ្ឋមួយនោះ អាចផ្តល់ការសហការត្រឹមត្រូវដល់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីរដ្ឋមួយទៀត ភាគីរដ្ឋដែលជាប់ពាក់ពន្ធ័ទាំងអស់អាចពិចារណាលើចូលក្នុងកិច្ចព្រមព្រៀង រឺការរៀបចំដែលជាប់ពាក់ពន្ធ័នឹងខដែលបានចែងមានសក្តានុពលដោយភាគីរដ្ឋផ្សេងទៀតនៃការប្រព្រឹត្តិដូចដែលបានចែងនៅក្នុងកថាខណ្ឌ ២និង៣ នៃមាត្រានេះ ។

## មាត្រា ៣៨

## កិច្ចសហការរវាងអាជ្ញាធរជាតិ

ដោយអនុលោមទៅច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានបែបហ្នឹងនៅពេលណាអាចចាំបាច់ដើម្បីលើកទឹកចិត្តដល់ការសហការម្យ៉ាងរវាងអាជ្ញាធរសាធារណៈ ក៏ដូចជាមន្ត្រីសាធារណៈរបស់ខ្លួន និងម្យ៉ាងទៀតអាជ្ញាធរទទួលខុសត្រូវចំពោះការស៊ើបអង្កេតនិងការយកបទល្មើសឧក្រិដ្ឋមកកាត់ទោស ។ ការសហការបែបហ្នឹងអាចរួមមាន :

ក. ការផ្តល់ពតិមានដល់អាជ្ញាធរក្រោយគេ ដោយផ្អែកលើគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួនដែលមានមូលដ្ឋានសមហេតុផលដើម្បីអោយជឿថា មានបទល្មើសណាមួយដូចដែលបានចែងដោយអនុឡោមទៅតាមមាត្រា ១៥ ២១និង២៣ នៃអនុសញ្ញានេះត្រូវបានគេប្រព្រឹត្តិឡើង រឺ

ខ. ការផ្តល់ពតិមានចាំបាច់ទាំងអស់តាមរយៈការស្នើសុំទៅអោយអាជ្ញាធរក្រោយគេ ។

## មាត្រា ៣៩

## កិច្ចសហការរវាងអាជ្ញាធរជាតិនិងផ្នែកឯកជន

១. ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការបែបហ្នឹងនៅពេលណាអាចចាំបាច់ដើម្បីលើកទឹកចិត្តដល់ការសហការរវាងអាជ្ញាធរកាត់ទោសនិងស៊ើបអង្កេតជាតិ និងអង្គភាពនៃផ្នែកឯកជនទាំងអស់ ជាពិសេសស្ថាបន័ហិរញ្ញវត្ថុដែលជាប់ពាក់ពន្ធ័នឹងការប្រព្រឹត្តិបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

២. ភាគីរដ្ឋនីមួយៗត្រូវពិចារណាលើការលើកទឹកចិត្តមន្ត្រីជាតិរបស់ខ្លួននិងជនដទៃៗទៀតដែលមានទីលំនៅជាប់លាប់នៅក្នុងទឹកដីរបស់ខ្លួនអោយរាយការណ៍ជូនអាជ្ញាធរកាត់ទោសនិងស៊ើបអង្កេតជាតិនូវការប្រព្រឹត្តិបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ។

## មាត្រា ៤០

### គោលការណ៍សំងាត់ធនាគារ

ក្នុងករណីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងប្រទេស ដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗត្រូវធានាថា មានយន្តការសមស្របដែលមាននៅក្នុងប្រពន្ធ័ច្បាប់ក្នុងប្រទេសរបស់ខ្លួនដើម្បីជំនះរាល់ឧបសគ្គទាំងឡាយដែលអាចកើតមានឡើងក្រៅពីការអនុវត្តន៍ច្បាប់សំងាត់ធនាគារ ។

## មាត្រា ៤១

### របាយការណ៍ព្រហ្មទណ្ឌ

ភាគីរដ្ឋនីមួយៗអាចទទូលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹងនិងវិធានការដទៃៗទៀតនៅពេលណាអាចចាំបាច់ដើម្បីធ្វើការពិចារណាទៅលើភាពពិតប្រាកដពីមុនណាមួយនៅក្នុងរដ្ឋផ្សេងរបស់ជនល្មើសដែលគេបានចោទប្រកាន់ សំរាប់គោលបំណងប្រើប្រាស់ពតិមានបែបហ្នឹងនៅក្នុងដំណើរការព្រហ្មទណ្ឌដែលជាប់ទាក់ទងនឹងបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះនៅក្រោមលក្ខខណ្ឌបែបហ្នឹង និងសំរាប់គោលបំណងដែលវាមើលឃើញថាសមស្រប ។

## មាត្រា ៤២

### យុត្តាធិការ

១. ភាគីរដ្ឋនីមួយៗត្រូវទទូលយកទុកជារបស់ខ្លួននូវវិធានការច្បាប់បែបហ្នឹងនិងវិធានការដទៃៗទៀតនៅពេលណាចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ នៅពេលណា :

ក. បទល្មើសត្រូវបានគេប្រព្រឹត្តិនៅក្នុងទឹកដីរបស់ភាគីរដ្ឋនោះ រឺ

ខ. បទល្មើសត្រូវបានគេប្រព្រឹត្តិនៅលើនាវាដែលមានទង់ជាតិរបស់ភាគីរដ្ឋនោះ រឺនៅលើយន្តហោះដែលបានចុះបញ្ជីក្រោមច្បាប់របស់ភាគីរដ្ឋនោះ នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តិឡើង ។

២. ដោយអនុឡោមទៅតាមមាត្រា ៤នៃអនុសញ្ញានេះ ភាគីរដ្ឋមួយក៏អាចបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសបែបហ្នឹងណាមួយ នៅពេល :

ក. បទល្មើសត្រូវបានគេប្រព្រឹត្តិប្រឆាំងនឹងជនជាតិណាមួយនៃភាគីរដ្ឋនោះ រឺ

ខ. បទល្មើសត្រូវបានប្រព្រឹត្តិដោយជនជាតិណាមួយនៃភាគីរដ្ឋនោះ រឺជនគ្មានជាតិកំណើតដែលមានលំនៅជាប់លាប់របស់គេនៅក្នុងទឹកដីរបស់ខ្លួន រឺ

គ. បទល្មើសនោះជាបទល្មើសមួយដូចដែលបានចែងដោយអនុឡោមទៅតាមមាត្រា ២៣ កថាខណ្ឌ ១ (ខ)(ii) នៃអនុសញ្ញានេះ ហើយត្រូវបានគេប្រព្រឹត្តិនៅខាងក្រៅទឹកដីរបស់ខ្លួនជាមួយការយល់ឃើញថាការប្រព្រឹត្តិបទល្មើសនោះនៅក្នុងទឹកដីរបស់ខ្លួនដូចដែលបានចែងដោយអនុឡោមទៅតាមមាត្រា ២៣ កថាខណ្ឌ ១ (ក)(i)រឺ(ii) រឺ(ខ)(i) នៃ អនុសញ្ញានេះ រឺ

ឃ. បទល្មើសត្រូវបានប្រព្រឹត្តិប្រឆាំងនឹងភាគីរដ្ឋនោះ ។

៣. ចំពោះគោលបំណងនៃមាត្រា ៤៤នៃអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការបែបហ្នឹងនៅពេលណាចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ នៅពេលជនល្មើសដែលគេចោទប្រកាន់មានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន ហើយខ្លួនមិនធ្វើបត្យាបន័ជននោះផ្អែកលើមូលដ្ឋានដែលគេជាជនជាតិមួយនៃជនជាតិរបស់ខ្លួន។

៤. ភាគីរដ្ឋនីមួយៗអាចចាត់វិធានការបែបនោះផងដែរនៅពេលណាចាំបាច់ដើម្បីយុត្តាធិការរបស់ខ្លួនលើបទល្មើសដូចដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះ នៅពេលជនល្មើសដែលគេបានចោទប្រកាន់នោះមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន ហើយខ្លួនមិនធ្វើបត្យាបន័ជននោះ ។

៥. ប្រសិនបើភាគីរដ្ឋមួយដែលអនុវត្តយុត្តាធិការរបស់ខ្លួនក្រោមកថាខណ្ឌ ១ រឺ២ នៃមាត្រានេះ ត្រូវបានគេប្រកាសជូនដំណឹង រឺបើពុំនោះសោតបានដឹងថា ភាគីរដ្ឋដទៃៗទៀតកំពុងអនុវត្តការស៊ើបអង្កេត ការកាត់ទោស រឺដំណើរការតុលាការដោយអនុឡោមទៅតាមឥរិយាបទដូចគ្នា នោះអាជ្ញាធរមាសមត្ថកិច្ចរបស់ភាគីរដ្ឋទាំងនោះនៅពេលណាសមស្របត្រូវពិគ្រោះនឹងភាគីរដ្ឋមួយផ្សេងទៀតជាមួយទស្សនៈសំរបសំរួលវិធានការរបស់ពួកគេ ។

៦. ដោយគ្មានបុរេនិច្ឆ័យចំពោះបទដ្ឋានទាំងឡាយរបស់ច្បាប់អន្តរជាតិទូទៅ អនុសញ្ញានេះមិនត្រូវដកចេញនូវការអនុវត្តន៍យុត្តាធិការព្រហ្មទណ្ឌណាមួយ ដែលបានចែងដោយភាគីរដ្ឋមួយស្របទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន។

## ជំពូក IV

## កិច្ចសហប្រតិបត្តិការអន្តរជាតិ

### មាត្រា ៤៣

### កិច្ចសហប្រតិបត្តិការអន្តរជាតិ

១. ភាគីរដ្ឋទាំងអស់ត្រូវសហការគ្នាក្នុងរឿងព្រហ្មទណ្ឌដោយអនុឡោមទៅតាមមាត្រា ៤៤ដល់ ៥០នៃអនុសញ្ញានេះ។ នៅពេលណាសមស្របហើយស្របទៅតាមប្រពន្ធ័ច្បាប់ក្នុងប្រទេសរបស់ពួកគេ ភាគីរដ្ឋទាំងអស់ត្រូវពិចារណាលើការជួយគ្នាទៅវិញទៅមកក្នុងការស៊ើបអង្កេត និងបណ្តឹងក្នុងរឿងរដ្ឋបាលនិងរដ្ឋប្បវេណីដែលជាប់ពាក់ពន្ធ័នឹងអំពើពុករលួយ។

២. ក្នុងបញ្ហានៃកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅពេលណាក៏ដោយអំពើឧក្រិដ្ឋទ្វេរភាគត្រូវបានគេចាត់ទុកថាជាតំរូវការមួយ នោះវានឹងត្រូវបានគេយល់ឃើញថាមិនបានគិតគូរពេញលេញ ទោះជាច្បាប់របស់ទីកន្លែងភាគីរដ្ឋដែលបានស្នើសុំក៏ដោយ ដល់បទល្មើសនៅក្នុងប្រភេទបទល្មើសតែមួយដូចគ្នា រឺកំណត់ឈ្មោះបទលើសតាមរយៈប្រជុំសព្ទ័តែមួយដូចដែលភាគីរដ្ឋកំពុងស្នើសុំ ប្រសិនបើ ការអនុវត្តន៏នៅក្រោមបទល្មើសចំពោះជំនួយដែលត្រូវបានគេស្វែងរកនោះ គឺជាបទល្មើសព្រហ្មទណ្ឌ័ក្រោមច្បាប់របស់ភាគីរដ្ឋទាំងពីរ។

### មាត្រា ៤៤

### ការធ្វើបត្យាបន័

១. មាត្រានេះត្រូវអនុវត្តចំពោះបទល្មើសដែលបានចែងឡើងដោយអនុឡោមទៅតាមអនុសញ្ញានេះ នៅពេលជនដែលជាប្រធានបទនៃសំណើសំរាប់ការធ្វើបត្យាបន័ មានវត្តមាននៅក្នុងទឹកដីរបស់ភាគីរដ្ឋដែលគេបានស្នើសុំ បានចែងថា បទល្មើសដែលត្រូវបានគេស្វែងរកបត្យាបន័គឺអាចផ្តន្ទាទោសបានក្រោមច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋដែលគេបានស្នើសុំ និងភាគីរដ្ឋដែលស្នើសុំ។

២. ថ្វីបើមានខដែលបានចែងនៃកថាខណ្ឌ ១នៃមាត្រានេះ ភាគីរដ្ឋមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យផងដែរ អាចផ្តល់បត្យាបន័ដល់ជនណាម្នាក់សំរាប់បទល្មើសណាមួយគ្រប់ដណ្តប់ដោយអនុសញ្ញានេះដែលមិនអាចផ្តន្ទាទោសបានក្រោមច្បាប់ក្នុងប្រទេសរបស់ខ្លួន។

៣. ប្រសិនបើសំណើសំរាប់បត្យាបន័រួមបញ្ចូលបទល្មើសដាច់ៗដោយឡែកពីគ្នាជាច្រើន យ៉ាងហោចណាស់បទល្មើសមួយនៃបទល្មើសទាំងនោះអាចធ្វើបត្យាបន័បានក្រោមមាត្រានេះ ហើយបទល្មើសមួយចំនួនមិនអាចធ្វើបត្យាបន័បានដោយហេតុផលនៃអំឡុងពេលដាក់គុករបស់ពួកគេ ប៉ុន្តែជាប់ទាក់ទងទៅនឹងបទល្មើសដែលបានចែងឡើងដោយអនុឡោមទៅតាមអនុសញ្ញានេះ នោះភាគីរដ្ឋដែលបានធ្វើសំណើអាចអនុវត្តមាត្រានេះផងដែរដោយស្របទៅតាមបទល្មើសទាំងនោះ។

៤. បទល្មើសនីមួយៗដែលអនុវត្តចំពោះមាត្រានេះត្រូវបានគេយល់ឃើញថាត្រូវបញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាបន័បានទៅក្នុងសិទ្ធិសញ្ញាបត្យាបន័ណាមួយដែលមានរវាងភាគីរដ្ឋទាំងអស់។ ភាគីរដ្ឋទាំងអស់ទទួលរ៉ាប់រងដើម្បីបញ្ចូលបទល្មើសបែបហ្នឹងជាបទល្មើសដែលអាចធ្វើបត្យាបន័បានទៅក្នុងគ្រប់សន្ធិសញ្ញាបត្យាបន័ដើម្បីអោយគេអនុវត្តរវាងពួកគេ។ ភាគីរដ្ឋមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតផងដែរក្នុងករណីដែលខ្លួនប្រើប្រាស់អនុសញ្ញានេះជាមូលដ្ឋានសំរាប់ការធ្វើបត្យាបន័ មិនត្រូវគិតពិចារណាដល់បទល្មើសណាមួយដែលបានចែងឡើងដោយអនុឡោមទៅតាមអនុសញ្ញានេះថាជាបទល្មើសនយោបាយឡើយ។

៥. ប្រសិនបើភាគីរដ្ឋមួយដែលធ្វើបត្យាបន័ដែលមានលក្ខខណ្ឌស្តីពីការមានសន្ធិសញ្ញាទទួលបាននូវសំណើមួយសំរាប់បត្យាបន័ពីភាគីរដ្ឋមួយផ្សេងទៀត ដែលជាមួយនឹងសំណើនេះ ខ្លួនមិនមានសន្ធិសញ្ញាបត្យាប័ននេះ នោះខ្លួនអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានស្របច្បាប់សំរាប់ការធ្វើបត្យាបន័ដោយអនុឡោមទៅតាមបទល្មើសណាមួយដែលមាត្រានេះអនុវត្ត។

៦. ភាគីរដ្ឋមួយដែលធ្វើបត្យាបន័ដែលមានលក្ខខណ្ឌស្តីពីការមានសន្ធិសញ្ញាត្រូវ :

ក. នៅពេលដាក់ឯកសារសច្ចានុម័តរបស់ខ្លួន ការទទួលយក រឺការយល់ព្រម រឺការយល់ព្រមចំពោះអនុសញ្ញានេះ ត្រូវជូនដំណឹងដល់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិថាតើវានឹងទទួលយកអនុសញ្ញានេះជាមូលដ្ឋានស្របច្បាប់សំរាប់កិច្ចសហប្រតិបត្តិការស្តីពីការធ្វើបត្យាបន័ជាមួយនឹងភាគីរដ្ឋដទៃៗទៀតចំពោះអនុសញ្ញានេះ ហើយ

ខ. ប្រសិនបើវាមិនទទួលយកអនុសញ្ញានេះជាមូលដ្ឋានស្របច្បាប់សំរាប់កិច្ចសហប្រតិបត្តិការស្តីពីការធ្វើ

បត្យាបន័ទេ នៅពេលណាសមស្របត្រូវស្វះស្វែងដើម្បីបញ្ចូលសន្ធិសញ្ញាទាំងឡាយស្តីពីការធ្វើបត្យាបន័ជាមួយនឹងភាគីរដ្ឋផ្សេងៗទៀតចំពោះអនុសញ្ញានេះដើម្បីអនុវត្តមាត្រានេះ ។

៧. ភាគីរដ្ឋទាំងអស់ដែលមិនធ្វើបត្យាបន័ដែលមានលក្ខខណ្ឌស្តីពីការមានសន្ធិសញ្ញា ត្រូវទទួលស្គាល់បទល្មើសទាំងឡាយដែលមាត្រានេះអនុវត្តជាបទល្មើសដែលអាចធ្វើបត្យាបន័បានរវាងពួកគេ ។

៨. ការធ្វើបត្យាបន័ត្រូវមានលក្ខខណ្ឌដែលបានផ្តល់ដោយច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋដែលគេបានស្នើ រឺដោយសន្ធិសញ្ញាបត្យាបន័ដែលអាចអនុវត្តបាន រួមមានលក្ខខណ្ឌជាប់ពាក់ពន្ធ័ទៅនឹងការតំរូវ ទោសទណ្ឌអប្បបរិមាសំរាប់ការធ្វើបត្យាបន័និងសំរាប់មូលដ្ឋានដោយផ្អែកលើមូលដ្ឋាននេះ ភាគីរដ្ឋដែលគេបានស្នើសុំអាចបដិសេធការធ្វើបត្យាបន័បាន ។

៩. ដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ភាគីរដ្ឋទាំងអស់ត្រូវខំខ្នះខ្នែងដើម្បីធ្វើនីតិវិធីបត្យាបន័អោយបានរួសរាន់ និងដើម្បីធ្វើអោយតំរូវការភស្តុតាងងាយស្រួលដែលជាប់ទាក់ទងនឹងបញ្ហានោះ ដោយគោរពទៅតាមបទល្មើសណាមួយដែលមាត្រានេះអនុវត្ត ។

១០. ដោយអនុឡោមទៅតាមខដែលបានចែងនៃច្បាប់ក្នុងប្រទេសនិងសន្ធិសញ្ញាបត្យាបន័របស់ខ្លួន ភាគីរដ្ឋដែលគេបានស្នើសុំដោយផ្អែកលើការឯកភាពពេញចិត្តរបស់ខ្លួនចំពោះ កាលៈទេសៈដែលតំរូវ និងបន្ទាន់ និងទៅតាមសំណើរបស់ភាគីរដ្ឋដែលស្នើសុំនោះអាចទទួលយកជនណាម្នាក់ដែលគេបានស្វែងរកបត្យាបន័អោយហើយជននោះកំពុងតែមានវត្តមានទៅក្នុងទឹកដីរបស់ខ្លួនកំពុងជាប់ឃុំឃាំង រឺ ចាត់វិធានការសមស្របដទៃៗទៀតដើម្បីធានាដល់វត្តមានរបស់ជននោះនៅពេលដំណើរការបត្យាបន័ ។

១១. នៅពេលជនល្មើសដែលគេបានចោទប្រកាន់ត្រូវបានគេរកឃើញនៅក្នុងទឹកដីរបស់ខ្លួន ប្រសិនបើភាគីរដ្ឋនោះមិនផ្តល់សច្ចាបន័ដល់ជនល្មើសនោះដោយគោរពទៅតាមបទល្មើសដែលមាត្រានេះអនុវត្តស្តីពីមូលដ្ឋានដែលគេគឺជនជាតិម្នាក់នៃជនជាតិរបស់ខ្លួន ភាគីរដ្ឋនោះត្រូវតំរូវអោយដាក់ជូនករណីនេះដោយគ្មានការពន្យាពេលហួសហេតុទៅអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនសំរាប់គោលបំណងកាត់ទោស ទៅតាមសំណើរបស់ភាគីរដ្ឋដែលកំពុងស្វែងរកបត្យាបន័ ។ អាជ្ញាធរទាំងនោះត្រូវទទួលយកសេចក្តីសំរេចរបស់ពួកគេ ហើយអនុវត្តដំណើរការរបស់ពួកគេនៅក្នុងបែបបទតែមួយដូចគ្នានៅក្នុងករណីបទល្មើសផ្សេងទៀតណាមួយនៃសារជាតិធ្ងន់ធ្ងរក្រោមច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋនោះ ។

១២. នៅពេលណាក៏ដោយ អោយតែភាគីរដ្ឋមួយត្រូវបានគេអនុញ្ញាតអោយនៅក្រោមច្បាប់ក្នុងប្រទេសរបស់ខ្លួន ដើម្បីធ្វើបត្យាប័ន ឬពុំនោះសោតគ្រាន់តែប្រគល់ជនម្នាក់នៃជនជាតិរបស់ខ្លួន ដោយផ្អែកលើលក្ខខណ្ឌដែលជននោះនឹងត្រូវបានគេបញ្ជូនត្រឡប់មកកាន់ភាគីរដ្ឋវិញនោះ ដើម្បីទទួលការវិនិច្ឆ័យទោសដែលបានដាក់ជាលទ្ធផលនៃការកាត់ក្តី ឬបណ្តឹងដែលការធ្វើបត្យាប័ន ឬការប្រគល់ជននោះត្រូវបានគេស្វែងរកសំរាប់ហេតុផលនេះ ហើយភាគីរដ្ឋនោះនិងភាគីរដ្ឋដែលកំពុងស្វែងរកបត្យាប័ននៃជននោះ យល់ព្រមជាមួយនឹងជំរើសនេះនិងលក្ខខណ្ឌដទៃទៀតដែលពួកគេអាចយល់ឃើញថាសមស្រប ការប្រគល់ ឬការធ្វើបត្យាប័នដែលមានលក្ខខណ្ឌបែបនោះត្រូវមានលក្ខណៈគ្រប់គ្រាន់ដើម្បីផ្តល់ការតព្វកិច្ចដូចដែលបានចែងនៅក្នុងកថាខណ្ឌ ១១ នៃមាត្រានេះ។

១៣. ប្រសិនបើបត្យាប័នដែលបានស្វែងរកសំរាប់គោលបំណងអនុវត្តការកាត់ទោសត្រូវបានគេបដិសេធ ពីព្រោះជនដែលគេបានស្វែងរកនោះគឺជាជនជាតិមួយរបស់ភាគីរដ្ឋដែលត្រូវបានស្នើសុំ នោះភាគីរដ្ឋនោះត្រូវពិចារណាលើការអនុវត្តន៍ការកាត់ទោសដែលបានដាក់នៅក្រោមច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋដែលស្នើសុំ ឬភាគីរដ្ឋដែលត្រូវបានស្នើសុំនោះ ប្រសិនបើច្បាប់ក្នុងប្រទេសរបស់ខ្លួនអនុញ្ញាតអោយដែរ ហើយដោយអនុឡោមទៅតាមតំរូវការនៃច្បាប់បែបហ្នឹងអាស្រ័យលើការអនុវត្តន៍របស់ភាគីរដ្ឋដែលស្នើសុំ។

១៤. ជនណាក៏ដោយដែលត្រូវគេប្តឹងដោយជាប់ទាក់ទងនឹងបទល្មើសណាមួយដែលមាត្រានេះអនុវត្ត ត្រូវបានគេធានានូវការប្រព្រឹត្តិត្រឹមត្រូវនៅគ្រប់ដំណាក់កាលទាំងអស់នៃបណ្តឹង រួមមានការទទួលបានសិទ្ធិគ្រប់យ៉ាងនិងអ្នកធានា ដូចបានចែងដោយច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋមួយដែលក្នុងទឹកដីនោះ ជននោះកំពុងមានវត្តមាន។

១៥. គ្មានអ្វីនៅក្នុងអនុសញ្ញានេះត្រូវបានបកស្រាយថា ជាការដាក់កាតព្វកិច្ចអោយធ្វើសច្ចាប័ន ប្រសិនបើភាគីរដ្ឋដែលគេបានស្នើសុំនោះមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីជឿថា សំណើនោះត្រូវបានគេធ្វើឡើងសំរាប់គោលបំណងការកាត់ទោស ឬការផ្តន្ទាទោសជនម្នាក់ដោយសារភេទ សាសន៍ សាសនា សញ្ជាតិ ដើមកំណើត ឬទស្សនៈនយោបាយរបស់ជននោះ ឬ ជឿថា ការស្របទៅតាមសំណើនឹងបណ្តាលអោយមានបុរេនិច្ឆ័យចំពោះតួនាទីរបស់ជននោះសំរាប់ហេតុផលណាមួយនោះទេ។

១៦. ភាគីរដ្ឋទាំងអស់មិនអាចបដិសេធនូវសំណើសំរាប់ការធ្វើបត្យាប័នស្តីពីមូលដ្ឋានតែមួយគត់ដែលបទល្មើសក៏ត្រូវបានគេគិតផងដែរថាជាប់ពាក់ពន្ធ័នឹងបញ្ហាសារពើពន្ធ។

១៧. មុនពេលបដិសេធការធ្វើបត្យាប់ន័ ភាគីរដ្ឋដែលគេបានស្នើសុំនៅពេលណាសមស្របត្រូវពិគ្រោះជាមួយនឹងភាគីរដ្ឋដែលស្នើសុំ ដើម្បីផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីនោះអោយបង្ហាញជូននូវគំនិតទស្សនៈរបស់ខ្លួន និងអោយផ្តល់ពតិមានដែលជាប់ពាក់ពន្ធ័ចំពោះការចោទប្រកាន់ដោយគ្មានភស្តុតាងរបស់ខ្លួន។

១៨. ភាគីរដ្ឋទាំងអស់ត្រូវស្វះស្វែងធ្វើការសន្និដ្ឋានកិច្ចព្រមព្រៀង រឺការរៀបចំទ្វេរភាគីនិងពហុភាគី ដើម្បីអនុវត្ត រឺដើម្បីលើកកំពស់ប្រសិទ្ធិភាពនៃបត្យាប់ន័។

## មាត្រា ៤៥

## ការបញ្ជូនជនជាប់ទោស

ភាគីរដ្ឋទាំងអស់អាចពិចារណាលើការចូលក្នុងការរៀបចំ រឺកិច្ចព្រមព្រៀងទ្វេរភាគីនិងពហុភាគីស្តីពីការបញ្ជូនជនជាប់ទោសទៅកាន់ទឹកដីរបស់ពួកគេដើម្បីដាក់គុក រឺទំរង់បែបបទផ្សេងទៀតនៃការដកហូតសេរីភាពសំរាប់បទល្មើសដែលបានចែងឡើងដោយអនុឡោមទៅតាមអនុសញ្ញានេះទៅតាមលំដាប់លំដោយដែលពួកគេអាចបង្គ្រប់ការកាត់ទោសរបស់ពួកគេនៅទីនោះ។

## មាត្រា ៤៦

## ជំនួយផ្នែកច្បាប់ទៅវិញទៅមក

១. ភាគីរដ្ឋទាំងអស់ត្រូវស្វះស្វែងរកពីគ្នាទៅវិញទៅមកនូវវិធានការទូលំទូលាយបំផុតនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងការស៊ើបអង្កេត ការកាត់ទោសនិងដំណើរការតុលាការដែលជាប់ពាក់ពន្ធ័ទៅនឹងបទល្មើសដែលគ្រប់ដណ្តប់ដោយអនុសញ្ញានេះ។

២. ជំនួយផ្នែកច្បាប់ទៅវិញទៅមកត្រូវតែបានខំស្វះស្វែងរកសំរាប់វិសាលភាពពេញលេញបំផុតដែលអាចធ្វើទៅបានក្រោមច្បាប់សិទ្ធិសញ្ញា កិច្ចព្រមព្រៀង និងការរៀបចំដែលជាប់ពាក់ពន្ធ័របស់ភាគីរដ្ឋដែលគេបានស្នើសុំដោយគោរពទៅតាមការស៊ើបអង្កេត ការកាត់ទោស និងដំណើរការតុលាការដែលជាប់ពាក់ពន្ធ័ទៅនឹងបទល្មើសដែលនីតិបុគ្គលម្នាក់អាចទទួលខុសត្រូវដោយអនុឡោមទៅតាមមាត្រា ២៦ នៃអនុសញ្ញានេះនៅក្នុងភាគីរដ្ឋដែលស្នើសុំ។

៣. ជំនួយផ្នែកច្បាប់ទៅវិញទៅមកដែលត្រូវខំស្វះស្វែងរកដោយអនុឡោមទៅតាមមាត្រានេះអាចត្រូវបានគេស្នើសុំសំរាប់គោលបំណងណាមួយដូចខាងក្រោម:

ក. ការយកភស្តុតាង រឺសេចក្តីអះអាងពីជនណាម្នាក់

ខ. ការមានឥទ្ធិពលលើការបំរើនៃឯកសារតុលាការ

គ. ការប្រតិបត្តិការឆែកឆេរនិងការរឹបអូស និងការបង្កក

ឃ. ការធ្វើកោសល្យវិច័្ឆយលើវត្ថុនិងទីកន្លែង

ង. ការផ្តល់ពត៌មាន ឯកសារភស្តុតាង និងការវាយតំលៃជំនាញ

ច. ការផ្តល់ច្បាប់ដើម រឺច្បាប់ថតចំលងនៃឯកសារនិងបញ្ជីដែលជាប់ពាក់ពន្ធ័ រួមមានបញ្ជីជំនួញ បញ្ជីសាជីវកម្ម បញ្ជីហិរញ្ញវត្ថុ បញ្ជីធនាគារ បញ្ជីរដ្ឋាភិបាល

ឆ. ការធ្វើអត្តសញ្ញាណកម្ម រឺការតាមដានចំណូលពីបទឧក្រិដ្ឋ ទ្រព្យសម្បត្តិ ការប្រើឧបករណ៍ រឺវត្ថុដទៃទៀតសំរាប់គោលបំណងភស្តុតាង

ជ. ការបង្កលក្ខណៈងាយស្រួលដល់ការបង្ហាញមុខដោយស្មគ្រ័ចិត្តរបស់ជននោះនៅក្នុងភាគីរដ្ឋដែលស្នើសុំ

ឈ. ជំនួយប្រភេទណាមួយផ្សេងទៀតដែលមិនផ្ទុយទៅនឹងច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋដែលគេបានស្នើ

ញ. ការធ្វើអត្តសញ្ញាណកម្ម ការបង្កកនិងការតាមដានចំណូលពីបទល្មើសដោយអនុឡោមទៅតាមខដែលបានចែងនៃជំពូក ៥នៃអនុសញ្ញានេះ

ដ. ការទទួលបានទ្រព្យមកវិញ ដោយអនុឡោមទៅតាមខដែលបានចែងនៃជំពូក ៥នៃអនុសញ្ញានេះ

៤. ដោយគ្មានបុរេនិច្ឆ័យចំពោះច្បាប់ក្នុងប្រទេស អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីរដ្ឋមួយដោយគ្មានសំណើអាទិភាពអាចបញ្ជូនពត៌មានដែលជាប់ពាក់ពន្ធ័ទៅនឹងរឿងព្រហ្មទណ្ឌ័ទៅអោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងភាគីរដ្ឋផ្សេងទៀត ដែលពួកគេមានជំនឿថា ពត៌មានបែបហ្នឹងអាចជួយដល់អាជ្ញាធរក្នុងការអនុវត្តន៍ រឺការសន្និដ្ឋានការស៊ើបអង្កេតនិងបណ្តឹងព្រហ្មទណ្ឌប្រកបដោយជោគជ័យ រឺអាចជាលទ្ធផលសំណើដែលបានបង្កើតឡើងដោយភាគីរដ្ឋក្រោយគេស្របទៅតាមអនុសញ្ញានេះ ។

៥. ការបញ្ជូនពត៌មានដោយអនុឡោមទៅតាមកថាខណ្ឌ័ ៤នៃមាត្រានេះ មិនត្រូវមានបុរេនិច្ឆ័យចំពោះការស៊ើបអង្កេត និងបណ្តឹងព្រហ្មទណ្ឌក្នុងរដ្ឋនៃអាជ្ញាធរមានសត្ថកិច្ចដែលផ្តល់ពត៌មាន ។ អាជ្ញាធរមានសមត្ថកិច្ចដែលផ្តល់ពត៌មានត្រូវធ្វើតាមសំណើដែលបានស្នើសុំអោយពត៌មាននៅតែសំងាត់ ទោះជាបណ្តោះក៏ដោយ រឺធ្វើតាមការកំរិតលើការប្រើប្រាស់ពត៌មាននោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ការនេះមិនត្រូវរារាំងដល់ភាគីរដ្ឋដែលទទួល ពីការផ្សាយពត៌មានទៅតាមដំណើរការរបស់វាដែលអាចអោយជនជាប់ចោទរួចទោស ។ ក្នុងករណីបែបហ្នឹង ភាគីរដ្ឋដែលទទួលនោះត្រូវផ្តល់ដំណឹងដល់ភាគីរដ្ឋដែលបញ្ជូនជាមុនចំពោះការផ្សាយ ហើយប្រសិន

បើបានធ្វើសំណើដូចនេះ ត្រូវពិគ្រោះជាមួយនឹងភាគីរដ្ឋដែលបញ្ជូនពតិមាន។ ប្រសិនបើក្នុងករណីលើកលែងសេចក្តីប្រកាសជូនដំណឹងមិនអាចធ្វើទៅបាន នោះភាគីរដ្ឋដែលទទួលត្រូវជូនដំណឹងទៅអោយភាគីរដ្ឋដែលផ្តល់ពតិមានស្តីអំពីការផ្សាយពតិមានដោយមិនបង្អង់យូរ។

៦. ខដែលបានចែងនៃមាត្រានេះមិនត្រូវជះឥទ្ធិពលដល់កាតព្វកិច្ចក្រោមសន្ធិសញ្ញាទ្វេរភាគីរឺពហុភាគីផ្សេងទៀតណាមួយ ដែលគ្រប់គ្រង រឺ នឹងគ្រប់គ្រងជំនួយផ្នែកច្បាប់ទៅវិញទៅមកដោយផ្នែក រឺទាំងស្រុង។

៧. កថាខណ្ឌ ៩ ដល់ ២៩ នៃមាត្រានេះត្រូវអនុវត្តចំពោះសំណើដែលបានធ្វើឡើងស្របទៅតាមមាត្រានេះប្រសិនបើភាគីរដ្ឋទាំងអស់ដែលមានបញ្ហាមិនបានចងសម្ពន្ធ័ក្នុងតាមរយៈសន្ធិសញ្ញានៃជំនួយផ្នែកច្បាប់ទៅវិញទៅមកទេនោះ។ ប្រសិនបើភាគីរដ្ឋទាំងនោះមិនបានចងសម្ពន្ធ័ក្នុងតាមរយៈសន្ធិសញ្ញាបែបហ្នឹង ខដែលបានចែងទាក់ទងគ្នានៃសន្ធិសញ្ញានោះត្រូវអនុវត្ត វាលែងតែភាគីរដ្ឋទាំងអស់យល់ព្រមអនុវត្តកថាខណ្ឌ ៩ ដល់ ២៩ នៃមាត្រានេះជំនួសសន្ធិសញ្ញានោះ។ ភាគីរដ្ឋទាំងអស់ត្រូវបានជំរុញលើកទឹកចិត្តយ៉ាងខ្លាំងអោយអនុវត្តកថាខណ្ឌទាំងនោះ ប្រសិនបើពួកគេជួយបង្កលក្ខណៈងាយស្រួលដល់កិច្ចសហប្រតិបត្តិការ។

៨. ភាគីរដ្ឋទាំងអស់មិនត្រូវមិនព្រមផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកស្របទៅតាមមាត្រានេះស្តីពីមូលដ្ឋាននៃការសំងាត់ធនាគារ។

៩. (ក) ភាគីរដ្ឋដែលគេបានស្នើសុំដោយឆ្លើយតបនឹងសំណើសុំជំនួយស្របទៅតាមមាត្រានេះក្នុងករណីអវត្តមាននៃឧក្រិដ្ឋកម្មទ្វេរ ត្រូវគិតពិចារណាលើគោលបំណងនៃអនុសញ្ញានេះ ដូចដែលបានចែងនៅក្នុងមាត្រា ១។

(ខ). ភាគីរដ្ឋទាំងអស់អាចមិនយល់ព្រមផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកស្របទៅតាមមាត្រានេះស្តីពីមូលដ្ឋានអវត្តមាននៃឧក្រិដ្ឋកម្មទ្វេរ។ ទោះជាយ៉ាងណាក៏ដោយភាគីរដ្ឋដែលគេបានស្នើសុំ នៅពេលស្របទៅតាមទស្សនៈជាមូលដ្ឋាននៃប្រពន្ធ័ច្បាប់របស់ខ្លួននោះ ត្រូវផ្តល់ជំនួយដែលមិនជាប់ពាក់ពន្ធ័នឹងវិធានការបង្ខាប់បញ្ហា។ ជំនួយបែបហ្នឹងអាចត្រូវបានបដិសេធ នៅពេលណាសំណើនេះជាប់ពាក់ពន្ធ័នឹងបញ្ហាផ្សេងទៀត រឺបញ្ហាដែលកិច្ចសហប្រតិបត្តិការ រឺជំនួយដែលគេបានស្វែងរក គឺស្ថិតនៅក្រោមបញ្ញត្តិដទៃទៀត នៃអនុសញ្ញានេះ

(គ). ភាគីរដ្ឋនីមួយៗអាចពិចារណាលើការទទួលយកទុកជារបស់ខ្លួននូវវិធានការបែបហ្នឹងនៅពេលណាចាំបាច់ដើម្បីធ្វើអោយខ្លួនអាចផ្តល់នូវទំហំជំនួយកាន់តែទូលំទូលាយស្របទៅតាមមាត្រានេះក្នុងអវត្តមានឧក្រិដ្ឋកម្មទ្វេរ។

១០. ជនណាម្នាក់ដែលត្រូវបានគេឃុំខ្លួន រឺកំពុងទទួលការកាត់ទោសនៅក្នុងទឹកដីរបស់ភាគីរដ្ឋមួយ ដែលវត្តមានរបស់គេនៅក្នុងភាគីរដ្ឋមួយផ្សេងទៀត នោះត្រូវបានគេស្នើសុំសំរាប់គោលបំណងនៃការធ្វើអត្តសញ្ញាណកម្មសក្ខីកម្ម រឺពុំនោះសោតសំរាប់ការផ្តល់ជំនួយក្នុងការផ្តល់ភស្តុតាងសំរាប់ការស៊ើបអង្កេត ការកាត់ទោស រឺដំណើរការតុលាការដែលជាប់ពាក់ព័ន្ធនឹងបទល្មើសដែលគ្រប់ដណ្តប់ដោយអនុសញ្ញានេះអាចត្រូវបានគេបញ្ជូនប្រសិនឆ្លើយតបទៅតាមលក្ខខណ្ឌដូចខាងក្រោម :

ក. ជនល្មើសនោះផ្តល់ការយល់ព្រមជូនដំណឹងរបស់ខ្លួន

ខ. អាជ្ញាធរមានសមត្ថកិច្ចនៃភាគីរដ្ឋទាំងសងយល់ព្រមដោយគោរពទៅតាមលក្ខខណ្ឌបែបហ្នឹង នៅពេលភាគីរដ្ឋទាំងនោះអាចយល់ឃើញថាសមស្រប ។

១១. សំរាប់គោលបំណងនៃកថាខណ្ឌ ១០នៃមាត្រានេះ

ក. ភាគីរដ្ឋដែលគេបញ្ជូនជនល្មើសទៅកាន់នោះត្រូវមានអាជ្ញានិងកាតព្វកិច្ចដាក់ជនដែលត្រូវបញ្ជូនមកនោះនៅក្នុងមន្ទីរឃុំឃាំង លើកលែងតែបានស្នើសុំផ្ទុយពីនេះ រឺផ្តល់អាជ្ញាផ្ទុយដោយភាគីរដ្ឋដែលបានបញ្ជូនជនល្មើសមក

ខ. ភាគីរដ្ឋដែលគេបញ្ជូនជនល្មើសទៅកាន់ដោយគ្មានពន្យាពេល ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដើម្បីបញ្ជូនជនល្មើសនោះទៅដាក់គុករបស់ភាគីរដ្ឋដែលបានបញ្ជូនជនល្មើសនោះមកដូចដែលបានព្រមព្រៀងគ្នាជាមុន រឺបើពុំនោះសោតដូចដែលបានព្រមព្រៀងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីរដ្ឋទាំងពីរ

គ. ភាគីរដ្ឋដែលគេបញ្ជូនជនល្មើសទៅកាន់នោះមិនត្រូវទាមទារអោយភាគីរដ្ឋដែលបានបញ្ជូនជនល្មើសមកផ្តួចផ្តើមនីតិវិធីបត្យាប័នសំរាប់ការបញ្ជូនជនល្មើសនោះទេ ។

១២. វៀលែងតែភាគីរដ្ឋដែលបានបញ្ជូនជនល្មើសមកអនុឡោមទៅតាមកថាខណ្ឌ ១០ និង ១១នៃមាត្រានេះយល់ព្រមដូចនេះ ទោះជាជនល្មើសមានសញ្ជាតិអ្វីក៏ដោយមិនត្រូវយកមកកាត់ទោស ឃុំឃាំងខ្លួន ផ្តន្ទាទោស រឺ អាចនឹងមានការរឹតបន្តឹងផ្សេងទៀតណាមួយនៃសេរីភាពរបស់គេនៅក្នុងទឹកដីរបស់ភាគីរដ្ឋដែលគេបានបញ្ជូនជនល្មើសទៅដោយគោរពទៅតាមអង្គហេតុ ការលុបចោល រឺការកាត់អោយជាប់ទោស មុនពេលការចេញដំណើររបស់គេពីទឹកដីរបស់រដ្ឋដែលបានបញ្ជូនជនល្មើសមក ។

១៣. ភាគីរដ្ឋនីមួយៗត្រូវបង្កើតអាជ្ញាធរមជ្ឈិមមួយដែលត្រូវមានការទទួលខុសត្រូវ និងអំណាចដើម្បីទទួលសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ហើយក៏ដើម្បីយកពួកគេមកកាត់ទោស រឺដើម្បីបញ្ជូនពួកគេទៅអោយអា

ជ្ញាធរមានសមត្ថកិច្ចសំរាប់ការប្រតិបត្តិ។ នៅពេលណាភាគីរដ្ឋមួយមានដំបន់ រឺទឹកដីពិសេសមួយដោយមានប្រពន្ធ័ជំនួយផ្នែកច្បាប់ទៅវិញទៅមកដាច់ដោយឡែក នោះភាគីរដ្ឋនោះអាចបង្កើតអាជ្ញាធរមជ្ឈឹមខុសគ្នាដែលត្រូវមានមុខងារដូចគ្នាសំរាប់តំបន់ រឺទឹកដីនោះ។ អាជ្ញាធរមជ្ឈឹមទាំងអស់ត្រូវធានានូវការប្រតិបត្តិ រឺការបញ្ជូនសំណើដែលបានទទួលអោយបានត្រឹមត្រូវហើយលឿនរហ័ស។ នៅពេលណាអាជ្ញាធរមជ្ឈឹមបញ្ជូនសំណើទៅអោយអាជ្ញាធរមានសមត្ថកិច្ចសំរាប់ការប្រតិបត្តិ វាត្រូវលើកទឹកចិត្តដល់ការប្រតិបត្តិសំណើអោយត្រឹមត្រូវហើយលឿនរហ័ស ដោយអាជ្ញាធរមានសមត្ថកិច្ច។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវជូនដំណឹងដល់អាជ្ញាធរមជ្ឈឹមដែលបានបង្កើតសំរាប់គោលបំណងនេះនៅពេលភាគីរដ្ឋនីមួយៗផ្ញើឯកសារសច្ចានុម័ត ការទទួល រឺការយល់ព្រម រឺអ្វីបន្ថែមផ្សេងទៀតរបស់ខ្លួនចំពោះអនុសញ្ញានេះ។ សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការទំនាក់ទំនងណាមួយដែលជាប់ទាក់ទងនោះត្រូវបញ្ជូនទៅអោយអាជ្ញាធរមជ្ឈឹមដែលបានបង្កើតឡើងដោយភាគីរដ្ឋទាំងអស់។ សេចក្តីតំរូវនេះមិនត្រូវមានបុរេនិច្ឆ័យចំពោះសិទ្ធិរបស់ភាគីរដ្ឋមួយតំរូវអោយសំណើនិងទំនាក់ទំនងបែបនោះឆ្លើយតបទៅកាន់វាតាមរយៈបណ្តាញការទូត ហើយនៅពេលភាគីរដ្ឋទាំងអស់យល់ព្រមនៅក្នុងកាលទេសៈបន្ទាន់ តាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិប្រសិនបើអាចធ្វើទៅបាន។

១៤. សំណើទាំងអស់ត្រូវធ្វើជាលាយលាក់អក្សរ រឺនៅពេលណាអាចធ្វើទៅបានតាមមធ្យោបាយណាមួយដែលបើកចំហរចំពោះការធ្វើបញ្ជីជាលាយលក្ខ័អក្សរជាភាសាដែលអាចទទួលយកបានដល់ភាគីរដ្ឋដែលគេបានស្នើសុំក្រោមលក្ខខណ្ឌដែលអនុញ្ញាតអោយភាគីរដ្ឋនោះបង្កើតភាពត្រឹមត្រូវ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវប្រកាសជូនដំណឹងពីភាសាមួយ រឺភាសាទាំងឡាយណាដែលអាចទទួលយកបានដល់ភាគីរដ្ឋនីមួយៗនៅពេលវាផ្ញើឯកសារសច្ចានុម័ត ការទទួល រឺការយល់ព្រម រឺអ្វីបន្ថែមផ្សេងទៀតរបស់ខ្លួនចំពោះអនុសញ្ញានេះ។ នៅក្នុងកាលៈទេសៈបន្ទាន់ហើយនៅពេលណាបានយល់ព្រមដោយភាគីរដ្ឋទាំងអស់ សំណើអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ប៉ុន្តែត្រូវអះអាងបញ្ជាក់ជាលាយលក្ខ័អក្សរភ្លាមៗ។

១៥. សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកត្រូវមាន :

ក. អត្តសញ្ញាណរបស់អាជ្ញាធរដែលធ្វើសំណើ

ខ. បញ្ហា និងធម្មជាតិសំខាន់នៃការស៊ើបអង្កេត ការកាត់ទោស រឺដំណើរការតុលាការដែលសំណើនោះជាប់ទាក់ទង និងឈ្មោះ មុខងាររបស់អាជ្ញាធរដែលអនុវត្តការស៊ើបអង្កេត ការកាត់ទោស រឺដំណើរការតុលាការ

គ. សេចក្ដីសង្ខេបអង្គហេតុដែលជាប់ពាក់ពន្ធ័ លើកលែងតែជាប់ពាក់ពន្ធ័នឹងសំណើសំរាប់គោលបំណងការបំរើឯកសារតុលាការ

ឃ. សេចក្ដីរៀបរាប់ពីជំនួយដែលគេស្វែងរក និងសេចក្ដីលំអិតស្ដីពីនីតិវិធីពិសេសណាមួយដែលភាគីរដ្ឋស្នើសុំចង់អនុវត្តតាម

ង. នៅពេលណាអាចធ្វើទៅបាន អត្តសញ្ញាណ ទីតាំង និងសញ្ជាតិរបស់ជនណាម្នាក់ដែលជាប់ពាក់ពន្ធ័ ហើយ

ច. គោលបំណងស្វែងរកភស្តុតាង ពត៌មាន រឺវិធានការ

១៦. ភាគីរដ្ឋដែលគេបានស្នើសុំអាចធ្វើសំណើសុំពត៌មានបន្ថែម នៅពេលណាវាចំបាច់សំរាប់ការប្រតិបត្តិនៃសំណើដោយអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន រឺនៅពេលវាអាចជួយសំរួលដល់ការប្រតិបត្តិបែបហ្នឹង ។

១៧. សំណើមួយត្រូវបានគេប្រតិបត្តិអនុឡោមទៅតាមច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋដែលគេបានស្នើសុំ និងទៅតាមវិសាលភាពដែលមិនផ្ទុយនឹងច្បាប់ក្នុងប្រទេសរបស់ភាគីរដ្ឋដែលគេបានស្នើសុំ ហើយនៅពេលណាអាចធ្វើទៅបានដោយអនុឡោមទៅតាមនីតិវិធីដែលកំណត់នៅក្នុងសំណើនោះ ។

១៨. នៅទីណាអាចធ្វើទៅបានហើយស្របទៅតាមគោលការណ៍ជាសារវ័ន្តនៃច្បាប់ក្នុងប្រទេស នៅពេលជនណាម្នាក់ស្ថិតនៅក្នុងទឹកដីរបស់ភាគីរដ្ឋមួយហើយត្រូវតែបានទទួលដំណឹងដូចជាសាក្សី រឺអ្នកជំនាញការតាមរយៈអាជ្ញាធរតុលាការរបស់ភាគីរដ្ឋមួយផ្សេងទៀត ភាគីរដ្ឋទីមួយទៅតាមសំណើរបស់ភាគីរដ្ឋមួយទៀត អាចអនុញ្ញាតអោយធ្វើសាវនាការតាមរយៈសន្និសីទវីដេអូ ប្រសិនបើវាមិនអាចធ្វើទៅបាន រឺមិនដូចបំណងសំរាប់បុគ្គលដែលមានបញ្ហាបង្ហាញមុខនៅក្នុងទឹកដីរបស់ភាគីរដ្ឋដែលស្នើសុំ ។ ភាគីរដ្ឋទាំងអស់អាចយល់ព្រម ថាសាវនាការត្រូវបានអនុវត្តដោយអាជ្ញាធរតុលាការរបស់ភាគីរដ្ឋដែលស្នើសុំ ហើយបានចូលរួមដោយអាជ្ញាធរតុលាការរបស់ភាគីរដ្ឋដែលគេស្នើសុំ ។

១៩. ភាគីរដ្ឋដែលស្នើសុំមិនត្រូវបញ្ជូន រឺប្រើប្រាស់ពត៌មាន រឺភស្តុតាងដែលបានផ្ដល់អោយដោយភាគីរដ្ឋដែលគេស្នើសុំសំរាប់ការស៊ើបអង្កេត ការកាត់ទោស រឺដំណើរការតុលាការច្រើនជាងភាគីរដ្ឋទាំងនោះដែលបានអះអាងនៅក្នុងសំណើដោយគ្មានការព្រមព្រៀងមុនរបស់ភាគីរដ្ឋដែលគេស្នើសុំ ។ គ្មានអ្វីនៅក្នុងកថាខណ្ឌ័នេះត្រូវរាំងដល់ភាគីរដ្ឋដែលស្នើសុំពីការផ្សាយពត៌មាន រឺភស្តុតាងនៅក្នុងដំណើរការរបស់ខ្លួន ដែលអោយរួចទោសចំពោះជនជាប់ចោទនោះ ។ នៅក្នុងករណីក្រោយ ភាគីរដ្ឋដែលស្នើសុំត្រូវប្រកាសជូនដំណឹងដល់ភាគីរដ្ឋដែលគេបានស្នើសុំមុនពេលការផ្សាយពត៌មាន ហើយប្រសិនបើបានស្នើសុំដូចនេះ ត្រូវពិគ្រោះជាមួយភាគីរដ្ឋដែល

គេបានស្នើសុំ។ ក្នុងករណីលើកលែងប្រសិនបើសេចក្តីប្រកាសជូនដំណឹងជាមុនគឺមិនអាចធ្វើទៅបាន ភាគីរដ្ឋដែលស្នើសុំត្រូវជូនដំណឹងដល់ភាគីរដ្ឋដែលគេបានស្នើសុំស្តីពីការផ្សាយពត៌មាននោះដោយគ្មានបង្អែបង្អង់។

២០. ភាគីរដ្ឋដែលស្នើសុំអាចតំរូវអោយភាគីរដ្ឋដែលគេស្នើសុំរក្សាជាសំងាត់នូវអង្គហេតុនិងកម្មវត្ថុនៃសំណើ លើកលែងចំពោះវិសាលភាពចាំបាច់ដែលត្រូវប្រតិបត្តិសំណើនោះ។ ប្រសិនបើភាគីដែលគេបានស្នើសុំនោះមិនអាចធ្វើតាមការតំរូវនៃការសំងាត់ ភាគីរដ្ឋនោះត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីរដ្ឋដែលបានស្នើ។

២១. ជំនួយផ្នែកច្បាប់ទៅវិញទៅមកអាចត្រូវបានគេបដិសេធ :

ក. ប្រសិនបើសំណើនោះមិនត្រូវបានគេធ្វើឡើងដោយអនុឡោមទៅតាមខដែលបានចែងនៃមាត្រានេះ

ខ. ប្រសិនបើភាគីរដ្ឋដែលគេបានស្នើសុំពិចារណាថា ការប្រតិបត្តិសំណើគឺទំនងជាធ្វើអោយលំអៀងដល់អធិបតេយ្យភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ រឺផលប្រយោជន៍ចាំបាច់ដទៃទៀតរបស់ខ្លួន

គ. ប្រសិនបើអាជ្ញាធររបស់ភាគីរដ្ឋដែលគេស្នើសុំត្រូវបានហាមឃាត់ដោយច្បាប់ក្នុងប្រទេសរបស់ខ្លួនមិនឱ្យអនុវត្តវិធានការដែលបានស្នើដោយគោរពទៅតាមបទល្មើសស្រដៀង១គ្នាណាមួយ វាត្រូវមានការស៊ើបអង្កេត ការកាត់ទោស រឺដំណើរការតុលាការក្រោមយុត្តាធិការផ្ទាល់របស់ពួកគេ

ឃ. ប្រសិនបើវាមិនផ្ទុយនឹងប្រពន្ធ័ច្បាប់របស់ភាគីរដ្ឋដែលគេបានស្នើសុំដែលជាប់ទាក់ទងនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមកសំរាប់សំណើដែលត្រូវផ្តល់អោយ។

២២. ភាគីរដ្ឋទាំងអស់មិនអាចបដិសេធនូវសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកស្តីពីមូលដ្ឋានតែមួយដែលបទល្មើសនោះក៏ត្រូវបានគេគិតថាជាប់ពាក់ពន្ធ័នឹងបញ្ហាសារពើពន្ធ។

២៣. ហេតុផលទាំងអស់ត្រូវតែផ្តល់អោយសំរាប់ការបដិសេធណាមួយនៃជំនួយផ្នែកច្បាប់ទៅវិញទៅមក។

២៤. ភាគីរដ្ឋដែលគេស្នើសុំត្រូវប្រតិបត្តិសំណើសុំជំនួញផ្នែកច្បាប់ទៅវិញទៅមកឆាប់១តាមដែលអាចធ្វើទៅបាន ហើយត្រូវពិចារណាអោយបានពេញលេញតាមដែលអាចធ្វើទៅបាននូវកាលបរិច្ឆេតកំណត់ដែលបានស្នើឡើងដោយភាគីរដ្ឋដែលបានស្នើសុំ ហើយសំរាប់ហេតុផលដែលត្រូវផ្តល់អោយគួរជាទីពេញចិត្តនៅក្នុងសំណើនោះ។ ភាគីរដ្ឋដែលស្នើសុំនោះអាចធ្វើសំណើសមហេតុផលសុំពត៌មានស្តីពីឋានៈនិងការវិវត្តន៍នៃវិធានការដែលបានអនុវត្តដោយភាគីរដ្ឋដែលគេបានស្នើសុំដើម្បីបំពេញបំណងសំណើរបស់ខ្លួន។ ភាគីរដ្ឋដែលគេបានស្នើសុំនោះត្រូវឆ្លើយតបចំពោះសំណើដែលសមហេតុផលដែលធ្វើឡើងដោយភាគីរដ្ឋស្នើសុំស្តីពីឋានៈ និងការវិវត្តន៍នៃ

សំណើនៅក្នុងការប្រើប្រាស់របស់ខ្លួន។ ភាគីរដ្ឋដែលស្នើសុំត្រូវជូនពត៌មានជាបន្ទាន់ដល់ភាគីរដ្ឋដែលគេបានស្នើសុំ នៅពេលជំនួយគេលែងត្រូវការទៀតនោះ។

២៥. ជំនួយផ្នែកច្បាប់ទៅវិញទៅមកអាចត្រូវបានផ្អាកដោយភាគីរដ្ឋដែលគេបានស្នើសុំស្ដីពីមូលដ្ឋានដែលវាជ្រៀតជ្រែកដល់ការស៊ើប ការកាត់ទោស រឺដំណើរការតុលាការដែលកំពុងប្រព្រឹត្តិទៅ។

២៦. មុនពេលបដិសេធសំណើមួយស្របទៅតាមកថាខណ្ឌ ២១នៃមាត្រានេះ រឺមុនពេលផ្អាកការប្រតិបត្តិរបស់ខ្លួនស្របទៅតាមកថាខណ្ឌ ២៥នៃមាត្រានេះ ភាគីរដ្ឋដែលគេបានស្នើសុំត្រូវពិគ្រោះជាមួយភាគីរដ្ឋដែលស្នើសុំដើម្បីគិតពិចារណាថាតើជំនួយអាចត្រូវបានគេផ្ដល់អោយគោរពទៅតាមលក្ខខណ្ឌបែបហ្នឹងរឺទេ នៅពេលវាបង្ហាញឃើញថាចាំបាច់នោះ។ ប្រសិនបើភាគីរដ្ឋដែលស្នើសុំព្រមទទួលយកជំនួយគោរពទៅតាមលក្ខខណ្ឌទាំងនោះ ភាគីរដ្ឋនោះត្រូវធ្វើទៅតាមលក្ខខណ្ឌទាំងនោះ។

២៧. ដោយគ្មានបុរេនិច្ច័យចំពោះការអនុវត្តនៃកថាខណ្ឌ ១២នៃមាត្រានេះ សាក្សី អ្នកជំនាញការ រឺជនផ្សេងទៀតដែលនៅក្នុងសំណើរបស់ភាគីរដ្ឋដែលស្នើសុំនោះព្រមព្រៀងផ្ដល់ភស្តុតាងក្នុងបណ្ដឹង រឺដើម្បីជួយក្នុងការស៊ើបអង្កេត ការកាត់ទោស រឺដំណើរការតុលាការនៅក្នុងទឹកដីរបស់ភាគីរដ្ឋដែលស្នើសុំនោះមិនត្រូវកាត់ទោស ឃុំខ្លួន ផ្ដន្ទាទោស រឺដាក់អោយទទួលរងការរឹងបណ្ដឹងផ្សេងទៀតណាមួយដល់សេរីភាពផ្ទាល់ខ្លួនរបស់គេ នៅក្នុងទឹកដីនោះ ដោយគោរពទៅតាមអង្គហេតុ ការលុបចោល រឺការកាត់អោយជាប់ទោសមុនពេលការចេញដំណើររបស់គេពីទឹកដីរបស់ភាគីរដ្ឋដែលគេបានស្នើសុំ។ ឥរិយាបទប្រកបដោយសុវត្ថិភាពបែបហ្នឹងត្រូវបញ្ឈប់ នៅពេលសាក្សី អ្នកជំនាញការ រឺជនផ្សេងទៀតដែលសំរាប់រយៈពេល១៥ថ្ងៃជាប់គ្នា រឺសំរាប់រយៈពេលណាមួយដែលបានព្រមព្រៀងគ្នាដោយភាគីរដ្ឋទាំងអស់ចាប់ពីកាលបរិច្ឆេតដែលជននោះត្រូវបានគេជូនដំណឹងអោយជាផ្លូវការ ដែលវត្តមានរបស់គេលែងតំរូវអោយមានទៀតដោយអាជ្ញាធរតុលាការ មានឱកាស ចាកចេញ ឬ បើពុំនោះទេសំរេចចិត្តបន្តនៅក្នុងដែនដីរបស់រដ្ឋដែលស្នើសុំដោយស្ម័គ្រចិត្ត ឬបានចាកចេញហើយ តែបានត្រឡប់មកវិញតាមឆន្ទៈរបស់ខ្លួន ។

២៨. ថ្លៃចំណាយធម្មតានៃការប្រតិបត្តិការសំណើត្រូវបានទទួលខុសត្រូវដោយភាគីរដ្ឋដែលគេបានស្នើសុំ វៀរលែងតែមានការយល់ព្រមផ្សេងដោយភាគីរដ្ឋទាំងអស់ដែលជាប់ពាក់ព័ន្ធ។ ប្រសិនបើការចំណាយនៃធម្ម-ជាតិពិសេស រឺច្រើនសម្បើមត្រូវបាន រឺនឹងតំរូវអោយមានដើម្បីបំពេញបំណងសំណើនោះ ភាគីរដ្ឋទាំងអស់ត្រូវពិគ្រោះគ្នាដើម្បីកំណត់លក្ខខណ្ឌដែលសំណើនឹងត្រូវបានគេប្រតិបត្តិ ដូចជាបែបបទដែលថ្លៃចំណាយទាំងអស់ត្រូវបានរ៉ាប់រង។

២៩. ភាគីរដ្ឋដែលគេបានស្នើ :

ក. ត្រូវផ្តល់ទៅអោយភាគីរដ្ឋដែលស្នើសុំនោះនូវឯកសារថតចំលងនៃបញ្ជីរដ្ឋាភិបាល ឯកសារ រឺពត៌មានក្នុងការកាន់កាប់របស់ខ្លួននៅក្រោមច្បាប់ក្នុងប្រទេសរបស់ខ្លួនគឺសាធារណៈជនទូទៅអាចរកបាន

ខ. ដោយដាច់ដោយឡែកអាចផ្តល់អោយភាគីរដ្ឋដែលស្នើសុំដោយផ្នែក រឺទាំងស្រុង រឺគោរពទៅតាមលក្ខខណ្ឌបែបហ្នឹងនៅពេលវាយល់ឃើញថាសមស្របនូវឯកសារថតចំលងនៃបញ្ជីរដ្ឋាភិបាលណាមួយ ឯកសារ រឺពត៌មានក្នុងការកាន់កាប់របស់ខ្លួននៅក្រោមច្បាប់ក្នុងប្រទេសរបស់ខ្លួននោះមិនអាចផ្តល់អោយសាធារណៈជនបានឡើយ

៣០. ភាគីរដ្ឋទាំងអស់ត្រូវពិចារណានៅពេលណាចាំបាច់លើការទទួលខុសត្រូវនៃការបញ្ចូលកិច្ចព្រមព្រៀង រឺការរៀបចំទ្វេរភាគី រឺពហុភាគី ដែលបំរើគោលបំណង ផ្តល់ប្រសិទ្ធិភាពសំខាន់ដល់ រឺដើម្បីលើកំពស់ខដែលបានចែងនៃមាត្រានេះ ។

## មាត្រា ៤៧

## ការផ្ទេរដំណើរបណ្តឹងព្រហ្មទណ្ឌ

ភាគីរដ្ឋទាំងអស់ត្រូវពិចារណាលើលទ្ធភាពនៃការបញ្ជូនទៅកាន់ដំណើរការមួយផ្សេងទៀតសំរាប់ការកាត់ទោសបទល្មើសដែលបានចែងដោយអនុឡោមទៅតាមអនុសញ្ញានេះក្នុងករណីដែលការបញ្ជូនបែបហ្នឹងត្រូវបានគេពិចារណាថាមានប្រយោជន៍ដល់រដ្ឋបាលត្រឹមត្រូវរបស់តុលាការ ជាពិសេសក្នុងករណីដែលយុត្តាធិការជាច្រើនបានជាប់ពាក់ពន្ធ័ជាមួយទស្សនៈយកចិត្តទុកដាក់លើការកាត់ទោស ។

## មាត្រា ៤៨

## កិច្ចសហការការអនុវត្តន៍ច្បាប់

១. ភាគីរដ្ឋទាំងអស់ត្រូវសហការអោយបានជិតស្និទ្ធជាមួយភាគីរដ្ឋផ្សេងទៀតដោយអនុឡោមទៅតាមប្រពន្ធ័រដ្ឋបាលនិងប្រពន្ធ័ច្បាប់ក្នុងប្រទេសដោយឡែករបស់ពួកគេ ដើម្បីលើកកំពស់ដល់ប្រសិទ្ធិភាពនៃវិធានការអនុវត្តន៍ច្បាប់ប្រយុទ្ធប្រឆាំងនឹងបទល្មើសដែលគ្រប់ដណ្តប់ដោយអនុសញ្ញានេះ ។ ភាគីរដ្ឋទាំងអស់ជាពិសេសត្រូវចាត់វិធានការដែលមានប្រសិទ្ធិភាព :

ក. ដើម្បីលើកកំពស់ ហើយនៅពេលណាចាំបាច់ដើម្បីបង្កើតបណ្តាញទំនាក់ទំនងរវាងអាជ្ញាធរមានសមត្ថកិច្ច ភ្នាក់ងារ និងការបំរើរបស់ពួកគេ ដើម្បីជួយសំរួលដល់កាផ្លាស់ប្តូរឆាប់រហ័សហើយមានសន្តិសុខនូវពតិមានដែលជាប់ពាក់ពន្ធ័ទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់នៃបទល្មើសដែលបានគ្រប់ដណ្តប់ដោយអនុសញ្ញានេះ រួមមាន ការជាប់ទាក់ទងជាមួយសកម្មភាពឧក្រិដ្ឋផ្សេងទៀត ប្រសិនបើភាគីរដ្ឋដែលជាប់ពាក់ពន្ធ័ ទាំងអស់យល់ឃើញថា វាសមស្រប

ខ. ដើម្បីសហប្រតិបត្តិការជាមួយនឹងភាគីរដ្ឋផ្សេងៗទៀតក្នុងការអនុវត្តការស៊ើបអង្កេត ដោយគោរពទៅតាមបទល្មើសដែលបានគ្របដណ្តប់ដោយអនុសញ្ញានេះ ដែលជាប់ពាក់ពន្ធ័នឹង :

(i) អត្តសញ្ញាណ ទីតាំង និងសកម្មភាពរបស់ជនដែលបានសង្ស័យថាមានការជាប់ពាក់ពន្ធ័នឹងបទល្មើសបែបហ្នឹង រឺ ទីតាំងរបស់ជនជាប់ពាក់ពន័ដទៃៗទៀត

(ii) ចលនារបស់ចំណូលពីបទឧក្រិដ្ឋ រឺទ្រព្យសម្បត្តិដែលបានមកពីការប្រព្រឹត្តិបទល្មើសបែបហ្នឹង

(iii) ចលនារបស់ទ្រព្យសម្បត្តិ សំភារៈ រឺឧបរណ៍ដែលបានប្រើប្រាស់ដទៃៗទៀត រឺដែលមានចេតនាសំរាប់ប្រើប្រាស់នៅក្នុងការប្រព្រឹត្តិបទល្មើសបែបហ្នឹង

គ. ផ្តល់នូវចំនួន ឬ បរិមាណចំបាច់នៃសារធាតុ សំរាប់គោលបំណងស៊ើបអង្កេត ឬ វិភាគ នៅពេលណាសមស្រប

ឃ. ផ្លាស់ប្តូរពតិមាន ជាមួយភាគីរដ្ឋដទៃទៀត ដែលពាក់ព័ន្ធទៅនឹងមធ្យោបាយ និង វិធីសាស្ត្រច្បាស់លាស់ដែលធ្លាប់បានប្រើ ដើម្បីប្រព្រឹត្តបទល្មើសដែលគ្របដណ្តប់ដោយអនុសញ្ញានេះ រួម ទាំងការប្រើ ប្រាស់អត្តសញ្ញាណបន្លំ ក្លែងក្លាយ បំប្លែង ឬ ឯកសារបន្លំ និង មធ្យោបាយ ផ្សេងៗនៃការលាក់បំបាំង សកម្មភាព

ង. សំរួលដល់ការសំរបសំរួលអោយមានប្រសិទ្ធភាពរវាងអាជ្ញាធរ ភ្នាក់ងារ និង សេវាកម្មដែលមានសមត្ថកិច្ចរបស់គេ និងដើម្បីជំរុញអោយមានការផ្លាស់ប្តូរបុគ្គលិក និង អ្នកជំនាញផ្សេងៗ ទៀត រួមទាំងចំពោះកិច្ចព្រមព្រៀង ឬ ការសំរុះសំរួលទ្វេភាគី ជាមួយភាគីរដ្ឋដែលពាក់ព័ន្ធការចាត់អោយ ទៅកាន់មុខដំណែងរបស់មន្ត្រីសំរបសំរួល

ច. ផ្លាស់ប្តូរពតិមាន និង សំរបសំរួលផ្នែករដ្ឋបាល និងការចាត់វិធានការផ្សេងៗទៀតដែលមានលក្ខណៈ សមស្របសំរាប់គោលបំណងនៃការបញ្ជាក់អត្តសញ្ញាណនៃបទល្មើសដែលគ្របដណ្តប់ដោយអនុសញ្ញា នេះអោយបានឆាប់ ។

២. ដោយមានការផ្តល់នូវកិច្ចខិតខំប្រឹងប្រែងចំពោះអនុសញ្ញានេះ ភាគីរដ្ឋនឹងពិចារណាការចូលជាធរមាននូវកិច្ចព្រមព្រៀង ឬការស្រុះស្រួលទ្វេភាគី ឬ ពហុភាគី ទៅលើកិច្ចសហប្រតិបត្តិការដោយផ្ទាល់ រវាង

ភ្នាក់ងារអនុវត្តច្បាប់ និង ការធ្វើវិសោធនកម្មវា នៅកន្លែងណាដែលកិច្ចព្រមព្រៀង ឬ ការសំរុះសំរួល មានរួចជាស្រេច។ ដោយគ្មានការព្រមព្រៀង ឬ សំរុះសំរួល រវាងភាគីរដ្ឋដែលពាក់ព័ន្ធ ភាគីរដ្ឋអាចពិចារណាទៅលើអនុសញ្ញានេះ ដើម្បីជាមូលដ្ឋានសំរាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ទៅវិញទៅមក ចំពោះបទល្មើសដែលគ្រប់ដណ្តប់ដោយអនុសញ្ញានេះ ។ នៅពេលណាមានលក្ខណៈសមស្រប ភាគីរដ្ឋនឹងធ្វើការប្រើប្រាស់កិច្ចព្រមព្រៀង ឬ ការស្រុះស្រួលអោយបានពេលលេញ រួមបញ្ចូលទាំងអង្គការតំបន់ ឬ អង្គការអន្តរជាតិ ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការរវាងភ្នាក់អនុវត្តច្បាប់របស់ខ្លួន ។

៣. ភាគីរដ្ឋ នឹងខិតខំប្រឹងប្រែង ដើម្បីសហប្រតិបត្តិការតាមមធ្យោបាយរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងបទល្មើសដែលគ្របដណ្តប់ដោយអនុសញ្ញានេះ ដោយអនុវត្តតាមរយៈការប្រើបច្ចេកវិទ្យាទំនើប ។

## មាត្រា ៤៩

## ការស៊ើបអង្កេតចំរុះ

ភាគីរដ្ឋនឹងពិចារណាដោយរួមបញ្ចូលកិច្ចព្រមព្រៀង ឬ ការរៀបចំ ទ្វេភាគី ឬ ពហុភាគី ទាក់ទងទៅនឹងបញ្ហាដែលជាកម្មវត្ថុនៃការស៊ើបអង្កេត ការចោទប្រកាន់ ឬ ដំណើរការផ្តែកតុលាការនៅក្នុងរដ្ឋមួយ ឬ ច្រើន អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធអាចបង្កើតអង្គការស៊ើបអង្កេតរួមគ្នា ។ នៅពេលគ្មានកិច្ចព្រមព្រៀង ឬ ការស្រុះស្រួលនោះ ការស៊ើបអង្កេតរួមគ្នា អាចត្រូវបានទទួលរ៉ាប់រងដោយកិច្ចព្រមព្រៀងទៅលើមូលដ្ឋានរឿងក្តីម្តងមួយៗ ។ ភាគីរដ្ឋដែលពាក់ព័ន្ធ នឹងធានាថា អធិបតេយ្យភាពនៃភាគីរដ្ឋដែលនៅក្នុងទឹកដីរបស់ភាគីនោះ ការស៊ើបអង្កេតត្រូវតែធ្វើឡើង ដោយត្រូវបានគេគោរពយ៉ាងពេលលេញ។

## មាត្រា ៥០

## វិធីសាស្ត្រស៊ើបអង្កេតពិសេស

១. ដើម្បីប្រឆាំងនឹងបំពើពុករលួយអោយមានប្រសិទ្ធភាពចំពោះវិសាលភាពដែលអនុញ្ញាតដោយគោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការនៅពេលណាចាំបាច់ តាមមធ្យោបាយរបស់ខ្លួនដើម្បីអោយមានការប្រើប្រាស់ដ៏សមស្របដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួននូវការប្រគល់ដោយមានការឃ្លាំមើល និង ទីកន្លែងដែលចាត់ទុកថាសមស្រប វិធីស៊ើបអង្កេតពិសេស ដូចជា អេឡិចត្រូនិក ឬ ទំរង់ផ្សេងៗនៃការឈ្លបមើល និង ប្រតិបត្តិការ ដែលប្រព្រឹត្តទៅដោយសំងាត់ នៅក្នុងទឹកដីរបស់ខ្លួន និងដើម្បីអោយភស្តុតាងទាំងអស់ដែលប្រមូលមកអាចទទួលយកបាននៅក្នុងតុលាការ ។

២. សំរាប់គោលបំណងនៃការស៊ើបអង្កេតបទល្មើសដែលគ្រប់ដណ្តប់ដោយអនុសញ្ញានេះ ភាគីរដ្ឋទាំងនោះត្រូវបានលើកទឹកចិត្ត នៅពេលណាចាំបាច់ ដើម្បីសំរេចនូវកិច្ចព្រមព្រៀង ឬ ការស្រុះស្រួល ទ្វេរភាគី ឬ ពហុភាគីដែលមានលក្ខណៈសមស្រប សំរាប់ការប្រើប្រាស់វិធីស៊ើបអង្កេតពិសេសក្នុង បរិបទនៃកិច្ចសហប្រតិបត្តិការក៏រិតអន្តរជាតិ ។ កិចច្ចព្រមព្រៀង ឬ ការស្រុះស្រួលទាំងនោះ នឹង ត្រូវបានសំរេច និង អនុវត្តស្របតាមទាំងស្រុងនូវគោលការណ៍ស្មើភាពគ្នារបស់រដ្ឋអធិបតេយ្យ ហើយ នឹងត្រូវបានអនុវត្តយ៉ាងតឹងរឹងដោយស្របទៅតាមបញ្ញត្តិនៃកិច្ចព្រមព្រៀង ឬ ការស្រុះស្រួល នោះ។

៣. ដោយគ្មានការព្រមព្រៀង ឬ ការស្រុះស្រួលគ្នាដូចដែលបានកំណត់នៅក្នុងកថាខណ្ឌ ២ នៃមាត្រានេះ ការសំរេចដើម្បីប្រើវិធីស៊ើបអង្កេតពិសេស នៅក្នុងក៏រិតអន្តរជាតិ នឹងត្រូវបានធ្វើឡើងដោយផ្អែកលើករណីនីមួយៗ ហើយនៅពេលណាចាំបាច់ និងអាចគិតពិចារណានូវការរៀបចំផ្នែក ហិរញ្ញវត្ថុ និងការយល់ដឹងចំពោះការអនុវត្តនៃយុត្តាធិការដោយភាគីរដ្ឋដែលពាក់ព័ន្ធ ។

៤. ការសំរេចដើម្បីប្រើការប្រគល់ដោយមានការឃ្លាំមើលថ្នាក់ក៏រិតអន្តរជាតិ ដោយមានការយល់ព្រមពីភាគីរដ្ឋដែលពាក់ព័ន្ធ អាចសំរេចវិធីសាស្ត្រ ដូចជា ការពួនស្ទាក់ ឬ ការអនុញ្ញាតអោយទំនិញ ឬ មូលនិធិ ចេះតែបន្ត ដោយគ្មានការខូចខាត ឬ ត្រូវបានផ្លាស់ទី ឬ ត្រូវបានជំនួសទាំងស្រុង ឬ មួយ ផ្នែក។

## ជំពូកទី ៥

## ការរកឃើញទ្រព្យ

### មាត្រា ៥១

### បទបញ្ញត្តិទូទៅ

ដោយអនុលោមទៅតាមជំពូកនេះ ការយកទៅវិញនូវទ្រព្យ គឺជាគោលការណ៍សារវន្តនៃអនុសញ្ញានេះ ហើយភាគីរដ្ឋ នឹងរិះរកវិធានការនៃកិច្ចសហប្រតិបត្តិការ និង ជំនួយឧបត្ថម្ភដ៏ទូលំទូលាយមួយផ្សេងទៀត ចំពោះបញ្ហានេះ ។

### មាត្រា ៥២

### ការទប់ស្កាត់ និង ការស៊ើបអង្កេតនូវការផ្ទេរផលនៃបទល្មើស

១. ដោយមិនលំអៀងចំពោះមាត្រា ១៤ នៃអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗ នឹងចាត់វិធានការដែលអាចជាចំបាច់ ដោយស្របទៅតាមច្បាប់ក្នុងស្រុក ដើម្បីតំរូវទៅតាមស្ថាប័នហិរញ្ញវត្ថុនៅក្នុងយុត្តាធិការរបស់ខ្លួន ដើម្បី

បញ្ជាក់អត្តសញ្ញាណរបស់អតិថិជន ដើម្បីចាត់វិធានការសមហេតុផលចំពោះការកំណត់អត្តសញ្ញាណរបស់ម្ចាស់មូលនិធិ ដែលមានផលប្រយោជន៍ ពេលជននោះដាក់ប្រាក់ចូលទៅក្នុងគណនេយ្យដែលមានតំលៃខ្ពស់ និង ដើម្បីអនុវត្តនីការពិនិត្យពិច័យលើគណនេយ្យដែលចង់បាន ឬ ដែលមានរួចហើយ ឬ អ្នកដែលតំណាងដែលត្រូវបានគេទុកចិត្តហើយដែលមានតួនាទី សាធារណៈសំខាន់ និង សមាជិកគ្រួសាររបស់ពួកគេ ព្រមទាំងបក្សពួកជិតស្និទ្ធរបស់ពួកគេផងដែរ ។ ការពិនិត្យ ពិច័យដែលបន្ថែមនោះ នឹងត្រូវបានគ្រោងដោយសមហេតុផល ដើម្បីស៊ើបអង្កេត កិច្ចការ ជំនួញដែលមានការអោយសង្ស័យ ក្នុងគោលបំណងដើម្បីរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង មិនគួរត្រូវបានបកស្រាយ ដែលជាការមិនលើកទឹកចិត្ត ឬ ហាមឃាត់ផ្នែកហិរញ្ញវត្ថុមិនអោយ ធ្វើកិច្ចការជំនួញជាមួយ អតិថិជនត្រឹមត្រូវតាមច្បាប់ ។

២. ដើម្បីសំរួលដល់ការអនុវត្តនូវវិធានការដែលបានចែងនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះដោយស្របទៅនឹងច្បាប់ក្នុងស្រុករបស់ខ្លួន និង ដោយមានការបណ្តុះគំនិត ដែលការផ្តួចផ្តើមរបស់អង្គការថ្នាក់តំបន់ថ្នាក់អន្តរជាតិ និង អង្គការចំរុះដែលពាក់ព័ន្ធក្នុងការប្រឆាំងនឹងការសំអាតប្រាក់ ភាគីរដ្ឋ នីមួយៗ នឹង :

ក- ចេញការណែនាំ ចំពោះប្រភេទនីតិបុគ្គល ឬ រូបវន្តបុគ្គលដែលគណនេយ្យស្ថាប័នហិរញ្ញវត្ថុនៅក្នុងយុត្តាធិការរបស់ខ្លួន នឹងត្រូវបានកំណត់អោយអនុវត្តនូវការពិនិត្យពិច័យ លើរាល់ប្រភេទគណនេយ្យ និង ប្រតិបត្តិការដោយយកចិត្តទុកដាក់ទាំងការបើកគណនេយ្យ ការគ្រប់គ្រង និង វិធានការរក្សារបាយការណ៍ផ្សេងៗលើគណនេយ្យនោះ ព្រមទាំង

ខ- ក្នុងករណីសមស្របត្រូវជូនពត៌មានដល់ស្ថាប័នហិរញ្ញវត្ថុ ដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួនតាមសំណើររបស់ភាគីរដ្ឋផ្សេងទៀតឬទៅតាមគំនិតផ្ទាល់របស់ខ្លួនអំពីអត្តសញ្ញាណរបស់រូបបវន្តបុគ្គល ឬ នីតិបុគ្គលដែលគណនេយ្យរបស់គេត្រូវបានស្ថាបន័ត្រូវបានតំរូវអោយមានការត្រួតពិនិត្យបន្ថែមលើអ្វីដែលស្ថាបន័ហិរញ្ញវត្ថុអាចកំណត់អត្តសញ្ញាណបាន ។

៣. នៅក្នុងបរិបទនៃកថាខណ្ឌ ២ (ក) នៃមាត្រានេះ ភាគីរដ្ឋនីមួយៗ នឹងអនុវត្តវិធានការ ដើម្បីធានា ថាស្ថាប័នហិរញ្ញវត្ថុរបស់ខ្លួន រក្សាឯកសារគណនេយ្យ និងកិច្ចការជំនួយបានគ្រប់គ្រាន់ដែលពាក់ព័ន្ធ នឹងមនុស្សដូចដែលបានចាប់អារម្មណ៍នៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ក្នុងរយៈពេលមួយដ៏សម ស្រប ដែលគួរផ្ទុកនូវពត៌មានអោយបានច្រើនទាក់ទងទៅនឹងអត្តសញ្ញាណនៃអតិថិជន ព្រមទាំងម្ចាស់ផល ប្រយោជន៍។

៤. ដោយមានបំណងទប់ស្កាត់ និងស៊ើបអង្កេត ការផ្ទេរព្រទ្យនៃបទល្មើស ដែលកើតឡើង ដោយអនុលោមតាមអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗ នឹងអនុវត្តវិធានការដ៏មានប្រសិទ្ធភាព និងសម ស្រប ដោយមានការជួយរបស់អង្គការចាត់តាំងគ្រប់គ្រងដើម្បីទប់ស្កាត់ការបង្កើត ធនាគារដែលគ្មានវត្តមានជាក់ស្តែង និង មិនមែន

ជាផ្នែកណាមួយនៃក្រុមហិរញ្ញវត្ថុដែលមានផែលស្ថិត ក្រោមការគ្រប់គ្រង ។ លើសពីនេះទៅទៀត ភាគីរដ្ឋអាចចាត់ទុកតំរូវការវិទ្យាស្ថានហិរញ្ញវត្ថុរបស់គេ ដើម្បី បដិសេធមិនអោយចូល ឬ បន្តនូវការឆ្លើយឆ្លងទំនាក់ទំនងផ្នែកធនាគារ ជាមួយវិទ្យាស្ថាន និង ដើម្បីការពារប្រឆាំងនឹងការបង្កើតទំនាក់ទំនងជាមួយវិទ្យាស្ថានហិរញ្ញវត្ថុបរទេស ដែលអនុញ្ញាត អោយគណនេយ្យរបស់គេ ដើម្បីប្រើប្រាស់ដោយធនាគារដែលគ្មានវត្តមានជាក់ស្តែង និងមិនត្រូវបានរួមបញ្ចូលគ្នាជាមួយក្រុមហិរញ្ញវត្ថុដែលស្ថិតនៅក្រោម ការគ្រប់គ្រង ។

៥. ដោយស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីរដ្ឋនីមួយៗ នឹងពិចារណាទៅលើការបង្កើតប្រព័ន្ធផ្សព្វ ផ្សាយហិរញ្ញវត្ថុដ៏មានប្រសិទ្ធភាព សំរាប់មន្ត្រីសាធារណៈ ហើយ នឹងផ្តល់សំរាប់ការដាក់ទណ្ឌកម្ម ដ៏ត្រឹមត្រូវចំពោះការមិនប្រព្រឹត្តតាម ។ ភាគីរដ្ឋនីមួយៗ នឹងពិចារណាផងដែរក្នុងការចាត់វិធានការ ដែលអាចជាចាំបាច់ដើម្បីអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនចែករំលែកពត៌មានទាំងនោះ ជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងភាគីរដ្ឋដទៃទៀត នៅពេលណាចាំបាច់ត្រូវស៊ើបអង្កេត ប្តឹងផ្តល់ និងរកឃើញផលនៃផលល្មើសដែលបង្កើតឡើង ស្របតាមអនុសញ្ញានេះ ។

៦. ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីរដ្ឋនីមួយៗ នឹងពិចារណាដើម្បីចាត់វិធានការដែល អាចជាចាំបាច់ដើម្បីតំរូវអោយមានមន្ត្រីសាធារណដ៏ត្រឹមត្រូវដែលមានផលប្រយោជន៍ ឬ ហត្ថលេខា ឬ អំណាចផ្សេងទៀតទៅលើគណនេយ្យហិរញ្ញវត្ថុមួយនៅឯបរទេស ដើម្បីរាយការណ៍ ថា ទំនាក់ទំនងចំពោះអាជ្ញាធរត្រឹមត្រូវ និងដើម្បីថែរក្សាឯកសារត្រឹមត្រូវដែលទាក់ទងទៅនឹង គណនេយ្យនោះ ។ វិធានការនោះ នឹងផ្តល់ផងដែរសំរាប់ការដាក់ទណ្ឌកម្មដ៏សមរម្យចំពោះការមិន ប្រព្រឹត្តតាម ។

## មាត្រា ៥៣

## វិធានការសំរាប់ការរកឃើញទ្រព្យដោយផ្ទាល់

ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីរដ្ឋនីមួយៗ នឹង :

ក. ចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយភាគីរដ្ឋដទៃទៀត ដើម្បីផ្តើមធ្វើបណ្តឹងរដ្ឋប្បវេណី នៅក្នុងតុលាការរបស់ខ្លួន ដើម្បីបង្កើតចំណងជើងចំពោះ ឬ ភាពជាកម្មសិទ្ធិនៃទ្រព្យសម្បត្តិដែលទទួលបាន តាមរយៈការប្រព្រឹត្តបទល្មើស ដែលបង្កើតឡើងស្របតាមអនុសញ្ញានេះ ។

ខ. ចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយតុលាការរបស់ខ្លួនបញ្ជាអ្នកដែលប្រព្រឹត្តបទល្មើសទាំងនោះ ដែលបង្កើតឡើងស្របតាមអនុសញ្ញានេះ ដើម្បីសងជំងឺចិត្ត ឬ ការខូចខាតចំពោះភាគីរដ្ឋដទៃទៀតដែលទទួលរងគ្រោះថ្នាក់ដោយបទល្មើសនោះ និង

គ. ចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន នៅពេលណាត្រូវធ្វើការសំរេចចិត្តទៅលើការរឹបអូស ដើម្បីទទួលស្គាល់ការប្តឹងតវ៉ារបស់ភាគីរដ្ឋដទៃទៀតដែលជាម្ចាស់ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់ដែលបង្កើតឡើង ស្របតាមអនុសញ្ញានេះ ។

## មាត្រា ៥៤

## យន្តការសំរាប់ការរកឃើញទ្រព្យសម្បត្តិ តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការរឹបអូស

១. ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ក្នុងគោលបំណងដើម្បីផ្តល់នូវការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ដោយស្របតាមមាត្រា ៥៥ នៃអនុសញ្ញានេះ ចំពោះទ្រព្យសម្បត្តិដែលទទួលបានតាមរយៈ ឬ ដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដែលបង្កើតឡើងដោយអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗ នឹង :

ក. ចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើអោយមានប្រសិទ្ធភាព ចំពោះដីកាបង្គាប់អោយរឹបអូសដែលចេញដោយតុលាការនៃភាគីរដ្ឋដទៃទៀត

ខ. ចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនកន្លែងដែលគេមានយុត្តាធិការ ដើម្បីចេញដីកាបង្គាប់អោយរឹបអូសនូវទ្រព្យសម្បត្តិដែលមានប្រភពនៅបរទេស ដោយការវិនិច្ឆ័យនៃបទល្មើសសំអាតប្រាក់ ឬ បទល្មើសផ្សេងទៀត ដែលអាចមាននៅក្នុងយុត្តាធិការរបស់ខ្លួន ឬ នីតិវិធីផ្សេងទៀតដែលបានផ្តល់អំណាចស្ថិតនៅក្រោមច្បាប់ក្នុងស្រុករបស់ខ្លួន និង

គ. ពិចារណា ដើម្បីចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយរឹបអូសទ្រព្យសម្បត្តិទាំងនោះ ដោយគ្មានការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ នៅក្នុងករណីដែលក្នុងនោះ ជនល្មើសមិនអាចត្រូវបានចោទប្រកាន់ដោយមនុស្សស្លាប់ ដោយការភៀសខ្លួនចេញ ឬ ដោយអវត្តមាន ឬ ក្នុងករណីសមហេតុ សមផលផ្សេងទៀត ។

២. ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួនដើម្បីផ្តល់នូវការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ នៅពេលមានសំណើដែលធ្វើឡើងស្របតាមកថាខណ្ឌ ២ នៃមាត្រា ៥៥ នៃអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗ នឹង :

ក. ចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនធ្វើការរឹបយក ឬ រឹបអូសនូវទ្រព្យសម្បត្តិ នៅពេលដីការឹបយក ឬ រឹបអូសចេញដោយតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីរដ្ឋដាក់សំណើដែលផ្តល់នូវមូលដ្ឋានសមហេតុផលមួយ សំរាប់ភាគីរដ្ឋទទួលសំណើ ដើម្បីជឿថា មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ចាត់វិធានការ ហើយថាទ្រព្យសម្បត្តិនោះគួរជាកម្មវត្ថុ យ៉ាងជាក់លាក់ ចំពោះដីកានៃការរឹបអូសសំរាប់គោលបំណងនៃកថាខណ្ឌ ១ (ក) នៃមាត្រានេះ

ខ. ចាត់វិធានការដែលអាចជាចាំបាច់ ដើម្បីអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ធ្វើការរឹបយក ឬ រឹបអូសនូវទ្រព្យសម្បត្តិ នៅពេលសំណើមួយដែលផ្តល់នូវមូលដ្ឋានសមហេតុផលមួយសំរាប់ភាគីរដ្ឋទទួលសំណើដើម្បីជឿថា មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ចាត់វិធានការ ហើយថាទ្រព្យសម្បត្តិនោះគួរជាកម្មវត្ថុយ៉ាងជាក់លាក់ ចំពោះដីកានៃការរឹបអូសសំរាប់គោលបំណងនៃកថាខណ្ឌ ១ (ក) នៃមាត្រា នេះ និង

គ. ពិចារណាការចាត់វិធានការបន្ថែម ដើម្បីអនុញ្ញាតអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ការពារទ្រព្យសម្បត្តិសំរាប់ការរឹបអូស ដូចជា ផ្អែកលើមូលដ្ឋាននៃការចាប់ជនបរទេស ឬ ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌដែលទាក់ទងទៅនឹងការបានមកនូវទ្រព្យសម្បត្តិ ។

## មាត្រា ៥៥
## កិច្ចសហប្រតិបត្តិការអន្តរជាតិសំរាប់គោលបំណងនៃការរឹបអូស

១. ភាគីរដ្ឋមួយដែលទទួលសំណើមួយពីភាគីរដ្ឋដទៃទៀត ដែលមានយុត្តាធិការគ្រប់ដណ្តប់លើបទល្មើសដែលបានបង្កើតឡើង ដោយស្របទៅតាមអនុសញ្ញានេះ សំរាប់រឹបអូសផលនៃបទល្មើសព្រហ្មទណ្ឌទ្រព្យសម្បត្តិ សំភារៈ ឬឧបករណ៍ផ្សេងៗទៀត ដោយយោងទៅតាមមាត្រា ៣១ កថាខណ្ឌ ១ នៃអនុសញ្ញានេះដែលស្ថិតនៅក្នុងទឹកដីរបស់ខ្លួន ដើម្បីពង្រីកអោយបានទូលំទូលាយដែលអាចធ្វើទៅបាននៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុករបស់ខ្លួននឹង :

ក. ដាក់សំណើជូនទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន សំរាប់គោលបំណងនៃការទទួលដីការឹបអូស និងធ្វើអោយមានប្រសិទ្ធភាពចំពោះវា ប្រសិនបើដីកានោះត្រូវបានគេផ្តល់អោយ ឬ

ខ. ដាក់សំណើជូនអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដោយមានផែនការធ្វើអោយមានប្រសិទ្ធភាពដល់ខ្លួនចំពោះវិសាលភាពដែលបានស្នើឡើង ដីការឹបអូសដែលចេញដោយតុលាការនៅក្នុងទឹកដីនៃភាគីរដ្ឋដាក់សំណើ ដោយយោងទៅតាមមាត្រា ៣១ កថាខណ្ឌ ១ និង មាត្រា៥៤ កថាខណ្ឌ ១ (ក) នៃអនុសញ្ញានេះ គ្រាន់តែទាក់ទងទៅនឹងផលនៃបទឧក្រិដ្ឋ ទ្រព្យសម្បត្តិ ឧបករណ៍ ឬ បរិក្ខាផ្សេងៗទៀត ដោយយោងទៅតាមមាត្រា ៣១ កថាខណ្ឌ ១ ដែលស្ថិតនៅក្នុងទឹកដីនៃភាគីរដ្ឋទទួលសំណើ ។

២. ដាមដានសំណើមួយដែលធ្វើឡើងដោយភាគីរដ្ឋផ្សេងទៀត ដែលមានយុត្តាធិការគ្រប់ដណ្តប់បទល្មើសដែលបង្កើតឡើងស្របទៅតាមអនុសញ្ញានេះ ភាគីរដ្ឋទទួលសំណើ នឹងចាត់វិធានការដើម្បីកំណត់អត្តសញ្ញាណ តាមដាន និង រឹបយក ឬ រឹបអូសទ្រព្យនៃបទឧក្រិដ្ឋ ព្រទ្យសម្បត្តិ ឧបករណ៍ ឬ បរិក្ខាផ្សេងៗទៀត ដោយយោងទៅតាមមាត្រា ៣១ កថាខណ្ឌ ១ នៃអនុសញ្ញានេះ សំរាប់គោលបំណងនៃការរឹបអូសជាយថាហេតុ ដែលត្រូវបានបញ្ជាទាំង ភាគីរដ្ឋដាក់សំណើ ទាំងភាគីរដ្ឋទទួលសំណើ ដោយអនុលោមទៅតាមសំណើមួយដែលមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

៣. បញ្ញត្តិនៃមាត្រា ៤៦ នៃអនុសញ្ញានេះ គឺអនុវត្តបាន រាល់ការផ្លាស់ប្តូរចាំបាច់ដែលធ្វើឡើង ចំពោះមាត្រានេះ ។ ដោយឡែកពត៌មានដែលបានបញ្ជាក់នៅក្នុងមាត្រា៤៦ កថាខណ្ឌ ១៥ សំណើដែលធ្វើឡើងស្របតាមមាត្រានេះត្រូវមាន :

ក. ក្នុងករណីសំណើមួយជាប់ទាក់ទងទៅកថាខណ្ឌ ១ (ក) នៃមាត្រានេះ ការរៀបរាប់ទ្រព្យសម្បត្តិដែលត្រូវរឹបអូសចំពោះវិសាលភាពដែលអាចមាន រួមទាំងទីកន្លែង និង ទីកន្លែងដែលពាក់ព័ន្ធតំលៃនៃទ្រព្យសម្បត្តិដែលប៉ាន់ប្រមាណ និងលិខិតបញ្ជាក់នូវអង្គហេតុដែលសំអាងលើ ដោយភាគីរដ្ឋដាក់សំណើគ្រប់គ្រាន់ដើម្បីអាចអោយភាគីរដ្ឋទទួលសំណើស្វែងរកការបញ្ជាដែលស្ថិតនៅក្រោម ច្បាប់ក្នុងស្រុករបស់ខ្លួន

ខ. ក្នុងករណីសំណើមួយជាប់ទាក់ទងទៅកថាខណ្ឌ ១ (ខ) នៃមាត្រានេះ ការថតចំលងដីការឹបអូសដែលអាចយកជាការបានតាមផ្លូវច្បាប់ ដែលជាមូលដ្ឋាននៃសំណើរសំណើ ចេញដោយភាគីរដ្ឋ ដាក់សំណើលិខិតបញ្ជាក់នូវអង្គហេតុ និងពត៌មាន ដែលជាវិសាលភាពក្នុងការអនុវត្តដីកាដែលបានស្នើឡើង លិខិតបញ្ជាក់មួយដែលបញ្ជាក់អំពីវិធានការដែលធ្វើឡើងដោយភាគីរដ្ឋដាក់សំណើ ដើម្បីផ្តល់នូវ ដំណឹងពិត

ប្រាជកដល់តតិភាគី និងដើម្បីធានានូវដំណើរការក្តី និង លិខិតបញ្ជាក់មួយដែលបញ្ជាក់ថាដីការឹប អូសគឺស្ថាពរ

គ. ក្នុងករណីសំណើមួយជាប់ទាក់ទងទៅកថាខណ្ឌ ២ នៃមាត្រានេះ លិខិតបញ្ជាក់មួយនៃអង្គហេតុដែលផ្អែកទៅលើដោយភាគីរដ្ឋដាក់សំណើ និង ការរៀបរាប់មួយនៃសកម្មភាពដែលបានស្នើឡើង នៅទីកន្លែងដែលអាចរកបាន និង ឯកសារចម្លងដីកាដែលអាចយកជាការបានតាមផ្លូវច្បាប់ ដែលជាមូលដ្ឋាននៃសំណើនោះ ។

៤. សេចក្តីសំរេច ឬ អំពើ ដែលបានចែងនៅក្នុងកថាខណ្ឌ ១ និង ២ នៃមាត្រានេះ នឹងត្រូវបានអនុវត្តដោយភាគីរដ្ឋទទួលសំណើ ដោយយោងទៅតាម និងដែលជាបទបញ្ញត្តិនៃច្បាប់ក្នុងស្រុករបស់ខ្លួន និងវិធាននីតិវិធីរបស់ខ្លួន ឬ កិច្ចព្រមព្រៀង ឬ ការឯកភាពទ្វេភាគី ឬ ពហុភាគីណាមួយ ចំពោះអ្វីដែលជាប់កិច្ចសន្យាក្នុងការទំនាក់ទៅនឹងភាគីរដ្ឋដាក់សំណើ ។

៥. ភាគីរដ្ឋនីមួយៗ នឹងផ្តល់ការថតចំលងនូវច្បាប់ និងគោលការណ៍របស់ខ្លួន ដែលធ្វើអោយមានប្រសិទ្ធភាពចំពោះមាត្រានេះ និង ការផ្លាស់ប្តូរជាយថាហេតុផ្សេងៗទៀត ចំពោះច្បាប់ និងបទបញ្ជាទាំងនោះ ឬការអធិប្បាយចំពោះអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៦. ប្រសិនបើភាគីរដ្ឋមួយជ្រើសរើសដើម្បីធ្វើការចាត់វិធានការ ដោយយោលទៅតាមកថាខណ្ឌ ១ និង ២ នៃមាត្រានេះ ដោយមានលក្ខខណ្ឌផ្អែកទៅលើការមានសន្ធិសញ្ញាដែលពាក់ព័ន្ធ ភាគីរដ្ឋនោះ នឹងពិចារណាអនុសញ្ញានេះ ទៅលើភាពចាប់បាច់ និង មូលដ្ឋានសន្ធិសញ្ញាអោយបានត្រឹមត្រូវ ។

៧. កិច្ចសហប្រតិបត្តិការនៅក្រោមមាត្រានេះ អាចត្រូវបានបដិសេធផងដែរ ឬ ជាវិធានការបណ្តោះអាសន្នដែលបានលើកឡើង ប្រសិនបើភាគីរដ្ឋទទួលសំណើ មិនព្រមទទួលនូវភស្តុតាងអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា ឬ ប្រសិនបើទ្រព្យសម្បត្តិនោះ គឺ មានតំលៃទាបបំផុត ។

៨. មុនពេលលើកឡើងវិធានការបណ្តោះអាសន្នណាមួយដែលបានធ្វើឡើង ដោយស្របទៅនឹងមាត្រានេះ ភាគីរដ្ឋទទួលសំណើ នៅទីកន្លែងណាដែលអាចធ្វើទៅបាន នឹងផ្តល់ឱកាសអោយភាគីរដ្ឋដាក់សំណើ ដើម្បីបង្ហាញហេតុផលរបស់ខ្លួនដោយយល់ស្របទៅនឹងការបន្តវិធានការ ។

៩. បទបញ្ញត្តិនៃមាត្រានេះ នឹងមិនត្រូវបានបកស្រាយដែលជាការលំអៀងសិទ្ធិរបស់តតិភាគីដោយសុច្ឆរិតនោះទេ ។

## មាត្រា ៥៦
## កិច្ចសហប្រតិបត្តិការពិសេស

ដោយមិនលំអៀងចំពោះច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីរដ្ឋនីមួយៗ នឹងខិតខំដើម្បីចាត់វិធានការបញ្ជូន ដោយគ្មានលំអៀងចំពោះការស៊ើបអង្កេត ការចោទប្រកាន់ ឬ ដំណើរការផ្តែកតុលាការផ្ទាល់ខ្លួន ពត៌មានស្តីពីផលនៃបទល្មើសដែលបង្កើតឡើងដោយអនុលោមទៅតាមអនុសញ្ញានេះ ចំពោះភាគីដទៃទៀត ដោយគ្មានសំណើពីមុនមក នៅពេលដែលវាពិចារណាថា ការផ្សាយនូវពត៌មានទាំងនោះ អាចជួយភាគីរដ្ឋទទួល ក្នុងការផ្តួចផ្តើម ឬ អនុវត្តការស៊ើបអង្កេត ការចោទប្រកាន់ ឬ ដំណើរការផ្តែកតុលាការ ឬ អាចឈានទៅរកសំណើមួយដោយភាគីរដ្ឋនោះ ស្ថិតនៅក្រោមជំពូកនេះនៃអនុសញ្ញា ។

## មាត្រា ៥៧
## ការបញ្ជូនត្រឡប់ និង ការចំណាយទ្រព្យ

១. ដោយអនុលោមទៅតាមមាត្រា ៣១ និង ៥៥ នៃអនុសញ្ញានេះ ទ្រព្យសម្បត្តិដែលរឹបអូសបានដោយភាគីរដ្ឋមួយ នឹងត្រូវចំណាយ ដោយភាគីរដ្ឋនោះស្របទៅនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ និងច្បាប់ក្នុងស្រុករបស់ខ្លួន ដោយរួមបញ្ចូលទាំងការបញ្ជូនត្រឡប់ទៅកាន់ម្ចាស់ស្របច្បាប់ពីមុនរបស់គេ ដោយស្របទៅតាមកថាខណ្ឌ ៣ នៃមាត្រានេះ ។

២. ដោយស្របទៅតាមគោលការណ៍ជាសារវ័ន្តនៃច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីរដ្ឋនីមួយៗ នឹងអនុម័តច្បាប់ និងវិធានការផ្សេងៗទៀតដែលអាចជាចំបាច់ដើម្បីជួយអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនបញ្ជូនត្រឡប់ទៅវិញនូវទ្រព្យដែលរឹបអូសបាន ដោយស្របតាមអនុសញ្ញានេះ នៅពេលដែលការធ្វើតាមសំណើដែលធ្វើឡើងដោយភាគីរដ្ឋដទៃទៀត ក្នុងការលើកឡើងពិចារណានូវសិទ្ធិរបស់តតិភាគីដោយត្រឹមត្រូវ ។

៣. ដោយអនុលោមទៅតាមមាត្រា ៤៦ និង ៥៥ នៃអនុសញ្ញានេះ និង កថាខណ្ឌ ១ និង ២ នៃមាត្រានេះ ភាគីរដ្ឋទទួលសំណើនឹង :

ក. ក្នុងករណីមានការបន្លំលួចមូលនិធិសាធារណៈ ឬ លាងមូលនិធិសាធារណៈដែលលួចបន្លំបាន ដោយយោងទៅតាមមាត្រា ១៧ និង ២៣ នៃអនុសញ្ញានេះ នៅពេលណា ការរឹបអូសទ្រព្យត្រូវបានអនុវត្តស្របតាមមាត្រា ៥៥ និងដោយផ្អែកលើមូលដ្ឋាននៃការវិនិច្ឆ័យចុងក្រោយនៅក្នុងភាគីរដ្ឋដាក់សំណើ តំរូវការមួយដែលអាចត្រូវបានបដិសេធដោយភាគីរដ្ឋទទួលសំណើ ការបញ្ជូនត្រឡប់នូវទ្រព្យសម្បត្តិដែលរឹបអូសបានទៅអោយភាគីរដ្ឋដាក់សំណើវិញ

ខ. ក្នុងករណីផលនៃបទល្មើសផ្សេងទៀតដែលមានចែងក្នុងអនុសញ្ញានេះ នៅពេលណា ការរឹបអូសត្រូវបានគេធ្វើឡើង ដោយអនុលោមទៅតាម មាត្រា ៥៥ នៃអនុសញ្ញានេះ និងដោយផ្អែកលើមូលដ្ឋាននៃការវិនិច្ឆ័យចុងក្រោយ នៅក្នុងភាគីរដ្ឋដាក់សំណើ តំរូវការមួយដែលអាចត្រូវបានបដិសេធដោយភាគីរដ្ឋទទួលសំណើ ការបញ្ជូនត្រឡប់នូវទ្រព្យសម្បត្តិដែលរឹបអូសបានទៅអោយភាគីរដ្ឋដាក់សំណើ នៅពេលដែលភាគីរដ្ឋកំណត់បាននូវម្ចាស់ដើមនៃព្រទ្យសម្បត្តិរបស់គេចំពោះភាគី រដ្ឋទទួលសំណើ ឬ នៅពេលដែលភាគីរដ្ឋទទួលសំណើទទួលស្គាល់ការខូចខាត ចំពោះភាគីរដ្ឋដាក់ សំណើដែលជាមូលដ្ឋានសំរាប់ការបញ្ជូនត្រឡប់នូវទ្រព្យសម្បត្តិដែលរឹបអូសបាន

គ. នៅក្នុងករណីផ្សេងៗជាច្រើនទៀត ការបញ្ជូនត្រឡប់នូវទ្រព្យសម្បត្តិទាំងនោះទៅអោយម្ចាស់ដើមត្រឹមត្រូវតាមច្បាប់របស់គេ ឬ ការសងការខូចខាតដល់ជនរងគ្រោះនៃបទឧក្រិដ្ឋ ផ្តល់តំលៃតបស្នងជាអាទិភាពចំពោះការបញ្ជូនត្រឡប់នូវទ្រព្យសម្បត្តិដែលរឹបអូសបាន ទៅអោយភាគីរដ្ឋដាក់សំណើវិញ ។

៤. ប្រសិនបើភាគីរដ្ឋមិនបានសំរេចដូច្នោះទេ នៅពេលមានទីកន្លែងសមស្រប ភាគីរដ្ឋទទួលសំណើអាចដកចេញនូវការចំណាយដែលជាប់ទាក់ទិនក្នុងការស៊ើបអង្កេត ការចោទប្រកាន់ ឬ ដំណើរការផ្នែកតុលាការ ដែលឈានទៅដល់ការបញ្ជូនត្រឡប់ ឬ ការចំណាយនូវទ្រព្យសម្បត្តិដែលរឹបអូសដោយអនុលោមទៅតាមមាត្រានេះ ។

៥. ភាគីរដ្ឋអាចផ្តល់នូវតំលៃតបស្នងពិសេសផងដែរ នៅពេលមានទីកន្លែងសមស្រប ចំពោះការរួមបញ្ចូលនូវកិច្ចព្រមព្រៀង ឬ ការស្រុះស្រួលគ្នាដែលអាចទទួលយកបានទៅវិញទៅមក ទៅតាមករណីនីមួយៗ សំរាប់ការចំណាយចុងក្រោយនៃទ្រព្យសម្បត្តិដែលរឹបអូសបាន ។

## មាត្រា ៥៨

## អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

ភាគីរដ្ឋនឹងសហប្រតិបត្តិការជាមួយភាគីរដ្ឋមួយផ្សេងទៀត សំរាប់គោលបំណងដើម្បីទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងទៅនឹងការផ្ទេរទ្រព្យនៃបទឧក្រិដ្ឋ ដែលបានបង្កើតឡើងស្របតាមអនុសញ្ញានេះ និង ជួយជំរុញអោយមានផ្លូវ និងមធ្យោបាយនៃការរកឃើញទ្រព្យ និងនៅទីបញ្ចប់នោះ នឹងចាត់ទុកថា ការបង្កើតអង្គភាពស៊ើបអង្កេតហិរញ្ញវត្ថុមួយ សំរាប់ទទួលខុសត្រូវចំពោះការទទួល ការវិភាគ និង ការចែកចាយ នូវរបាយការណ៍នៃកិច្ចការជំនួញផ្នែកហិរញ្ញវត្ថុដែលមានការសង្ស័យរបស់អាជ្ញាធរមានសមត្ថកិច្ច ។

## មាត្រា ៥៩

## កិច្ចព្រមព្រៀង និង ការសំរុះសំរួលទ្វេភាគី និង ពហុភាគី

ភាគីរដ្ឋ នឹងពិចារណា ការសំរេចនូវកិច្ចព្រមព្រៀង ឬ ការសំរុះសំរួលទ្វេភាគី ឬ ពហុភាគី ដើម្បីលើកកំពស់ភាពមានប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិដែលធ្វើឡើងដោយស្របទៅតាមជំពូកនេះនៃអនុសញ្ញា ។

# ជំពូក ៦

# ជំនួយបច្ចេកទេស និង ការផ្លាស់ប្តូរព័ត៌មាន

## មាត្រា ៦០

## ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាល

១. ចំពោះវិសាលភាពចាំបាច់ ភាគីរដ្ឋនីមួយៗ នឹងផ្តួចផ្តើមគំនិត អភិវឌ្ឍន៍ ឬ បង្កើនកម្មវិធីបណ្តុះបណ្តាលជាក់លាក់សំរាប់បុគ្គលិករបស់ខ្លួនដែលទទួលខុសត្រូវចំពោះការទប់ស្កាត់ និង ការប្រយុទ្ធប្រឆាំងនឹង អំពើពុករលួយ ។ កម្មវិធីបណ្តុះបណ្តាលទាំងនោះ អាចទាក់ទងជាមួយផ្នែកជាច្រើន ក្នុងចំណោមផ្នែក ទាំងនោះដូចតទៅនេះ :

ក. វិធានការដ៏មានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ ស៊ើបសួរ ស៊ើបអង្កេត ដាក់ទណ្ឌកម្ម និង ត្រួតពិនិត្យអំពើពុករលួយ រួមទាំងការប្រើប្រាស់ការប្រមូលភស្តុតាង និងវិធិសាស្ត្រស៊ើបអង្កេត

ខ. ការកសាងសមត្ថភាពក្នុងការអភិវឌ្ឍន៍ និង ការរៀបចំផែនការគោលនយោបាយជាយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ

គ. បណ្តុះបណ្តាលអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំសំណើសំរាប់ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ដែលធ្វើតាមតំរូវការនៃអនុសញ្ញានេះ

ឃ. ការវាយតំលៃ និង ការពង្រឹងស្ថាប័ន ការរៀបចំសេវាកម្មសាធារណៈ និង ការចាត់ចែងហិរញ្ញវត្ថុសាធារណៈ រួមទាំងការជួយផ្នែកសាធារណៈ និង ផ្នែកឯកជន

ង. ការទប់ស្កាត់ និង ការប្រយុទ្ធប្រឆាំងទៅនឹងការផ្ទេរផលនៃបទល្មើស ដែលបង្កើតឡើងដោយស្របទៅតាមអនុសញ្ញានេះ និង ការរកឃើញទ្រព្យសម្បត្តិទាំងនោះ

ច. ការស៊ើបការណ៍ និង ការរឹបយកនូវការផ្ទេរផលនៃបទល្មើស ដែលបង្កើតឡើងដោយស្របទៅតាមអនុសញ្ញានេះ

ឆ. ការឃ្លាំមើលដោយប្រុងប្រយ័ត្ននូវចលនាផលនៃបទល្មើសដែលបង្កើតឡើង ដោយស្របទៅតាមអនុសញ្ញានេះ និងវិធីសាស្ត្រដែលប្រើដើម្បីផ្ទេរ លាក់ ឬ បិទបាំងនូវទ្រព្យនោះ

ជ. យន្តការរដ្ឋបាលដែលមានប្រសិទ្ធិភាព និង ស្របច្បាប់រួមទាំង វិធីសាស្ត្រសំរាប់ការសំរួលដល់ការបញ្ជូនត្រឡប់ទៅវិញនូវផលនៃបទល្មើសដែលបង្កើតឡើង ដោយស្របទៅតាមអនុសញ្ញានេះ

ឈ. វិធីសាស្ត្រដែលបានប្រើក្នុងការការពារជនរងគ្រោះ និង សាក្សីដែលសហប្រតិបត្តិការជាមួយមន្ត្រីយុត្តិធមិនិង

ញ. ការបណ្តុះបណ្តាលបទបញ្ជា និង ភាសា ថ្នាក់ជាតិ និង អន្តរជាតិ ។

២. ដោយស្របទៅតាមសមត្ថភាពរបស់គេ ភាគីរដ្ឋ នឹងពិចារណាក្នុងការស្វះស្វែងរកវិធានការជំនួយបច្ចេកទេសមួយដ៏ទូលំទូលាយបំផុត ជាពិសេសសំរាប់ផលប្រយោជន៍ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងផែនការ និងកម្មវិធីរៀង១ខ្លួនរបស់ពួកគេ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រួមទាំងការគាំទ្រផ្នែក សំភារៈ និង ការបណ្តុះបណ្តាលក្នុងផ្នែកជាច្រើនដោយយោងទៅតាម កថាខណ្ឌ ១ នៃមាត្រានេះ និង ការបណ្តុះបណ្តាល និង ជំនួយ និង ការផ្លាស់ប្តូរទៅវិញទៅមកនូវបទពិសោធន៍ដែលពាក់ព័ន្ធ និង ចំណេះដឹងជំនាញដែលនឹងសំរួលដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងភាគីរដ្ឋក្នុងផ្នែកបត្យាប័ន និង ការជួយ គ្នាទៅវិញទៅមកផ្នែកច្បាប់ ។

៣. ចំពោះវិសាលភាពដ៏ចាំបាច់ ភាគីរដ្ឋ នឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកសកម្មភាពបណ្តុះបណ្តាល និងប្រតិបត្តិការនៅក្នុងអង្គការជាតិ និងអន្តរជាតិ និងនៅក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀង ឬការស្រុះ ស្រួលទ្វេភាគី និងពហុភាគីដែលពាក់ព័ន្ធ ។

៤. ភាគីរដ្ឋ នឹងពិចារណាការជួយមួយផ្សេងទៀត លើសំណើ ក្នុងការអនុវត្តការវាយតំលៃ ការសិក្សា និង ការស្រាវជ្រាវដែលទាក់ទងទៅនឹងប្រភេទ បុព្វហេតុ ផលប៉ះពាល់ និងតំលៃនៃអំពើពុករលួយ នៅក្នុងប្រទេស រៀង១ខ្លួនរបស់គេ ជាមួយផែនការនៃការអភិវឌ្ឍន៍ ជាមួយនិងការចូលរួមរបស់អាជ្ញាធរមាន សមត្ថកិច្ច និង សង្គម យុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីប្រឆាំងនឹងអំពើពុករលួយ ។

៥. ដើម្បីសំរួលដល់ការរកឃើញនូវផលនៃបទល្មើសដែលបង្កើតឡើងស្របតាមអនុសញ្ញានេះ ភាគីរដ្ឋអាចសហ ប្រតិបត្តិការក្នុងការផ្តល់អោយគ្នាទៅវិញទៅមកនូវឈ្មោះអ្នកជំនាញដែលអាចជួយក្នុងការសំរេច គោលបំណង នោះ ។

៦. ភាគីរដ្ឋ នឹងពិចារណាការប្រើប្រាស់សន្និសីទ និង សិក្ខាសាលាថ្នាក់អនុតំបន់ តំបន់ និងអន្តរជាតិ ដើម្បី បង្កើនកិច្ចសហប្រតិបត្តិការ និងជំនួយបច្ចេកទេស និង ដើម្បីធ្វើអោយមានកាន់តែច្រើនឡើងនូវការ ពិភាក្សា ស្តីពីបញ្ហានៃការព្រួយបារម្ភទៅវិញទៅមក រួមទាំងកម្មវិធីពិសេស និងសេចក្តីត្រូវការរបស់ ប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសដែលមានការប្រែប្រួលខាងសេដ្ឋកិច្ច ។

៧. ភាគីរដ្ឋ នឹងពិចារណានូវការបង្កើតយុទ្ធការស្ម័គ្រចិត្ត ជាមួយនឹងផែនការដើម្បីចែកចាយជាហិរញ្ញវត្ថុទៅ ដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសដែលមានការប្រែប្រួលខាងសេដ្ឋកិច្ច ដើម្បីអនុវត្ត អនុសញ្ញានេះ តាមរយៈ កម្មវិធី និងគំរោងជំនួយបច្ចេកទេស ។

៨. ភាគីរដ្ឋនីមួយ១ នឹងពិចារណា ដើម្បីធ្វើការចែកចាយដោយស្ម័គ្រចិត្តទៅដល់ការិយាល័យរបស់អង្គការ សហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្ម និង គ្រឿងញៀន សំរាប់គោលបំណងក្នុងការជំរុញអោយមានការរីក ចំរើន តាមរយៈ ការិយាល័យកម្មវិធី និង គំរោងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាមួយនឹងផែនការ ដើម្បីអនុវត្តអនុ សញ្ញានេះ ។

## មាត្រា ៦១

## ការប្រមូល ការផ្លាស់ប្តូរ និង ការវិភាគពត៌មាន ស្តីអំពីអំពើពុករលួយ

១. ភាគីរដ្ឋនីមួយៗ នឹងពិចារណាទៅលើ ការវិភាគ ការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និន្នាការនៅក្នុងអំពើពុករលួយក្នុងដែនដីរបស់ខ្លួន ព្រមទាំងកាលៈទេសៈដែលក្នុងនោះ បទល្មើសអំពើពុករលួយត្រូវបានប្រព្រឹត្ត ។

២. ភាគីរដ្ឋ នឹងពិចារណាទៅលើការអភិវឌ្ឍន៍ និងការចែករំលែកគ្នាទៅវិញទៅមកនិង តាមរយៈស្ថិតិ របស់អង្គការតំបន់ និង អន្តរជាតិ កោសល្យវិច័យវិភាគដែលពាក់ព័ន្ធនឹងអំពើពុករលួយ និងពត៌មានជាមួយនឹងផែនការដើម្បីអភិវឌ្ឍន៍ និយមន័យរួម គំរូ និង វិធីសាស្ត្រ ត្រឹមតែលទ្ធភាពដែលអាចធ្វើបាន ព្រមទាំងពត៌មានស្តីពីការអនុវត្តដ៏ល្អបំផុត ដើម្បីទប់ស្កាត់ និង ប្រឆាំងអំពើពុករលួយ ។

៣. ភាគីរដ្ឋនីមួយៗ នឹងពិចារណាទៅលើការត្រួតពិនិត្យនូវគោលនយោបាយរបស់ខ្លួន និង វិធានការពិតប្រាដក ដើម្បីប្រឆាំងអំពើពុករលួយ និង ធ្វើការវាយតំលៃនូវភាពមានប្រសិទ្ធភាព និង ភាពផ្តល់អោយនូវផលល្អរបស់ខ្លួន ។

## មាត្រា ៦២

## វិធានការដទៃទៀត : ការអនុវត្តអនុសញ្ញា តាមរយៈការអភិវឌ្ឍន៍សេដ្ឋកិច្ច និងជំនួយបច្ចេកទេស

១. ភាគីរដ្ឋ នឹងចាត់វិធានការ ដោយបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តអនុសញ្ញានេះយ៉ាងល្អប្រសើ ដើម្បីពង្រីកតាមលទ្ធភាពដែលអាចធ្វើបានតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ការលើកឡើងពីផលប៉ះពាល់អវិជ្ជមាននៃអំពើពុករលួយទៅលើសង្គមជាទូទៅ ហើយជាពិសេស ទៅលើការអភិវឌ្ឍន៍ដែលអាចទ្រទ្រង់បាន ។

២. ភាគីរដ្ឋ នឹងធ្វើការខិតខំប្រឹងប្រែងយ៉ាងច្បាស់លាស់ ទៅលើវិសាលភាពដែលមាន និង ក្នុងកិច្ចសំរបសំរួលជាមួយភាគីរដ្ឋដទៃទៀត ព្រមទាំងជាមួយអង្គការអន្តរជាតិ និងតំបន់:

ក. ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការនៅគ្រប់កំរិតផ្សេងៗ ជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការពង្រឹងសមត្ថភាពដើម្បីទប់ស្កាត់ និង ប្រឆាំងអំពើពុករលួយ

ខ. ដើម្បីលើកកំពស់ផ្នែកជំនួយហិរញ្ញវត្ថុ និងសំភារៈ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយអោយមានប្រសិទ្ធភាព និងជួយអោយពួកគេអនុវត្តអនុសញ្ញានេះដោយជោគជ័យ

គ. ដើម្បីផ្តល់ជំនួយបច្ចេកទេសទៅដល់ប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសដែលមានការប្រែប្រួលខាងសេដ្ឋកិច្ចដើម្បីជួយពួកគេក្នុងការជួបប្រទះនូវភាពចាំបាច់របស់គេ សំរាប់ការអនុវត្តនៃអនុសញ្ញានេះ។ ដើម្បីបញ្ចប់បញ្ហានោះ ភាគីរដ្ឋ នឹងខ្នះខ្នែងដើម្បីធ្វើអោយបានគ្រប់គ្រាន់ និង ទៀងទាត់នូវការជួយឧបត្ថម្ភដោយស្ម័គ្រចិត្ត ចំពោះគណនេយ្យដែលបានបង្កើតឡើងយ៉ាងជាក់លាក់ សំរាប់គោលបំណងនោះ នៅក្នុងយន្តការមូលនិធិរបស់អង្គការសហប្រជាជាតិ ។ ដោយយោងទៅតាមច្បាប់ក្នុងស្រុករបស់គេ និង បទបញ្ញត្តិនៃអនុសញ្ញានេះ ភាគីរដ្ឋអាចផ្តល់តំលៃតបស្នងពិសេសផងដែរ ដើម្បីធ្វើការចែកចាយទៅដល់គណនេយ្យនោះនូវភាគរយនៃលុយ ឬ ការទាក់ទងតំលៃនៃផលឧក្រិដ្ឋ ឬទ្រព្យសម្បត្តិដែលរឹបអូសបាន ដោយស្របទៅតាមបទបញ្ញត្តិនៃអនុសញ្ញានេះ

ឃ. ដើម្បីលើកទឹកចិត្ត និងបញ្ចុះបញ្ចូលភាគីរដ្ឋផ្សេងៗទៀត និង ស្ថាប័នហិរញ្ញវត្ថុដែលមានលក្ខណៈសមស្រប ដើម្បីចូលរួមជាមួយពួកគេក្នុងកិច្ចខិតខំប្រឹងប្រែងដោយស្របទៅតាមមាត្រានេះ ជាពិសេសដោយ ផ្តល់កម្មវិធីបណ្តុះបណ្តាល និងបច្ចេកទេសទំនើបបន្ថែមទៀត ដល់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីជួយ ពួកគេក្នុងការសំរេចនូវវត្ថុបំណងនៃអនុសញ្ញានេះ ។

៣ តាមដែលអាចធ្វើទៅបាន វិធានការទាំងនេះ នឹងមិនត្រូវលំអៀងចំពោះការមានការប្តេជ្ញា ចិត្តផ្នែកជំនួយបរទេស ឬ ចំពោះការស្រុះស្រួលគ្នាក្នុងកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ នៅក្នុងកំរិតទ្វេភាគី តំបន់ ឬ អន្តរជាតិ ។

៤. ភាគីរដ្ឋអាចបញ្ចប់កិច្ចព្រមព្រៀង ឬ ការសំរុះសំរួលទ្វេភាគី ឬ ពហុភាគី ទៅលើ សំភារៈ និងជំនួយសមហេតុផល ដើម្បីធ្វើការពិចារណាភាពចាំបាច់ក្នុងការរៀបចំផ្នែកហិរញ្ញវត្ថុ សំរាប់មធ្យោបាយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិដែលបានផ្តល់អោយដោយអនុសញ្ញានេះ ដើម្បីធ្វើអោយមានប្រសិទ្ធភាព និងសំរាប់ទប់ស្កាត់ ស៊ើបអង្កេត និង ត្រួតពិនិត្យអំពើពុករលួយ ។

# ជំពូក ៧

# យន្តការសំរាប់ការអនុវត្ត

## មាត្រា ៦៣

## សន្និសីទរបស់ភាគីរដ្ឋចំពោះអនុសញ្ញា

១. សន្និសីទរបស់ភាគីរដ្ឋចំពោះអនុសញ្ញា ត្រូវបានបង្កើតឡើង ដើម្បីបង្កើនសមត្ថភាពនៃកិច្ចសហប្រតិបត្តិការរវាងភាគីរដ្ឋ ដើម្បីសំរេចបាននូវវត្ថុបំណងដែលបានបង្កើតឡើងនៅក្នុងអនុសញ្ញានេះ និងដើម្បីជំរុញ និងពិនិត្យឡើងវិញនូវការអនុវត្តច្បាប់ ។

២. អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ នឹងកោះប្រជុំសន្និបាតរបស់ភាគីរដ្ឋ មិនអោយយឺតជាងមួយឆ្នាំបន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ ។ ហេតុដូច្នេះហើយ កិច្ចប្រជុំជាទៀតទាត់នៃសន្និសីទរបស់ភាគីរដ្ឋ នឹងធ្វើឡើងដោយស្របទៅតាមវិធាននៃនីតិវិធីដែលបានអនុម័តដោយសន្និសីទ ។

៣. សន្និសីទរបស់ភាគីរដ្ឋ នឹងអនុម័តវិធាននៃនីតិវិធី និង វិធានគ្រប់គ្រងមុខងាររបស់សកម្មភាពដែលបង្កើតនៅក្នុងមាត្រានេះ រួមបញ្ចូលទាំងវិធានដែលពាក់ព័ន្ធផ្នែកតំលៃ និង ការចូលរួមរបស់អ្នកអង្កេតការណ៍ និងថ្លៃចំណាយ ដែលកើតឡើងក្នុងការអនុវត្តសកម្មភាពទាំងនោះ ។

៤. ដើម្បីសំរេចបាននូវវត្ថុបំណងដែលបានបង្កើតឡើងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ សន្និសីទរបស់ភាគីរដ្ឋ នឹងយល់ព្រមទៅលើសកម្មភាព នីតិវិធី និង វិធីសាស្ត្រការងារ រួមមានដូចតទៅ:

ក. ការសំរួលសកម្មភាព ដោយភាគីរដ្ឋនៅក្រោមមាត្រា ៦០ និង ៦២ និង ជំពូក ២ ដល់ជំពូក ៥ នៃអនុសញ្ញានេះ ការរួមបញ្ចូនដោយមានការលើកទឹកចិត្តដល់ការរួមរួមក្នុងការជួយឧបត្ថម្ភដោយស្ម័គ្រចិត្ត

ខ. ការសំរួលដល់ការផ្លាស់ប្តូរពត៌មាន ក្នុងចំណោមភាគីរដ្ឋ ស្តីអំពីភាពគំរូ និង និន្នាការក្នុងអំពើពុករលួយ និង ស្តីអំពីការអនុវត្តដែលទទួលជោគជ័យ សំរាប់ការទប់ស្កាត់ និង ការប្រឆាំងអំពើពុករលួយ និងសំរាប់ការបញ្ជូនត្រឡប់វិញនូវផលនៃបទឧក្រិដ្ឋ តាមរយៈក្នុងចំណោម ការបោះពុម្ពផ្សាយពត៌មានដែលពាក់ព័ន្ធដូចដែលបានចាប់អារម្មណ៍នៅក្នុងមាត្រានេះ

គ. ការសហប្រតិបត្តិការជាមួយអង្គការតំបន់ និង អន្តរជាតិដែលពាក់ព័ន្ធ និងយន្តការ និង អង្គការមិនមែនរដ្ឋាភិបាល

ឃ. ធ្វើការប្រើប្រាស់អោយបានសមស្របនូវពត៌មានពាក់ព័ន្ធដែលផលិតឡើងដោយយន្តការតំបន់ និង អន្តរជាតិផ្សេងទៀត សំរាប់ការប្រឆាំង និងទប់ស្កាត់អំពើពុករលួយ ដើម្បីបញ្ចៀសការងារឌុបដែល មិនចាំបាច់

ង. ការពិនិត្យឡើងវិញ យូរៗម្តង នូវការអនុវត្តនៃអនុសញ្ញានេះ ដោយភាគីរដ្ឋរបស់ខ្លួន

ច. ការធ្វើអនុសាសន៍ ដើម្បីកែលំអអនុសញ្ញានេះ និង ការអនុវត្តរបស់គេ

ឆ. ធ្វើការកត់សំគាល់នូវតំរូវការជំនួយបច្ចេកទេសរបស់ភាគីរដ្ឋ ចំពោះការអនុវត្តអនុសញ្ញានេះ និង ការ អោយអនុសាសន៍នូវអំពើណាមួយ វាអាចចាត់ទុកថាជាចាំបាច់ នៅក្នុងប្រការនោះ ។

៥. សំរាប់គោលបំណងនៃកថាខណ្ឌ ៤ នៃមាត្រានេះ សន្និសីទរបស់ភាគីរដ្ឋ នឹងទទួលបានចំណេះដឹងចាំបាច់សំរាប់ ភាគីរដ្ឋចាត់វិធានការក្នុងការអនុវត្តអនុសញ្ញានេះ និង ការលំបាកដែលបានជួបប្រទះដោយពួកគេ និង ក្នុងការធ្វើអ្វី ផ្សេងៗទៀត តាមរយៈពត៌មានដែលផ្តល់អោយដោយពួកគេ និង តាមរយៈយន្តការ ពិនិត្យឡើងវិញដោយបន្ថែម ដែលអាចត្រូវបានបង្កើតឡើងដោយសន្និសីទរបស់ភាគីរដ្ឋ ។

៦. ភាគីរដ្ឋនីមួយៗ នឹងផ្តល់ជូនសន្និសីទរបស់ភាគីរដ្ឋនូវពត៌មានស្តីអំពីកម្មវិធី ផែនការ និង ការអនុវត្ត របស់ខ្លួន ព្រមទាំងស្តីអំពីវិធានការរដ្ឋបាល និង នីតិបញ្ញត្តិ ដើម្បីអនុវត្តអនុសញ្ញានេះ ដូចដែលតំរូវអោយមាននៅក្នុង សន្និសីទរបស់ភាគីរដ្ឋ ។ សន្និសីទរបស់ភាគីរដ្ឋ នឹងត្រួតពិនិត្យមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតនៃការទទួល និង ការធ្វើសកម្មភាពទៅលើពត៌មានរួមទាំង ក្នុងចំណោមពត៌មាន ដែលទទួលបានពីភាគីរដ្ឋ និង ពីអង្គការអន្តរជាតិ មានសមត្ថកិច្ច។ ទិន្នន័យដែលទទួលបានពីអង្គការ ក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធដែលបានបញ្ចូលយ៉ាងត្រឹមត្រូវ ស្របទៅតាមនីតិវិធីដែលបានសំរេចដោយ សន្និសីទរបស់ភាគីរដ្ឋ អាចត្រូវបានគេពិចារណាផងដែរ ។

៧. ដោយអនុលោមតាមកថាខណ្ឌ ៤ ដល់ ៦ នៃមាត្រានេះ ប្រសិនបើយល់ឃើញថាចាំបាច់ សន្និសីទ របស់ភាគីរដ្ឋ នឹងបង្កើតយន្តការ ឬ អង្គការ សមស្របណាមួយ ដើម្បីជួយក្នុងការអនុវត្តអនុសញ្ញានេះ អោយមានប្រសិទ្ធភាព ។

## មាត្រា ៦៤

## លេខាធិការដ្ឋាន

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ នឹងផ្តល់សេវាលេខាធិការដ្ឋានចាំបាច់ ដល់សន្និសីទរបស់ភាគីរដ្ឋ ចំពោះអនុសញ្ញានេះ។

២. លេខាធិការដ្ឋាន នឹង :

ក. ជួយសន្និសីទរបស់ភាគីរដ្ឋក្នុងការអនុវត្តសកម្មភាពដែលបានបង្កើតឡើងនៅក្នុងមាត្រា ៦៣ នៃអនុសញ្ញានេះ និង ធ្វើការរៀបចំ និង ផ្តល់សេវាកម្មចាំបាច់ សំរាប់សម័យប្រជុំសន្និសីទរបស់ភាគីរដ្ឋ

ខ. នៅពេលមានសំណើ លេខាធិការដ្ឋាន នឹងជួយភាគីរដ្ឋ ក្នុងការផ្តល់ពត៌មានទៅអោយសន្និសីទរបស់ភាគីរដ្ឋ ដូចដែលបានគ្រោងទុកនៅក្នុងមាត្រា ៦៣ កថាខណ្ឌ ៥ និង ៦ នៃអនុសញ្ញានេះ និង

គ. ធានាការសំរបសំរួលចាំបាច់ជាមួយលេខាធិការដ្ឋាននៃអង្គការតំបន់ និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ។

## ជំពូក ៨

## អវសានប្បញ្ញត្តិ

### មាត្រា ៦៥

### ការអនុវត្តអនុសញ្ញា

១. ដោយស្របទៅតាមគោលការណ៍ជាសារវន្តនៃច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីរដ្ឋនីមួយៗ នឹងចាត់វិធានការចាំបាច់រួមទាំងវិធានការរដ្ឋបាល និងនីតិបញ្ញត្តិ ដើម្បីធានាការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញា នេះ ។

២. ភាគីរដ្ឋនីមួយៗ អាចអនុម័តវិធានការធ្ងន់ធ្ងរ ឬ តឹងរឹងអោយច្រើនជាងវិធានការដែលបានចែងដោយអនុសញ្ញានេះ សំរាប់ការទប់ស្កាត់ និង ប្រឆាំងអំពើពុករលួយ ។

### មាត្រា ៦៦

### ការដោះស្រាយជំលោះ

១. ភាគីរដ្ឋ នឹងខិតខំប្រឹងប្រែង ដោះស្រាយជំលោះ ដែលពាក់ព័ន្ធទៅនឹងការបកស្រាយ ឬ ការអនុវត្តអនុសញ្ញានេះ តាមរយៈការចរចា ។

២. រាល់ជំលោះ រវាងភាគីរដ្ឋពីរ ឬ ច្រើន ដែលពាក់ព័ន្ធក្នុងការបកស្រាយ ឬ អនុវត្តអនុសញ្ញានេះ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចាក្នុងពេលវេលាសមហេតុមួយ ជំលោះនោះ នឹងត្រូវបានដាក់ជូនទៅអាជ្ញាកណ្តាល ចំពោះសំណើមួយក្នុងកំណោមសំណើជាច្រើនរបស់ភាគីរដ្ឋ ។ ប្រសិនភាគីរដ្ឋទាំងនោះមិនអាចយល់ព្រមទៅលើការរៀបចំរបស់អាជ្ញាកណ្តាលទេនោះ ក្នុងរយៈពេល ៦ ខែ បន្ទាប់ពីថ្ងៃដាក់សំណើជូនអាជ្ញាកណ្តាល ភាគីរដ្ឋណាមួយក្នុងចំណោមភាគីរដ្ឋទាំងនោះ អាចបញ្ជូនរឿងនោះទៅតុលាការយុត្តិធម៌ អន្តរជាតិ ដោយស្របទៅតាមលក្ខន្តិកៈរបស់តុលាការ ។

៣. នៅពេលមានការហត្ថលេខា ការអោយសច្ចាប័ន ការយល់ព្រម ឬ ការអនុម័តយល់ព្រម ឬ ការព្រម ចូលទៅក្នុងអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗ អាចប្រកាសថា វាមិនចាត់ទុកខ្លួនឯងថាជាប់កិច្ចសន្យា ដោយកថាខណ្ឌ ២នៃមាត្រានេះទេ ។ ភាគីរដ្ឋដទៃទៀត នឹងមិនត្រូវជាប់កិច្ចសន្យា ដោយកថាខណ្ឌ ២ មាត្រានេះ ចំពោះភាគីរដ្ឋណាមួយ ដែលបានធ្វើឋបនីយ ។

៤. ភាគីរដ្ឋណាមួយដែលបានធ្វើឋបនីយដោយស្របទៅតាមកថាខណ្ឌ ៣ នៃមាត្រានេះ នៅពេលណាមួយ អាចដកឋបនីយនោះ ដោយមានការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៦៧

## ការចុះហត្ថលេខា ការអោយសច្ចាប័ន ស្វីការ ការអនុម័តយល់ព្រម និង ការចូលជាធម៌មាន

១. អនុសញ្ញានេះ នឹងបើកចំហចំពោះរដ្ឋទាំងអស់ សំរាប់ការចុះហត្ថលេខ ចាប់ពី ថ្ងៃទី ៩ ដល់ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០០៣ នៅទីក្រុង មារីដា ប្រទេស ម៉ិចសិចកូ បន្ទាប់មក នៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ នាទីក្រុងញូយ៉ក រហូតដល់ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៥ ។

២. អនុសញ្ញានេះ នឹងបើកចំហផងដែរ សំរាប់ការចុះហត្ថលេខា ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលបានចែងថា យ៉ាងហោចណាស់ រដ្ឋសមាជិកមួយនៃអង្គការនោះ បានចុះហត្ថលេខាលើអនុសញ្ញានេះ ដោយស្របទៅតាមកថាខណ្ឌ ១ នៃមាត្រានេះ ។

៣. អនុសញ្ញានេះ គឺជាកម្មវត្ថុនៃការអោយសច្ចាប័ន ស្វីការ ឬការអនុម័តយល់ព្រម។ លិខិតុបករណ៍នៃការអោយសច្ចាប័ន ស្វីការ ឬ ការអនុម័តយល់ព្រម នឹងត្រូវដិកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ អាចដិកល់ទុកលិខិតុបរណ៍នៃការអោយសច្ចាប័ន ស្វីការ ឬ ការអនុម័តយល់ព្រមរបស់ខ្លួន យ៉ាងហោចណាស់ ប្រសិន បើរដ្ឋសមាជិកមួយក្នុងចំណោមរដ្ឋសមាជិកទាំងអស់បានធ្វើដូច្នោះមែន។ នៅក្នុងលិខិតុបរណ៍នៃការអោយសច្ចាប័ន ស្វីការ ឬ ការអនុម័តយល់ព្រមនោះ អង្គការនោះ នឹងប្រកាសវិសាលភាពនៃ សមត្ថកិច្ចរបស់ខ្លួនចំពោះបញ្ហាដែលគ្រប់គ្រងដោយអនុសញ្ញានេះ ។ អង្គការនោះ នឹងជំរាបផងដែរ អំពីទីកន្លែងដិកល់ទុកនៃកំណែប្រែដែលពាក់ព័ន្ធណាមួយ នៅក្នុងវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ។

៤. អនុសញ្ញានេះ បើកបំហសំរាប់ការចូល ដោយរដ្ឋណាមួយ ឬ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយដែលអង្គការនោះ យ៉ាងហោចណាស់ សមាជិករដ្ឋមួយ គឺជាភាគីនៃអនុសញ្ញានេះ ។ លិខិតុ-បករណ៍នៃការចូល នឹងត្រូវដំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នៅពេលការចូលរបស់ខ្លួន អង្គការសមាហរណកម្មតំបន់ នឹងប្រកាសវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួនចំពោះបញ្ហាដែលគ្រប់គ្រងដោយអនុសញ្ញានេះ ។ អង្គការនោះ នឹងជំរាបផងដែរ អំពីទីកន្លែងដំកល់ទុកនៃកំណែប្រែដែលពាក់ព័ន្ធណាមួយ នៅក្នុងវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ៦៨

## ការចូលជាធរមាន

១. អនុសញ្ញានេះ នឹងចូលជាធរមាន រយៈពេលកៅសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដំកល់លិខិតុបរណ៍នៃការអោយសច្ចាប័ន ស្ទីការ ការអនុម័តយល់ព្រម ឬ ការចូល។ សំរាប់គោលបំណងនៃកថាខណ្ឌនេះ លិខិតុបករណ៍ណាមួយដែលដំកល់ទុកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងមិនត្រូវបានគេរាប់បញ្ចូល ដែលបន្ថែមទៅនឹងលិខិតុបករណ៍ដែលដំកល់ទុកដោយរដ្ឋសមាជិកនៃអង្គការនោះ ។

២. សំរាប់រដ្ឋ ឬ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នីមួយៗ ការអោយសច្ចាប័ន ស្ទីការ ការអនុម័តយល់ព្រម ឬ ការយល់ព្រម ចំពោះអនុសញ្ញានេះ បន្ទាប់ពីការដំកល់លិខិតុបករណ៍រយៈពេល សាមសិបថ្ងៃនៃអំពើនោះ អនុសញ្ញានេះ នឹងចូលជាធរមាន សាមសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដំកល់ទុកដោយរដ្ឋ ឬ អង្គការនៃលិខិតុបករណ៍ដែលពាក់ព័ន្ធ ឬ នៅថ្ងៃអនុសញ្ញានេះ ចូលជាធរមានដោយស្របទៅតាមកថាខណ្ឌ ១ នៃមាត្រានេះ វិធីនេះគឺយឺតជាង ។

## មាត្រា ៦៩

## ការធ្វើវិសោធនកម្ម

១. បន្ទាប់ពីផុតកំណត់រយៈពេលប្រាំឆ្នាំ ចាប់ពីអនុសញ្ញានេះចូលជាធរមាន ភាគីរដ្ឋមួយ អាចស្នើអោយមានការធ្វើវិសោធនកម្ម និង បញ្ជូនវាទៅអោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលអង្គការនោះ នឹងបញ្ជូនបន្ត សំណើវិសោធនកម្មដែលបានស្នើឡើងបញ្ជូនទៅភាគីរដ្ឋផ្សេងៗទៀត និងទៅសន្និសីទ របស់ភាគីរដ្ឋ ចំពោះអនុសញ្ញា សំរាប់ការពិចារណា និង ការសំរេចចិត្តទៅលើសំណើនេះ ។

សន្និសីទរបស់ភាគីរដ្ឋ នឹងខិតខំប្រឹងប្រែង ដើម្បីសំរេចបានការឯកភាពគ្នាលើការធ្វើ វិសោធនកម្មនីមួយៗ ។ ប្រសិន បើកិច្ចខិតខំប្រឹងប្រែងទាំងអស់ ចំពោះការឯកភាព ត្រូវបានគេបញ្ចេញអស់ ហើយគ្មានកិច្ចព្រមព្រៀង ណាមួយត្រូវបានសំរេច ចំពោះមធ្យោបាយក្រោយបំផុត ការធ្វើវិសោធនកម្ម នឹងតំរូវអោយមានការ អនុម័តសំលេងភាគីច្រើន ពីរភាគបី នៃវត្តមានរបស់ភាគីរដ្ឋ និង ការបោះឆ្នោត នៅពេលប្រជុំនៃសន្និសីទរបស់ភាគីរដ្ឋ។

២. ក្នុងបញ្ហាដែលទាក់ទងជាមួយសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងអនុវត្តសិទ្ធិរបស់គេដើម្បីបោះឆ្នោតដែលស្ថិតនៅក្រោមច្បាប់នេះ ជាមួយនិងចំនួនមួយនៃសំលេងឆ្នោត ស្មើនឹងចំនួននៃរដ្ឋសមាជិករបស់គេដែលជាភាគីចំពោះអនុសញ្ញានេះ ។ អង្គការនោះនឹងមិនអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោត ប្រសិនបើរដ្ឋសមាជិករបស់ខ្លួនអនុវត្តសិទ្ធិរបស់ខ្លួន និងត្រឡប់វិញ ។

៣. ការវិធ្វើសោធនកម្មដែលបានអនុម័តដោយស្របទៅនឹងកថាខណ្ឌ១នៃមាត្រានេះ គឺជាកម្មវត្ថុចំពោះការអោយសច្ចាប័ន ស្វីការ ឬ ការអនុម័តយល់ព្រមដោយភាគីរដ្ឋ។

៤. ការធ្វើវិសោធនកម្ម ដែលបានអនុម័តដោយស្របទៅនឹងកថាខណ្ឌ ១ នៃមាត្រានេះ នឹងចូលជាធរមានចំពោះភាគីរដ្ឋមួយក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទ នៃការដំកល់ទុកជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនូវលិខិតុបករណ៍នៃការអោយសច្ចាប័ន ស្វីការ ឬ ការអនុម័តយល់ព្រមនៃការធ្វើ វិសោធនកម្មនោះ ។

៥. នៅពេលដែលការធ្វើវិសោធនកម្មចូលជាធរមាន វានឹងកំពុងចងទៅលើភាគីរដ្ឋទាំងនោះ ដែលបានសំដែងនូវការយល់ព្រមរបស់ខ្លួន ចំពោហការជាប់ដោយកិច្ចសន្យា ។

## មាត្រា ៧០

## ការប្រកាសមិនយល់ព្រម

១. ភាគីរដ្ឋមួយ អាចប្រកាសមិនយល់ព្រមទៅលើអនុសញ្ញានេះ ដោយការជូនដំណឹងជាលាយលក្ខអក្សរទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ ការប្រកាសមិនយល់ព្រមនេះ នឹងមានប្រសិទ្ធភាពបន្ទាប់ពីរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹងដោយអគ្គលេខាធិការ ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ នឹងឈប់ជាភាគីចំពោះអនុសញ្ញានេះ នៅពេលណារដ្ឋសមាជិករបស់វាទាំងអស់បានប្រកាសមិនព្រមទទួលយកអនុសញ្ញានេះ ។

## មាត្រា ៧១

## ការដាក់ដំកល់ទុក និង ភាសា

១. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវបានគេជ្រើសរើសជាកន្លែងដំកល់ទុកអនុសញ្ញានេះ ។

២. ឯកសារដើមនៃអនុសញ្ញានេះជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រូស្ស៊ី និង អេស្ប៉ាញ៉ុល ក្នុងនោះ អត្ថបទនីមួយៗគឺមានតំលៃស្មើៗគ្នាតាមផ្លូវច្បាប់ នឹងត្រូវបានដំកល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

ដើម្បីជាសាក្សី និង ក្នុងនាមជាតំណាងពេញសិទ្ធិនៃរដ្ឋាភិបាលរបស់ខ្លួននីមួយៗដែលបានទទួលការចាត់តាំង និង ត្រូវបានអនុញ្ញាតិ អោយចុះហត្ថលេខាលើអនុសញ្ញានេះ ។